# អត្ថបទព្រះធម៌
## ភាគ២



ដោយ
ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណ**
ព.ស.២៥៥២ គ.ស.២០០៨
www.hoksavann.org

# ប្រវត្តិរូបសង្ខេប
# ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

ប្រសូត ថ្ងៃ១០មីនា១៩៤០ នៅឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ ប្រទេសកម្ពុជា ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណ** ជាបុត្រទី៣ក្នុងបណ្ដាបុត្រទាំង៥នាក់ បិតានាម **ហុក ហៃ** មាតានាម **សុខ យឹម**។ ព្រះជន្ម១៥ឆ្នាំ បានបួសជាសាមណេរ លុះព្រះជន្ម២១ឆ្នាំ បានបំពេញឧបសម្បទាជាភិក្ខុ។ កាលប្រព្រឹត្តការណ៍ឆ្នាំ១៩៧៥ ព្រះអង្គបានភៀសខ្លួនទៅប្រទេសថៃ បន្ទាប់មកបានទៅរស់នៅទីក្រុងម៉ុងរេអាល់ ប្រទេសកាណាដា នៅថ្ងៃ២៣មេសា១៩៨១។

កាលពីកុមារភាព ព្រះអង្គបានសិក្សាអក្សរសាស្ត្រជាតិចប់បឋមសិក្សា។ ពេលចូលកាន់ផ្នួស ព្រះអង្គបានសិក្សាធម្មវិន័យទាំង៣ថ្នាក់ត្រីទោឯក បានសិក្សានៅពុទ្ធិកសិក្សា ជាប់ពុទ្ធិកបឋមសិក្សា ពុទ្ធិកមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ និងពុទ្ធិមហាវិទ្យាល័យព្រះសីហនុរាជ។ ឆ្លៀតទៅរៀនអក្សរសាស្ត្រនិងមនុស្សសាស្ត្រនៅសាកលវិទ្យាល័យភ្នំពេញ។ ក្រៅពីសិក្សាគន្ថធុរៈ ព្រះអង្គបានប្រតិបត្តិវិបស្សនាធុរៈអស់ជាច្រើនឆ្នាំ។

នៅបរទេស ព្រះអង្គបានសិក្សាបន្តជាប់អនុបណ្ឌិត (Master's degree) ទីបំផុត ជាប់បណ្ឌិតទស្សនាវិជ្ជាផ្នែកព្រះពុទ្ធសាសនា (Doctor of Philosophy on Buddhism) នៅសាកលវិទ្យាល័យញូដេលលី្ល នៃប្រទេសឥណ្ឌា នៅថ្ងៃ២៨កុម្ភៈ ២០០៤។

នៅក្នុងប្រទេសក៏ដូចជានៅក្រៅប្រទេស ព្រះអង្គបានជួយសង្គមខ្មែរយ៉ាងច្រើនផ្នែកបញ្ញាស្មារតី ដោយវិធីទេសនាពន្យល់តាមមាគ៌ាព្រះពុទ្ធសាសនា។

---

## <u>មាតិកាអត្ថបទ</u>


- ប្រវត្តិរូបសង្ខេប ព្រះតេជព្រះគុណបណ្ឌិត **ហុក  សាវណ្ណា**

| | |
|---|---|
| ១. អរិយធ្វាក្នុងព្រះពុទ្ធសាសនា | ១ |
| ២. ការច្បាំងនឹងកិលេសតណ្ហា | ៤ |
| ៣. សតិបដ្ឋាន | ៦ |
| ៤. ការគ្រប់គ្រងខ្លួន | ១០ |
| ៥. ព្រហ្មវិហារធម៌៤ | ១៤ |
| ៦. បាប និង បុណ្យ | ១៧ |
| ៧. ព្រហ្មលិខិត | ២០ |
| ៨. និស្ស័យ និង ឧបនិស្ស័យ | ២៣ |
| ៩. ផលនៃការប្រទូស្សរាយ | ២៥ |
| ១០. ពាល និង បណ្ឌិត | ២៨ |
| ១១. សតិ និង សម្បជញ្ញៈ | ៣១ |
| ១២. កម្មចែកសត្វ | ៣៣ |
| ១៣. ផ្លូវប្រតិបត្តិចេញចាកទុក្ខ | ៣៦ |
| ១៤. ជ័យជំនះដ៏ប្រសើរ | ៤០ |
| ១៥. អគតិធម៌៤ | ៤២ |
| ១៦. ការប្រាថ្នាសេចក្ដីសុខ | ៤៥ |


---

វិភាគដោយព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា**

១៧. ពាក្យពិតជាពាក្យពុំស្លាប់ ៤៨

១៨. សាមគ្គីធម៌ ៥១

១៩. ធម្មាធិបតេយ្យ និង ប្រជាធិបតេយ្យ ៥៥

២០. អនត្តាធម៌របស់ព្រះពុទ្ធសាសនា ៥៩

២១. ព្រះពុទ្ធប្រោសមាលុង្ក្យបុត្រ ៦៣

២២. នាមបញ្ញត្តិរបស់អ្នកប្រតិបត្តិព្រះពុទ្ធសាសនា ៦៦

២៣. សិទ្ធិមនុស្សតាមន័យព្រះពុទ្ធសាសនា ៧០

២៤. អត្ថន័យរបស់ពាក្យលោភៈ ៧៤

២៥. បុគ្គលធ្វើឱ្យអ្នកដទៃមានទុក្ខ តែងជាប់ជំពាក់ពៀរ ៧៩

២៦. បុណ្យកុសលដែលធ្វើជាតិនេះ
ពុំមែនឱ្យផលតែជាតិខាងមុខតែម្យ៉ាងទេ ៨២

២៧. ជំនួញខុស៥ប្រការ ៨៥

២៨. ចូរយកខ្លួន និង ធម៌ជាទីពឹង ៨៩

២៩. គុណវិបត្តិនៃការអុជធូប ៩១

- នាមអ្នកបរិច្ចាគបច្ច័យបោះពុម្ព

# អវិជ្ជាក្នុងព្រះពុទ្ធសាសនា

**អវិជ្ជា** តាមន័យរបស់ព្រះពុទ្ធសាសនាជាសភាវធម៌ សំដៅយកការមិនដឹងនូវអរិយសច្ច៤គឺ មិនដឹងនូវទុក្ខ មិនដឹងនូវហេតុដែលនាំឱ្យកើតទុក្ខ មិនដឹងនូវការរំលត់ទុក្ខ មិនដឹងនូវផ្លូវប្រតិបត្តិទៅកាន់ការរំលត់ទុក្ខ។ **អវិជ្ជា**ជានាមធម៌ ពុំមែនជារូបធម៌ ដូចជាដីទឹកភ្លើងខ្យល់ឡើយ គឺជាគំនិតយល់ខុស បើគំនិតយល់ត្រូវហៅថា **មានវិជ្ជា** គឺមានចំណេះយល់ច្បាស់ក្នុងអរិយសច្ច៤។ អវិជ្ជាផ្លូវធម៌ផ្សេងពីអវិជ្ជាផ្លូវលោក។ **អវិជ្ជា** ផ្លូវលោកសំដៅយកការពុំចេះនូវវិជ្ជាទាំងឡាយដែលមនុស្សលោកបង្កើតឡើង ដូចជាពុំចេះអក្សរសាស្ត្រ ពុំចេះប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ចរិយាសាស្ត្រ ទស្សនវិជ្ជា និងបច្ចេកវិទ្យាផ្សេងៗជាដើម។ ឯអវិជ្ជាផ្លូវធម៌ ពុំមែនល្ងង់ព្រោះពុំចេះនូវវិជ្ជាទាំងនេះទេ ព្រោះវិជ្ជាផ្លូវលោកទាំងនេះមានភាពពិតតាមលោកសច្ចៈ។ អ្នកមានវិជ្ជាផ្លូវលោកទាំងនេះពុំឈ្មោះថាអស់អវិជ្ជាឡើយ គឺនៅមានអវិជ្ជាដដែល អវិជ្ជាព្រោះពុំដឹងនូវអរិយសច្ចដែលធ្វើឱ្យទុក្ខអស់ទៅ មានជាតិទុក្ខជាដើម។ អវិជ្ជាពុំដឹងថាខ្លួនមនុស្សសត្វចែកជាខន្ធ៥គឺ **រូប វេទនា សញ្ញា សង្ខារ** និង **វិញ្ញាណ** ដែលប្រព្រឹត្តទៅដោយលក្ខណៈ៣យ៉ាងគឺ **អនិច្ចំ** មិនទៀងជា **ទុក្ខ** និងជា **អនត្តា** ពុំមែនខ្លួនប្រាណ។ ព្រះពុទ្ធសំដែងថា សេចក្តីល្ងង់អ្វីពុំស្មើនឹងសេចក្តីល្ងង់ក្នុងខន្ធ៥ឡើយ។ ការស្គាល់លក្ខណៈខន្ធ៥ ទើបធ្វើទុក្ខឱ្យអស់ទៅបាន។ វិជ្ជាផ្លូវលោកគ្រាន់តែជួយសម្រួលឱ្យរស់នៅក្នុងសង្គម បានសុខស្រួលខ្លះប៉ុណ្ណោះ

ប៉ុន្តែពុំអាចធ្វើទុក្ខមានជាតិទុក្ខជាដើមឱ្យអស់ទៅបានឡើយ។ ចំណែកការមានវិជ្ជាក្នុងខន្ធ៥ ផ្នែកវិបស្សនាវិជ្ជាទើបធ្វើទុក្ខឱ្យអស់ទៅបាន។ អវិជ្ជាកន្លែងខ្លះ **វិគ្គហៈ** ថា ធម្មជាតិបាននូវអំពើដែលគេមិនចង់បាន បានដល់ទុច្ចរិត៣ យ៉ាងគឺ **កាយទុច្ចរិត វចីទុច្ចរិត** និង **មនោទុច្ចរិត**។ មួយទៀតថា ធម្មជាតិមិនបាននូវអំពើដែលគេត្រូវបាន បានដល់ **កាយសុចរិត វចីសុ-ចរិត** និង **មនោសុចរិត**។ អវិជ្ជាពុំដឹងនូវវត្ថុ៨ប្រការគឺ **អរិយសច្ច៤** ហើយបន្ថែម៤ខាងចុងគឺ ពុំដឹងនូវខន្ធអតីត ពុំដឹងនូវខន្ធអនាគត ពុំដឹងនូវខន្ធទាំងអតីតនិងអនាគត និងពុំដឹងនូវបដិច្ចសមុប្បាទធម៌ គឺធម៌កើតរលត់តគ្នាដោយហេតុដោយបច្ច័យ ដូចជាអវិជ្ជាកើតមាននាំឱ្យមានសង្ខាររហូតជាតិកើតមាននាំឱ្យមានជរានិងមរណៈជាដើម។ ព្រះពុទ្ធសំដែងថា តថាគតរកពុំឃើញធម៌ណាមួយ ដែលមានទោសដូចអវិជ្ជានេះឡើយ អវិជ្ជាមានទោសធ្ងន់ជាងធម៌ដទៃដោយហេតុថា មនុស្សសត្វធ្វើខុសដោយសារអវិជ្ជា ការពុំដឹង នូវអរិយសច្ច៤ គឺពុំដឹងនូវទុក្ខ នូវហេតុដែលនាំឱ្យកើតទុក្ខជាដើមនេះឯង។ ប្រៀបដូចមនុស្សងងឹតភ្នែកពីកំណើត ហើយវង្វេងផ្លូវក្នុងព្រៃតែងតែដើរខុសផ្លូវជាធម្មតា។ **អវិជ្ជា** ប្រៀបដូចសត្វមមាចមមង់ដែលឃើញអណ្តាតភ្លើងភ្លឺថ្លាក៏ស្មានខុសថាជាពន្លឺគួរជាទីរីករាយសប្បាយឥតបានដឹងថា ភ្លើងនោះក្តៅក៏ហើរចូលទៅដល់នូវការក្សិណក្ស័យជីវិត។ ប្រៀបម្យ៉ាងទៀតដូចសត្វដង្កូវនាងដែលរុំព័ទ្ធខ្លួននៅក្នុងសំបុក បានត្រូវគេយកទៅស្ងោរដើម្បីយកសរសៃសូត្រដែលរុំព័ទ្ធខ្លួនវាធ្វើជាសូត្រ ដើម្បីត្បាញធ្វើសំពត់ស្លៀកពាក់ក៏ក្ស័យជីវិតទៅ។

សេចក្តីទាំងអស់នេះប្រៀបដូចជាបុគ្គលប្រកបដោយ **អវិជ្ជា** បិទបាំងពុំឱ្យឃើញការពិតហើយប្រព្រឹត្តតាមការយល់ខុសនោះ ក៏ដល់នូវសេចក្តីវិនាសទៅ។ **អវិជ្ជា** អាចកម្ចាត់បានដោយការសិក្សាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយប្រតិបត្តិតាមសមថវិបស្សនាឱ្យឃើញអរិយសច្ចទាំង៤ ពន្លុះមគ្គផលនិ-ព្វានរហូតអរហត្តផល។ ពុទ្ធសាសនិកជនដែលបានសិក្សាយល់ច្បាស់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ទោះពុំអាចលះបង់អវិជ្ជានេះបានក្នុងពេលនេះ ក៏ឈ្មោះថាដើរត្រូវតាមផ្លូវដែលត្រូវលះហើយ។ **អវិជ្ជា** បិទបាំងមិនឱ្យឃើញការពិតនេះ មានទោសទាំងផ្លូវលោកនិងផ្លូវធម៌។

# ការច្បាំងនឹងកិលេសតណ្ហា

វិធីទេសនារបស់ព្រះពុទ្ធមានកន្លែងខ្លះ ព្រះអង្គសំដែងជា **ឧបមាណវិធី** គឺជាវិធីប្រៀបធៀបដើម្បីឱ្យមនុស្សឆាប់យល់ធម៌ ដូចជាព្រះអង្គប្រៀបអ្នកស្វែងរកធម៌ដូចអ្នកធ្វើចម្បាំង គឺយោធាទាហានត្រូវមានសមត្ថភាពនិងសេចក្ដីអង់អាចក្លាហានប្រកបដោយអង្គបីគឺ

**១-ទូរេបាតី** អ្នកបាញ់បានឆ្ងាយ

**២-អក្ខណវេធី** អ្នកបាញ់មិនខុស

**៣-មហតោ កាយស្ស បទាលេតា** អ្នកទម្លាយគំនរធំបាន។ នេះហៅថាយោធាជីវធម៌ ប្រែថា ធម៌សម្រាប់អ្នករស់នៅជាហាន។ ពាក្យថាបាញ់បានឆ្ងាយគឺប្រសប់បាញ់បានឆ្ងាយទៅមុខក្ដីទៅលើក្ដីឬមានអាវុធសំខាន់សំរាប់ទៅកាន់ទីឆ្ងាយសំដៅទៅរកទ័ពបច្ចាមិត្តឬគ្រឿងការពាររបស់បច្ចាមិត្តដែលនៅឆ្ងាយៗ នេះជាអង្គទី១។ បាញ់មិនខុសគឺដៃត្រង់ឬមានអាវុធមានគ្រឿងតម្រង់ឱ្យត្រង់មិនខុសទៅរកបច្ចាមិត្តធ្វើឱ្យបច្ចាមិត្តវិនាសអន្តរាយ នេះជាអង្គទី២។ ទម្លាយគំនរធំៗបាន គឺមានចិត្តក្លាហានមិនខ្លាចស្លាប់ ហ៊ានកាន់អាវុធចូលខ្លួនទៅបំផ្លាញទ័ពបច្ចាមិត្រ ឬគ្រឿងការពាររបស់បច្ចាមិត្តឱ្យបែកបាក់ខ្ទេចខ្ទីបាន នេះជាអង្គទី៣។ ទាហានដែលប្រកបដោយអង្គ៣នេះរាប់ថាជាទាហានអាចការពារជាតិសាសនានិងប្រទេសរបស់ខ្លួនបាន។ ព្រះពុទ្ធបានត្រាស់ប្រៀបប្រដូចយោធាឬទាហានមកពុទ្ធបរិស័ទជាអ្នកច្បាំងនឹងកិលេសតណ្ហា

ដែលស្ថិតនៅក្នុងចិត្តមនុស្សសត្វថា ម្នាលភិក្ខុទាំងឡាយពុទ្ធបរិស័ទគឺជាសាវ័ក សាវិកា អ្នកប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនា ហៅថា អ្នកច្បាំងនឹងសត្រូវគឺ **កិលេស** ត្រូវតែក្លាហានអង់អាចជានិច្ចដោយពុំភ្លេចខ្លួន ពីព្រោះកិលេសគ្រឿងសៅហ្មងចិត្តតែងជំរុញចិត្តឱ្យធ្វើបាបកម្ម។ ទាហានមានចិត្តក្លាហានមិនខ្លាចស្លាប់ហ៊ានចូលទៅតស៊ូនឹងសត្រូវយ៉ាងណា អ្នកប្រតិបត្តិជាអ្នកក្លាហានមិនគិតនឿយហត់មិនខ្លាចស្លាប់ តាំងព្យាយាមចំរើនធម៌ក្នុងព្រៃក្នុងផ្ទះដែលស្ងាត់ ដើម្បីកម្ចាត់សត្រូវគឺកិលេសក៏យ៉ាងនោះដែរ។ ពាក្យថា **បាញ់** គឺសំដៅយកការពិចារណាឃើញច្បាស់នូវបញ្ចក្ខន្ធ។ ពាក្យថា **បាញ់** បានឆ្ងាយ គឺពុំមែនពិចារណាតែខន្ធរបស់ខ្លួនទេ គឺពិចារណានូវខន្ធរបស់មនុស្សទូទៅថាសុទ្ធតែជា **អនិច្ចំ ទុក្ខំ** និង**អនត្តា** ដូចគ្នាទាំងអស់។ ពាក្យថា បាញ់មិនខុស គឺតម្រង់ចិត្តវិញ្ញាណទៅរកអរិយសច្ច៤គឺ សេចក្តីទុក្ខ ហេតុដែលនាំឱ្យកើតទុក្ខ ការរំលត់ទុក្ខនិងផ្លូវទៅកាន់ការរំលត់ទុក្ខ។ពាក្យថាទម្លាយនូវគំនរធំ គឺទម្លាយឬកម្ចាត់បង់នូវអវិជ្ជាដែលជាធម្មជាតិពុំដឹងនូវអរិយសច្ច៤នេះឯង ព្រោះអវិជ្ជានេះចាត់ជាគំនរធំ ដែលជាហេតុបច្ច័យនាំឱ្យកើតរូបធម៌និងនាមធម៌ គឺខន្ធ៥របស់មនុស្សសត្វជាថ្មីទៀត។

# សតិបដ្ឋាន

សតិបដ្ឋានសូត្រនេះ ព្រះពុទ្ធសំដែងក្នុងដែន**កុរុ**ប្រារព្ធចំពោះភិក្ខុទាំងឡាយ ថា ម្នាលភិក្ខុទាំងឡាយផ្លូវគឺសតិបដ្ឋាន៤ជាផ្លូវមូលតែមួយប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីលះបង់សេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ៤ប្រការ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន។ **សតិបដ្ឋាន** ប្រែថាការតម្កល់ស្មារតីមាន៤ប្រការគឺ

**១-<u>កាយានុបស្សនាសតិបដ្ឋាន</u>** ប្រែថា ការតម្កល់ស្មារតី ពិចារណារឿយៗនូវកាយដោយលក្ខណៈ៥យ៉ាងគឺ

**ក.** ដោយកំណត់ខ្យល់ដកដង្ហើមចេញចូលត្រង់រន្ធចុងច្រមុះ។

**ខ.** កំណត់ពិចារណាឥរិយាបថគឺ **ដេក ដើរ ឈរ អង្គុយ** ត្រូវកំណត់ដឹងជាពិសេសគ្រប់ចលនាការកម្រើករាងកាយនិងអវយវៈទាំងអស់ ត្រូវកំណត់ដឹង។

**គ.** កំណត់ពិចារណានូវកាយប្រកបដោយអាការៈ៣២មាន **កេសា លោមា នខា ទន្តា តចោ**...គឺសក់ រោម ក្រចក ធ្មេញ ស្បែកជាដើម ថាជាវត្ថុពុំស្អាត។

**ឃ.** កំណត់ពិចារណានូវរូបរាងកាយថា គ្រាន់តែជាធាតុ៤ គឺ ធាតុទឹក ធាតុដី ធាតុភ្លើង ធាតុខ្យល់ប៉ុណ្ណោះ ពុំមែនជាសត្វជាបុគ្គលមានសភាពសោះសូន្យទទេ។

**ខ.** ពិចារណានូវ**អសុភៈ១០**មាន **អសុភៈ** ហើមប៉ោងរហូតដល់ **អសុភៈ** មានតែរាងឆ្អឹង មកប្រៀបធៀបនឹងខ្លួនឯងថាជាវត្ថុពុំស្អាត។

**២.__វេទនានុបស្សនាសតិបដ្ឋាន__** ប្រែថា ការតម្កល់សតិស្មារតីពិចារណារឿយៗនូវវេទនា។ **វេទនា** ប្រែថា ការដឹងឬការទទួលអារម្មណ៏ជាសុខជាទុក្ខ។ ការទទួលអារម្មណ៏ជាសុខជាទុក្ខតាមផ្លូវកាយ ត្រូវកំណត់ដឹង។ សោមនស្សទោមនស្សឬឧបេក្ខាតាមផ្លូវចិត្តត្រូវកំណត់ដឹងថាគ្រាន់តែជាវេទនាប៉ុណ្ណោះ។

**៣.__ចិត្តានុបស្សនាសតិបដ្ឋាន__** ប្រែថា ការតម្កល់សតិស្មារតីពិចារណារឿយៗនូវចិត្ត។ ចិត្តមាន៤ប្រភេទ គឺកាមាវចរចិត្តជាចិត្តរបស់កាមាវចរសត្វដែលប្រព្រឹត្តទៅក្នុងរូប សំឡេង ក្លិន រស សម្ផស្ស រូបាវចរចិត្តជាចិត្តប្រព្រឹត្តទៅក្នុងរូបជ្ឈាន អរូបាវចរចិត្តជាចិត្តដែលប្រព្រឹត្តទៅក្នុងអរូបជ្ឈាន លោកុត្តរចិត្តជាចិត្តដែលឆ្លងចាកភពបី ត្រូវកំណត់ដឹងតាមប្រភេទចិត្តដែលកើតឡើង។

**៤.__ធម្មានុបស្សនាសតិបដ្ឋាន__** ប្រែថា ការតម្កល់សតិពិចារណារឿយៗនូវធម៌។ ធម៌ក្នុងទីនេះសំដៅយកនីវរណធម៌៥ ឧបាទានក្ខន្ធ៥ អាយតនៈ១២ ពោជ្ឈង្គៈ៧ និង អរិយសច្ច៤។ នីវរណធម៌៥គឺ កាមច្ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ និង វិចិកិច្ឆា។ ខន្ធ៥គឺ រូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណ។ អាយតនៈ១២គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ មនោ រូប សំឡេង ក្លិន រស សម្ផស្ស និង ធម្មៈ។ ពោជ្ឈង្គៈ ប្រែថា ធម៌ជាអង្គនៃការត្រាស់ដឹងមានសតិសម្ពោជ្ឈង្គៈជាដើម។ ធម៌ទាំងអស់នេះទាំងកុសលទាំងអកុសលកើត

ឡើងត្រូវកំណត់ដឹង។ ធម្មានុបស្សនាសតិបដ្ឋានទី៤នេះ សំដៅយកវត្ថុដែលចិត្តគោងមកជាអារម្មណ៍។

ការកំណត់ពិចារណាតាមសតិបដ្ឋានទាំង៤នេះដើម្បីឱ្យកើតសតិបញ្ញា កើតសម្បជញ្ញៈឃើញការកើតរលត់របស់សង្ខារ ដែលពុំមែនជាតួខ្លួន។ **សតិបដ្ឋាន** នេះបានត្រូវអ្នកដឹកនាំវិបស្សនាជាតិភូមាសម្រួលធ្វើហៅថាប៉ោងផត ហើយថែមយកមកបន្ថែមថា **ប៉ោងហ្ន៎ ផតហ្ន៎**។ ការកំណត់ពិចារណានេះ ដើម្បីឱ្យចូលក្នុងលក្ខណៈ **អនិច្ចំ ទុក្ខំ** និង **អនត្តា** ដែលជាលក្ខណៈរបស់វិបស្សនា។ ក្នុងសូត្រនេះ បានបញ្ជាក់ថា បុគ្គលដែលបានចំរើននូវសតិបដ្ឋានឱ្យបានហ្មត់ចត់ អាចសម្រេចព្រះអរហន្តឬជាអនាគាមី ក្នុងរវាង៧ឆ្នាំឬ៧ខែឬក៏៧ថ្ងៃ បើមានឧបនិស្ស័យពីមុនផងរំផង។

## សេចក្តីសង្ខេប

**សតិបដ្ឋាន** ប្រែថា ការតាំងស្មារតី គឺសតិពិចារណាកំណត់ដល់នូវ **កាយ វេទនា ចិត្ត** និង **ធម្មៈ**។ ការពិចារណាកាយ គឺគ្រប់ចលនាកាយត្រូវកំណត់ដឹង។ **វេទនា** ជាសុខជាទុក្ខ ប្រព្រឹត្តទៅតាមផ្លូវកាយ និងសោមនស្ស ទោមនស្ស ឧបេក្ខាប្រព្រឹត្តទៅតាមផ្លូវចិត្តត្រូវកំណត់ដឹង។ ចិត្តនឹកគិតទៅរកវត្ថុណាត្រូវកំណត់ដឹង។ **ធម្មៈ** បានដល់អ្វីដែលចិត្តនឹកគិតត្រូវកំណត់ដឹង។ ត្រូវកំណត់ថាកាយវេទនាចិត្តនិងធម្មៈ គ្រាន់តែជាកាយជាវេទនាជាចិត្តនិងជាធម្មៈប៉ុណ្ណោះ ពុំមែនជាសត្វជាបុគ្គលមានសភាពសោះសូន្យទទេ។ ការចំរើន

សតិបដ្ឋាននេះ អាចធ្វើបានគ្រប់ឥរិយាបថទាំង៤ គឺដេក ដើរ ឈរ អង្គុយ។ ការកំណត់តាមសតិបដ្ឋានទាំង៤នេះ ក្រៅពីឥរិយាបថអង្គុយគេអាចដើរចង្ក្រម យ៉ាងយឺត១ កំណត់ឆ្វេងស្តាំតាមជំហានដែលឈានទៅ។ វិធីចង្ក្រមអាចធ្វើចិត្ត ឱ្យឆាប់មូលល្អ។

ការកំណត់ស្មារតីតាមសតិបដ្ឋាន៤នេះ បើគិតទៅតាមផ្លូវលោកវិញមានប្រយោជន៍ណាស់សម្រាប់សង្គមមនុស្ស ព្រោះអ្នកចំរើនសតិបដ្ឋាន៤ តែងមាន ស្មារតីល្អ មិនភ្លេចភ្លាំងមិនវង្វេងស្មារតី ហើយជាអ្នកពុំសូវលោភពុំសូវក្រោធ ទៀតផង ដែលជាសមាជិកដ៏ល្អរបស់សង្គម។ បើមានសមាជិកដ៏ល្អច្រើនគ្នា នាំឱ្យសង្គមលូតលាស់ខាងសីលធម៌ ហើយជំរុញឱ្យលូតលាស់ខាងសម្ភារៈផង។

# ការគ្រប់គ្រងខ្លួន

គាថាមួយបទនៅក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសាសនាពោលថា **នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ ឯវំ គោបេថ អត្តានំ ខណោ វោ មា ឧបច្ចគា ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា** ប្រែថា អ្នកទាំងឡាយចូរគ្រប់គ្រងខ្លួន ឱ្យដូចជាគេថែរក្សាការពារទីកជីនគរ ដែលតាំងនៅជាយដែនទាំងខាងក្នុងទាំងខាងក្រៅយ៉ាងនោះឯង។ ខណៈចូរកុំកន្លងនូវអ្នកទាំងឡាយឡើយ ព្រោះបុគ្គលទាំងឡាយអ្នកមានខណៈកន្លងហួសទៅហើយ រមែងសោកស្តាយ ហើយសោយសោកនៅក្នុងនរក។

ពាក្យថា អ្នកទាំងឡាយចូរគ្រប់គ្រងខ្លួន បានសេចក្តីថា ត្រូវអប់រំចិត្តឱ្យស្ថិតនៅក្នុងកុសលធម៌ជានិច្ចដោយសមថវិបស្សនាបិទបាំងរារាំងកុំឱ្យអកុសលចូលមកក្នុងចិត្តបាន ដោយសេចក្តីព្យាយាម៤យ៉ាងគឺ លះបាបដែលកើតមានហើយ១ ឃាំងកុំឱ្យបាបថ្មីចូលមកក្នុងចិត្តបាន១ កុសលណាកើតមានហើយត្រូវរក្សាទុក១ កុសលណាដែលពុំទាន់កើតមានត្រូវធ្វើឱ្យកើតមានឡើង១។ ក្នុងគាថានេះប្រៀបធៀបនៅក្នុងការគ្រប់គ្រងចិត្ត ដូចគេថែរក្សាការពារទីកជីនគរដែលស្ថិតនៅជាយដែន ព្រោះនៅជាយដែនជាជនបទ ស្ថិតនៅដាច់ស្រយាលពីក្រុងតែងមានចោរប្រព្រឹត្តអំពើចោរកម្មលួចប្លន់ធ្វើបាបអ្នកស្រុក។ មួយទៀត នៅជាយដែលរវាងប្រទេសនីមួយៗ តែងមានបញ្ហាព្រំប្រទល់ដែនដូចជាប្រទេសកម្ពុជាតែងចោទប្រទេសជិតខាងទាំងពីរ គឺប្រទេសវៀតណាម និងប្រទេសថៃ

ថា បានរំលោភឈ្លានពានទឹកដីនៃប្រទេសកម្ពុជា ដោយការបង្ខិតព្រំប្រទល់ដែនចូលមកក្នុងទឹកដីនៃប្រទេសកម្ពុជា។ ដូច្នេះហើយបានជាប្រទេសនីមួយៗតែងរក្សាការពារព្រំប្រទល់ដែនរៀងៗខ្លួន។ មធ្យោបាយការពារព្រំប្រទល់ដែនមានវិធីច្រើនយ៉ាង បើដីគោកគេចាត់ឱ្យមានប៉ុស្តិ៍យាម។ បើមានព្រៃមានភ្នំ នោះជារបងធម្មជាតិប្រសើរណាស់ ត្រូវព្រមព្រៀងកំណត់ដោយប្រទេសដែលជាប់នឹងព្រំដែន។ វិធីមួយទៀត គឺការធ្វើថ្នល់ព័ទ្ធជុំវិញព្រំប្រទល់ដែន។ ពិសេសការពារព្រំប្រទល់ដែនដ៏ស័ក្តិសិទ្ធិបំផុត គឺរកមធ្យោបាយឱ្យប្រជាពលរដ្ឋទៅរស់នៅព្រំប្រទល់ដែនឱ្យបានច្រើន ដើម្បីសម្រេចបំណងនេះ រដ្ឋត្រូវធ្វើផ្លូវគមនាគមន៍ គឺផ្លូវថ្នល់ពីទីក្រុងទៅព្រំប្រទល់ដែន បង្កើតទីផ្សារ បង្កើតសាលារៀន បង្កើតវត្ត ដោះស្រាយបញ្ហាទឹក រក្សាសន្តិសុខជាដើម នោះប្រជាពលរដ្ឋនឹងទៅរស់នៅទីនោះច្រើនទុកជារបងការពារព្រំដែន កុំឱ្យប្រទេសជិតខាងរំកិលព្រំដែន។ ក្រៅពីនេះ ត្រូវមានសន្ធិសញ្ញារវាងប្រទេសដែលនៅជាប់ព្រំប្រទល់គ្នា ដោយទទួលស្គាល់ព្រំដែនរៀងខ្លួន។ ត្រូវបោះបង្គោលព្រំដែនឱ្យបានត្រឹមត្រូវ ដោយមានការទទួលស្គាល់ពីអង្គការសហប្រជាជាតិផង។ បើព្រំប្រទល់ជាប់ដោយដែនសមុទ្រ គេយាមល្បាតដោយកប៉ាល់ឬកាណូត រហូតយាមល្បាតដោយយន្តហោះម្តងម្កាលផង ប្រសិនបើព្រំប្រទល់តែងមានបញ្ហានឹងគ្នា។

គាថានោះបន្តទៀតថា បុគ្គលដែលមានខណៈកន្លងទៅហើយតែងមានការសោយសោកនោះ បានសេចក្តីថា ពេលកន្លងទៅពុំបានបំពេញកិច្ចការដែលជាប្រយោជន៏ខ្លួន និងប្រយោជន៏សង្គមរបស់ខ្លួនដោយការធ្វេសប្រហែស។

ព្រះសម្ពុទ្ធជាម្ចាស់សំដែងថា ពេលកន្លងទៅអាយុជីវិតរបស់សត្វក៏ប្រព្រឹត្តទៅមុខដែរ គឺទៅកាន់ការ **ចាស់ ជរា** និង **ស្លាប់**។ ដូច្នេះ បើបានបំពេញកិច្ចការល្អជាប្រយោជន៏ហើយ បើពេលកន្លងទៅក៏មិនស្តាយក្រោយព្រោះបានបំពេញកិច្ចជាប្រយោជន៏ហើយ។ ព្រះពុទ្ធសាសនាមិនឱ្យមនុស្សដេកចាំសំណាងឡើយ កើតមកត្រូវតែបំពេញការងារប្រកបដោយធមិសុចរិត។ បើទុកជាដឹងថា មានសំណាងបានកសាងល្អពីជាតិមុនក៏ដោយ ក៏ត្រូវតែព្យាយាមប្រឹងធ្វើការងារក្នុងបច្ចុប្បន្ននេះទៀត ទើបសំណាងនោះចេញឱ្យផលបាន។ មនុស្សម្នាក់ៗត្រូវសាងខ្លួនឱ្យមានវិជ្ជាសម្បត្តិចរិយាសម្បត្តិនិងគុណធមិមានមេត្តាជាដើម ដោយការសិក្សារៀនសូត្រនិងការអប់រំចិត្ត។ ចំពោះអាជ្ញាធរខ្មែរ ដែលជា**បុគ្គលសាធារណៈ** ត្រូវធ្វើកិច្ចការងារឱ្យបានត្រឹមត្រូវតាមមុខ-ងារដែលរដ្ឋប្រគល់ឱ្យ ដើម្បីធ្វើឱ្យប្រទេសកម្ពុជាមានការចំរើនលូតលាស់បំបាត់អំពើហិង្សាបំបាត់ភាពក្រីក្រជាដើម។ ប្រទេសកម្ពុជាបានខាតពេលអស់ជាង៣០ឆ្នាំព្រោះមានវិបត្តិនយោបាយ ការទាស់ទែងខ្វែងគំនិតគ្នា បានធ្វើឱ្យប្រទេសកម្ពុជាវិនាសអន្តរាយគ្រប់វិស័យទាំងទ្រព្យសម្បត្តិជាតិទាំងធនធានមនុស្ស។ តទៅមុខទៀត ជនជាតិកម្ពុជាគ្រប់រូប ត្រូវទុកអតីតកាលជាមេរៀនកុំដើរតាមគន្លងចាស់នេះ ហើយធ្វើកិច្ចការឱ្យបានល្អ ស្របតាមពុទ្ធភាសិតខាង

ដើមថា កុំឱ្យវេលាកន្លងទៅដោយពុំបានបំពេញការងារជាប្រយោជន៍ខ្លួន និង ប្រយោជន៍របស់សង្គមខ្លួនឡើយ ។

# ព្រហ្មវិហារធម៌៤

**ព្រហ្មវិហារធម៌** ប្រែថា ធម៌ជាទីនៅដ៏ប្រសើរ បានដល់គុណធម៌នៃចិត្ត របស់មនុស្ស ដែលមានចំពោះមនុស្សសត្វទូទៅ។ **ព្រហ្មវិហារធម៌** មានពីរប្រការគឺ ព្រហ្មវិហារធម៌របស់មាតាបិតា ដែលរាប់អានស្រឡាញ់អាណិតសង្គ្រោះចំពោះបុត្រធីតាប្រុសស្រី។ ព្រហ្មវិហារធម៌មួយទៀតគឺ **អប្បមញ្ញា ព្រហ្មវិហារ** ប្រែថា ព្រហ្មវិហារកំណត់ចំនួនមិនបាន បានដល់ការផ្សាយ **មេត្តា ករុណា មុទិតា** និង **ឧបេក្ខា** ដល់សព្វសត្វទូទៅកំណត់ចំនួនមិនបាន គឺជាព្រហ្មវិហារនៃលោកអ្នកដែលមានចិត្តទូលាយ ជាពិសេសផ្នែកលោកអ្នកចំរើនឈានចិត្តដែលយក **មេត្តា ករុណា មុទិតា ឧបេក្ខា** ជាអារម្មណ៍ ដែលមានលក្ខណៈផ្សេងគ្នា ពីព្រហ្មវិហារធម៌របស់មាតាបិតាដែលមានចំពោះតែកូនរបស់គាត់តែប៉ុណ្ណោះ។

ព្រហ្មវិហារធម៌របស់មាតាបិតាចំពោះបុត្រធីតាគឺមេត្តាមានចិត្តរាប់អានកូនតាំងពីកូនមកចាប់បដិសន្ធិក្នុងផ្ទៃរបស់ខ្លួនម្ល៉េះ គឺចង់ឃើញកូនមានរាងរៅបែបណា លុះកើតមកហើយ ក៏មានចិត្តរីករាយចាប់បំបៅដោះបម្រើកូនដូចបាវបម្រើ។ **ករុណា** ប្រែថា អាណិតអាសូរ គឺពេលកូនមានទុក្ខដូចជាកូនមានជំងឺក៏មានចិត្តអាណិតអាសូរកូនយកកូនទៅមន្ទីរពេទ្យដើម្បីព្យាបាលជាដើម។ **មុទិតា** ប្រែថា មានចិត្តរីករាយ គឺពេលដែលកូនបានសេចក្តីសុខពុំមានជំម្ងឺ

មានសុខភាពល្អជាដើម មាតាបិតាក៏មានចិត្តសប្បាយរីករាយ។ **ឧបេក្ខា** ប្រែថា ចិត្តស្ថិតនៅជាកណ្តាល មិនបារម្ភខ្វល់ខ្វាយដូចមុន។

**ព្រហ្មវិហារធម៌** ដែលមានចិត្តទូលំទូលាយ ផ្សាយទៅចំពោះសព្វសត្វទាំងអស់។ **មេត្តា** ប្រែថា ការរាប់អាន គឺរាប់អានចំពោះមនុស្សសត្វទូទៅមិនរើសមុខ។ មេត្តានេះមានមនុស្សសត្វជាអារម្មណ៍។ លើសពីនេះទៅទៀត មេត្តានេះពុំមែនរាប់អានតែមនុស្សជាតិប៉ុណ្ណោះទេ គឺស្រឡាញ់រាប់អានរហូតដល់សត្វតិរច្ឆានផងទៀត។ ការបណ្តុះចិត្តឱ្យមានមេត្តាគឺដើម្បីដោះចិត្តចេញពីមានះការប្រកាន់ជាតិត្រកូលទ្រព្យសម្បត្តិយសស័ក្តិជាដើម។ **ករុណា** ប្រែថា ការអាណិតអាសូរ គឺមានចិត្តអាណិតអាសូរចំពោះមនុស្សសត្វដែលមានទុក្ខដូចជាមានជំងឺតម្កាត់បៀតបៀនក្រខ្សត់អត់ឃ្លានមានទុក្ខវេទនាដោយហេតុអ្វីមួយ ក៏កើតមានចិត្តអាណិតអាសូរហើយទៅជួយសង្គ្រោះ។ **ករុណា** មានសេចក្តីទុក្ខរបស់មនុស្សសត្វជាអារម្មណ៍។ ការបង្កើតចិត្តឱ្យមានករុណា គឺដើម្បីកំចាត់បង់នូវការព្យាបាទការបៀតបៀនអ្នកដទៃ។ ការកើតចិត្តអាណិតអាសូរបែបនេះ ដោយពិចារណាថា មនុស្សសត្វទាំងអស់តែងមានទុក្ខ ម្តងគេមានទុក្ខម្តងយើងមានទុក្ខ ដូច្នេះមិនត្រូវបៀតបៀនគ្នាទេត្រូវតែជួយសង្គ្រោះគ្នាវិញ។ **មុទិតា** ប្រែថា ត្រេកអរ គឺមានចិត្តត្រេកអរចំពោះសេចក្តីសុខអ្នកដទៃ។ បានសេចក្តីថា បើអ្នកដទៃមានសុខភាពល្អហើយមានទ្រព្យសម្បត្តិល្មមនឹងចិញ្ចឹមជីវិតបានហើយ មានសិទ្ធិសេរីភាពហើយ ក៏ជួយអនុមោទនាត្រេកអរ។ **មុទិតា** នេះមានទ្រព្យសម្បត្តិនិងសេចក្តីសុខរបស់អ្នកដទៃជាអារម្មណ៍។

គោលបំណងនៃការផ្សាយមុទិតាចិត្ត គឺជៀសវាងការច្រណែនគ្នា។ បើគេមានបានដោយរកស៊ីត្រឹមត្រូវក្នុងក្របខណ្ឌនៃច្បាប់រដ្ឋ រៀនសូត្រចេះដឹងច្រើន អ្នកដទៃត្រូវជួយត្រេកអរ។ ចំណែកអ្នកមានបានអ្នកមានចំណេះខ្ពស់ គួរជួយអ្នកក្រខ្សត់អត់ឃ្លានអ្នកមានចំណេះទន់ខ្សោយជាងខ្លួន។ **ឧបេក្ខា** ប្រែថា ចិត្តនៅកណ្ដាល ព្រោះសេចក្ដីទុក្ខខ្លះដូចជាមនុស្សស្លាប់គេពុំអាចឱ្យរស់ឡើងវិញបានឡើយ។ បើប្រើករុណាចិត្តអាណិតអាសូរចំពោះជនជាទីស្រឡាញ់ដែលស្លាប់បាត់បង់ជីវិតទៅហើយនោះ គេរមែងកើតទុក្ខខ្លាំងណាស់។ ខ្លះកើតទុក្ខខ្លាំងរហូតធ្វើអត្តឃាតខ្លួនឯងក៏មាន។ ដូច្នេះ **ឧបេក្ខា** នេះត្រូវពិចារណាកម្មផលរបស់មនុស្សសត្វ មានកម្មផលរបស់មនុស្សសត្វជាអារម្មណ៍ ប្រើចិត្តឧបេក្ខាដើម្បីកុំឱ្យខូចផ្លូវចិត្ត។

ដូចបានពោលមកហើយ បើមនុស្សនិងសង្គមមនុស្សប្រតិបត្តិតាមព្រហ្ម-វិហារធម៌ទាំង៤ប្រការនេះ ពិតជាធ្វើឱ្យពិភពលោកជាពិសេសសង្គមខ្មែរបានសុខសន្តិភាព ព្រោះព្រហ្មវិហារនេះជាទឹកបន្សារ សម្រាប់ផ្សារភ្ជាប់រវាងមនុស្សនិងមនុស្ស សង្គមមនុស្សនិងសង្គមមនុស្សឱ្យរត់រកគ្នានិងរស់នៅជាមួយគ្នាប្រកបដោយសេចក្ដីសុខសាន្តហើយសង្គ្រាមគ្រប់ប្រភេទរមែងពុំកើតមានឡើយ។

# បាប និង បុណ្យ

ពាក្យថា **បាប** ប្រើជាភាសាខ្មែរដែលចេញពីភាសាបាលីថា **បាបំ** ប្រែថា អំពើអាក្រក់។ ឯពាក្យថា **បុណ្យ** ក៏ប្រើជាភាសាខ្មែរ ដែលមានដើមកំណើតពីភាសាសំស្ក្រឹតស្មើនឹងពាក្យថា **បុញ្ញំ** ប្រែថា ការជ្រះថ្លារីករាយចិត្តឬពេញចិត្តជាផ្នែកកុសល។

បុណ្យបាបនេះជាចេតនាអាក្រក់ល្អផ្លូវចិត្ត ទើបបញ្ចេញឱ្យប្រព្រឹត្តអាក្រក់ល្អតាមផ្លូវកាយនិងវាចា។ ការជម្រះសន្ដានចិត្តឱ្យបានស្អាតបានល្អហៅថា **បុណ្យ**។ ចិត្តសៅហ្មង ហៅថា **បាប**។ ចិត្តសៅហ្មងនាំឱ្យប្រព្រឹត្តអាក្រក់ចិត្តបរិសុទ្ធនាំឱ្យប្រព្រឹត្តល្អ។ **បាប** ឱ្យផលជាទុក្ខ **បុណ្យ** ឱ្យផលជាសុខ។ នេះជាអត្ថន័យខ្លះនៃពាក្យថា **បាប** និងពាក្យថា **បុណ្យ**។ ពាក្យថា **បាប** មានពាក្យប្រើផ្លាស់ប្ដូរគ្នាបានគឺ **អកុសល ទុច្ចរិត អយុត្តិធម៌ ធម៌ខ្មៅ** (**កាឡ-ធម៌**)។ ឯពាក្យថា **បុណ្យ** ក៏មានប្រើផ្លាស់ប្ដូរគ្នាបានគឺ **កុសល សុចរិត យុត្តិធម៌ ធម៌ស** (**សុក្កធម៌**)។ **បាប** និង **បុណ្យ** នេះកើតចេញមកពីកាយវាចាចិត្តប្រចាំថ្ងៃរបស់មនុស្សក្នុងសង្គមបានដល់កុសលកម្មបថ១០ គឺ **កាយកម្ម៣** គឺវៀរចាកការសម្លាប់ ការលួច ការប្រព្រឹត្តខុសក្នុងកាម គឺវៀរចាកការលួចប្រពន្ធកូនប្ដីអ្នកដទៃ។ **វចីកម្ម៤** គឺវៀរចាកនិយាយកុហក និយាយពាក្យញុះញង់ ពាក្យគំរោះគំរើយនិងពាក្យឥតប្រយោជន៍។ **មនោ-កម្ម៣** គឺវៀរចាកគំនិតព្យាបាទគំនិតរំពៃចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ

និងមាន **សម្មាទិដ្ឋិ** ការយល់ត្រូវទៅតាមសភាពពិត។ ឯអកុសលកម្មបថ១០ មានលក្ខណៈផ្ទុយពីនេះ គឺពុំវៀរចាកអំពើអាក្រក់ដោយកាយ៣ដោយវាចា៤ ដោយចិត្ត៣នេះឯង។ សកម្មភាពរបស់មនុស្សតែងតែប្រព្រឹត្តទៅតាមដំណើរ កុសលកម្មបថ១០ និងអកុសលកម្មបថ១០នេះ ទើបឱ្យឈ្មោះថា **បុណ្យ** និង **បាប**។

អំពីបុណ្យបាបនេះបើនិយាយដោយបរិយាយសេចក្ដីដូចជាសិស្សនិងនិស្សិត ខំសិក្សារៀនសូត្រ គោរពច្បាប់សាលាមានចរិយាល្អ នេះជាបុណ្យព្រោះសកម្មភាពល្អនេះ នាំឱ្យចំរើនលូតលាស់ខាងការសិក្សា។ ផ្ទុយទៅវិញ បើសិស្សនិស្សិតពុំយកចិត្តទុកដាក់ក្នុងការសិក្សា ពុំគោរពច្បាប់សាលា មានទៅរៀនយឺតពេល ពុំធ្វើកិច្ចការតាមមេរៀនដែលគ្រូដាក់ឱ្យ ដើរលេងប្រព្រឹត្តអបាយមុខផ្សេង៧ជាដើមនេះជា **បាប** ព្រោះសកម្មភាពនេះ នាំឱ្យខូចការសិក្សា។ ម្ដាយឪពុកកូនចៅប្ដីប្រពន្ធបើចេះគោរពគ្នា តាមមុខងារតាមតួនាទីរៀងខ្លួន មិនរំលោភលើគ្នា នេះជាបុណ្យដែលជាហេតុនាំឱ្យបានសេចក្ដីសុខចំរើនក្នុងសង្គមគ្រួសារ។ បើមានការរំលោភលើគ្នា ឈ្មោះថា **បាប** ដែលជាហេតុនាំឱ្យមានការទាស់ទែងខ្វែងគំនិតគ្នាក្នុងសង្គមគ្រួសារពុំបានសេចក្ដីសុខឡើយ។ ក្រុមហ៊ុនរោងចក្រនានា បើពុំគោរពច្បាប់មិនគោរពសិទ្ធិកម្មករ កេងប្រវ័ញ្ចនឹងលើកម្លាំងកម្មករជាដើម នេះជាអំពើបាប។ អំពើនេះ អាចមានកូដកម្មបាតុកម្មរបស់កម្មករប្រឆាំងនឹងការរំលោភនេះ បើដំណោះស្រាយដោយសន្តិវិធីពុំបានទទួលលទ្ធផលល្អតាមបំណងរបស់កម្មករទេ។ សង្គមប្រទេសទាំងមូល បើរដ្ឋា

ភិបាលសភាជាតិតុលាការនិងអាជ្ញាធរគ្រប់ក្រសួងបានបំពេញកិច្ចក្នុងក្រសួងតាមមុខងាររបស់ខ្លួនឱ្យបានត្រឹមត្រូវ ក្នុងក្របខណ្ឌច្បាប់របស់រដ្ឋដើម្បីបម្រើប្រជាពលរដ្ឋ នេះហើយជាអំពើល្អដែលហៅថា **បុណ្យ**។ បើប្រព្រឹត្តផ្ទុយពីនេះឈ្មោះថាអំពើ **បាប** ព្រោះបានធ្វើអំពើអាក្រក់នាំឱ្យខូចប្រយោជន៍ក្រសួងនិងប្រយោជន៍ជាតិទាំងមូល។ បើអ្នកកាន់អំណាចជួយប្រទេសកម្ពុជាឱ្យចំរើនលូតលាស់ ខាងសេដ្ឋកិច្ចខាងវប្បធម៌ជួយឱ្យមានការគោរពសិទ្ធិមនុស្ស នេះជា **បុណ្យ**។ ផ្ទុយទៅវិញ បើអ្នកកាន់អំណាចគិតតែពីប្រយោជន៍ខ្លួន បក្សពួកខ្លួនប្រព្រឹត្តអំពើពុករលួយ ធ្វើឱ្យប្រជាពលរដ្ឋរងទុក្ខវេទនាក្រីក្រលំបាកព្រមទាំងប្រព្រឹត្តអំពើផ្តាច់ការ បំបិទសិទ្ធិគ្រប់យ៉ាងរបស់ប្រជាពលរដ្ឋ នេះជាអំពើ **បាប** ហើយផលបាបនឹងផ្តល់ឱ្យអ្នកប្រព្រឹត្តវិញពុំខានឡើយ។

# ព្រហ្មលិខិត

ពាក្យថា **ព្រហ្មលិខិត** មានដើមកំណើតពីភាសាបាលីដែលចែកជាពីរបទ **ព្រហ្ម** និង **លិខិត** ។ ពាក្យថា **ព្រហ្ម** ជាឈ្មោះអាទិទេពមួយអង្គក្នុងសាសនាព្រាហ្មណ៍ គឺ**ព្រះព្រហ្ម**។ ពាក្យថា **លិខិត** ប្រែថាការចារឬការសរសេររបស់ព្រះព្រហ្ម។ រួមពាក្យទាំងពីរ **ព្រហ្មលិខិត** ប្រែថាការចារឬការសរសេររបស់ព្រះព្រហ្ម។ គេយល់ថា សេចក្តីសុខទុក្ខចំរើនវិនាសរបស់មនុស្សកើតចេញមកពីព្រះព្រហ្មបណ្តាលឱ្យកើតឡើង។ ទស្សនៈនេះ ស្រដៀងគ្នានឹងទស្សនៈរបស់ហោរាសាស្ត្រដែលហៅថា **ព្រហ្មជាតិ** ដែលទស្សន៍ទាយថា ជោគជតារាសីរបស់មនុស្សកើតមកអំពីព្រហ្មលិខិតឱ្យផលបែបណាតាមតែថ្ងៃខែឆ្នាំកំណើតរបស់ខ្លួន។ បើអ្នកទាយនោះជាអ្នកកាន់ព្រះពុទ្ធសាសនា ក៏ទាញមករកព្រះពុទ្ធសាសនាបណ្តាលមកពីកម្មផល។ មនុស្សបានអាយុប៉ុន្មានស្លាប់ទៅវិញក៏ដោយសារព្រះព្រហ្មលោកដាក់កម្រិតមក។ អ្នកនេះនិងនាងនេះជាគូនឹងគ្នាក៏ដោយសារព្រះព្រហ្មលោកតម្រូវឱ្យ។ បានសេចក្តីថា ព្រះព្រហ្មលោកជាអ្នកគូសវាសនាល្អអាក្រក់ឱ្យមនុស្ស។ តាមន័យនេះហើយបានជាមានបទចម្រៀងខ្មែរខ្លះ ច្រើនបន្ទោសទៅលើព្រះព្រហ្មថាពុំគួរកម្រិតខ្លួនឱ្យមានទុក្ខដូច្នេះសោះ។

ព្រះពុទ្ធសាសនាវិញ ព្រហ្មលិខិតបានដល់កម្មផលរបស់ខ្លួនវិញទេ។ សេចក្តីសុខទុក្ខ ចំរើនវិនាស បណ្តាលមកពីកម្មផលរបស់ខ្លួន **កម្មស្សកោម្ហិ**។

បើមានទុក្ខគប្បីបន្ទោសនូវអំពើអាក្រក់ដែលខ្លួនបានប្រព្រឹត្តវិញ។ បើខ្លាចសេចក្ដីទុក្ខគួរជៀសវាងអំពើអាក្រក់កុំធ្វើតទៅទៀត។ មុននឹងបន្ទោសកម្មពីអតីត គប្បីពិនិត្យមើលសកម្មភាពល្អអាក្រក់របស់ខ្លួនក្នុងបច្ចុប្បន្ន ព្រោះជួនកាលផលអាក្រក់ដែលខ្លួនបានទទួលពេលនេះ កើតមកអំពីអាក្រក់របស់ខ្លួនក្នុងបច្ចុប្បន្ននេះឯង។ ពុទ្ធសាសនាសំដែងថា បើមានសេចក្ដីទុក្ខណាមួយកើតឡើង ត្រូវដោះស្រាយមូលហេតុដែលនាំឱ្យកើតសេចក្ដីទុក្ខនោះ សេចក្ដីទុក្ខក៏ត្រូវរលត់។ ប៉ុន្តែមានសេចក្ដីទុក្ខខ្លះពុំអាចដោះស្រាយបាន ត្រូវតែលះបង់បើពុំដូច្នោះទេ នឹងខូចផ្លូវចិត្តដូចជាសមាជិកគ្រួសារណាម្នាក់បានស្លាប់ដែលពុំអាចរស់ឡើងវិញបាន។

ពុទ្ធសាសនិកជនខ្មែរគោរពព្រះពុទ្ធសាសនា ដូច្នេះការសរសេរ ការនិយាយស្ដី ត្រូវពោលឱ្យត្រឹមត្រូវតាមខ្លឹមសាររបស់ព្រះពុទ្ធសាសនា គឺព្រះពុទ្ធសាសនាពោលថា ហេតុ(ឬកម្ម)យ៉ាងណាផលយ៉ាងនោះ ពុំមែនព្រះព្រហ្មលិខិតឡើយ។ គេតែងឮបទចម្រៀងនិងអ្នកនិយាយក្នុងរឿងល្ខោនខ្មែរថា អ្វីទាំងអស់កើតពីព្រះព្រហ្មលិខិត គឺពុំអាចជៀសព្រហ្មលិខិតបានឡើយ។ ត្រង់នេះធ្វើឱ្យអ្នកស្ដាប់ដែលជាពុទ្ធសាសនិកជនស្ដាប់ទៅទាស់ត្រចៀក ព្រោះពុទ្ធសាសនានិយាយពី **កម្មលិខិត** គឺកម្មរបស់ខ្លួនដាក់កម្រិតឱ្យខ្លួនតាមអំពើរបស់ខ្លួនវិញទេ។ ជោគវាសនាល្អអាក្រក់យ៉ាងណាគឺបណ្ដាលមកពី **កម្មទាយាទោ** គឺកម្មជាមតិករបស់ខ្លួនពីអតីតនិងបច្ចុប្បន្ន ពុំមែនកើតពីព្រះជាម្ចាស់អង្គណាមួយឡើយ។ ដូច្នេះអ្នកនិពន្ធខ្មែរសរសេរ ឬនិយាយរឿងល្ខោនក្ដី អ្នកតែងបទ

ចម្រៀងក្តី ត្រូវប្រើពាក្យកម្មលិខិតជាន័យព្រះពុទ្ធសាសនា មិនត្រូវប្រើពាក្យ **ព្រហ្មលិខិត** ដែលជាព្រហ្មញ្ញសាសនាឡើយ ។

# និស្ស័យ និង ឧបនិស្ស័យ

ពាក្យថា **និស្ស័យ** និង **ឧបនិស្ស័យ** ទាំងពីរនេះមានលក្ខណៈខុសគ្នា។ ពាក្យថា **និស្ស័យ** ប្រែតាមពាក្យធម្មតាថា ពឹងផ្អែក ឬពឹងអាស្រ័យដូចជាកុលបុត្រ ដែលបានបួសហើយភ្លាម ព្រះឧបជ្ឈាយ៍ឱ្យនិស្ស័យ៤គឺ អ្នកបួសត្រូវប្រើសំពត់បង្សុកូលដើរបិណ្ឌបាតនៅក្រោមម្លប់ឈើប្រើថ្នាំកែរោគ។ អ្នកបួសត្រូវតែអាស្រ័យបច្ច័យ៤នេះ ទើបរស់នៅបាន នេះជាពុទ្ធានុញ្ញាតខាងដើម។ ចំណែកនៅក្នុងគម្ពីរអភិធម្មនិយាយថា **និស្សយបច្ចយោ** ធមិជានិស្ស័យជាបច្ច័យដល់គ្នានឹងគ្នា ដូចជារូបអាស្រ័យនាម។អាស្រ័យរូបជាដើម។ រូបសំដៅយករូបរាងកាយរបស់មនុស្សសត្វ ឯនាមសំដៅយក **វេទនា សញ្ញា សង្ខារ** និង **វិញ្ញាណ**។ ពាក្យធម្មតាថាអ្នកនេះមាននិស្ស័យនឹងអ្នកនោះ បានសេចក្តីថា មាននិស្ស័យចិត្តថ្លើមស្រដៀងគ្នាឬដូចគ្នាអាចនិយាយគ្នាបាន និងអាចពឹងពាក់គ្នាបាន។ ពាក្យថា**ឧបនិស្ស័យ** បានដល់អំពើល្អឬកុសលណាមួយដែលមានក្នុងចិត្តនៃមនុស្សសត្វជាប់តាំងពីអតីតកាលមក។ កុសលធមិដែលជាឧបនិស្ស័យ បើនិយាយជាគោលមាន៣យ៉ាងគឺ **ទានូបនិស្ស័យ** ប្រែថា ឧបនិស្ស័យដោយការឱ្យទាន **សីលូបនិស្ស័យ** ប្រែថា ឧបនិស្ស័យដោយការរក្សាសីល **ភាវនូបនិស្ស័យ** ប្រែថា ឧបនិស្ស័យ ឬកុសលធមិដោយការភាវនា គឺការអប់រំចិត្តដោយសមថៈនិងវិបស្សនាភាវនា។ ការឱ្យវត្ថុផ្សេងៗ ឬប្រាប់មធ្យោបាយល្អ មធ្យោបាយនាំទៅរកសេចក្តីសុខចំរើន ដែលហៅថា

ធម្មទានដល់អ្នកដទៃហៅថា **ទានូបនិស្ស័យ**។ ការវៀរចាកអំពើអាក្រក់ដោយផ្លូវកាយនិងវាចាដោយការរក្សាសីល មានសីល៥ សីល៨ជាដើម ហៅថា **សីលូបនិស្ស័យ** គឺវៀរចាកបានពេលណាឈ្មោះថាសីលូបនិស្ស័យពេលនោះ។ ការអប់រំចិត្តរហូតកើតសមាធិចិត្តនិងឃើញច្បាស់នូវសង្ខារគឺខន្ធប្រាំជា **អនិច្ចំ ទុក្ខំ** និង**អនត្តា** ដោយផ្លូវវិបស្សនា ឈ្មោះថាភាវនូបនិស្ស័យ។ **ឧបនិស្ស័យ**នោះពុំមែននិយាយតែក្នុងអតីតទេ គឺនិយាយការកសាងក្នុងកាលទាំងបីឱ្យតែបង្កើតមានទានសីលនិងភាវនាពេលណា ឈ្មោះថាមានឧបនិស្ស័យពេលនោះហើយ។ ព្រះនាមព្រះពុទ្ធមួយបទថា **បុរិសទម្មសារថិ** ដែលប្រែថា ព្រះពុទ្ធជានាយសារថីទូន្មាននូវសត្វដែលគួរទូន្មានបាននោះមានសេចក្ដីថា សត្វដែលបានធ្វើទានរក្សាសីលចំរើនភាវនាពីមុនមក ទើបព្រះអង្គទូន្មានបាន គឺសត្វមាន **ទានូបនិស្ស័យ សីលូបនិស្ស័យ** និង **ភាវនូបនិស្ស័យ** នេះឯង។ សត្វដែលគួរទូន្មានបាននោះ សំដៅយកសត្វដែលព្រះអង្គទេសនាពន្យល់ធម៌ណាមួយ ហើយយកចិត្តទុកដាក់ស្ដាប់ ហើយយកពាក្យនោះទៅពិចារណាឱ្យយល់សេចក្ដីពិត ហើយប្រតិបត្តិតាម ព្រោះសត្វនោះធ្លាប់ប្រព្រឹត្តល្អតាំងពីដើមមក។ ផ្ទុយទៅវិញ បើសត្វនោះកំពុងលង់នឹងមិច្ឆាទិដ្ឋិការយល់ខុស ហើយប្រព្រឹត្តតាមការយល់ខុសរបស់ខ្លួន ព្រះអង្គអាចទៅប្រោសឱ្យយល់ត្រូវជាសម្មាទិដ្ឋិវិញបាន ប៉ុន្តែបើសត្វនោះលង់ក្នុងមិច្ឆាទិដ្ឋិដ៏ជ្រៅថ្នាក់និយតមិច្ឆាទិដ្ឋិហើយ ព្រះអង្គពុំអាចកែឱ្យយល់ត្រូវវិញបានឡើយ។

# ផលនៃការប្រទូស្សរ៉ាយ

ប្រធានបទខាងលើនេះ ជាពុទ្ធភាសិតនៅក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសាសនា ដែលជាគាថាថា **យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ សុទ្ធស្ស បោសស្ស អនង្គណស្ស តមេវ ពាលំ បច្ចេតិ បាបំ សុខុមោ រជោ បដិវាតំ ច ខិត្តោ** ប្រែថា បុគ្គលណាប្រទូស្សរ៉ាយបៀតបៀនដល់អ្នកមិនប្រទូស្សរ៉ាយជាបុគ្គលបរិសុទ្ធមិនមានកិលេសគ្រឿងកង្វល់បាបរមែងត្រឡប់មករកបុគ្គលនោះវិញ ដូចជាផង់ធូលីដ៏ល្អិតដែលគេបាចច្រាស់ខ្យល់ រមែងរសាត់មករកអ្នកបាចវិញយ៉ាងនេះឯង។ គាថានេះព្រះបរមសាស្តាសំដែងប្រារព្ធ ចំពោះព្រានសុនខម្នាក់ឈ្មោះ **កោកៈ**។ រឿងដោយសង្ខេបថា ថ្ងៃមួយមានព្រានម្នាក់ឈ្មោះ **កោកៈ** បានបណ្តើរហ្វូងឆ្កែទៅដេញចាប់សត្វក្នុងព្រៃ គាប់ជួនថ្ងៃនោះរកសត្វពុំបានសោះ ព្រានដើរចុះដើរឡើង ស្រាប់តែជួបព្រះថេរៈមួយអង្គទើបគិតថា អញរកសត្វពុំបានថ្ងៃនេះ ព្រោះតែបានជួបនឹងមនុស្សអាក្រក់កាឡកិណីនេះឯង ក៏កើតកំហឹងពន្យុះឆ្កែឱ្យដេញខាំ ព្រះថេរៈក៏រត់ឡើងដើមឈើគេចពីឆ្កែ ព្រានព្រៃឃើញហើយក៏ស្ទុះទៅចាក់ព្រះបាទលោកដោយលំពែង ទោះបីលោកអង្វរថា ញោមកុំធ្វើដូច្នេះ អាត្មាគ្មានកំហុសអ្វីទេ ព្រានរឹតតែចាក់លើសពីមុនទៀត។ ពេលនោះស្រាប់តែចីវររបស់ព្រះថេរៈរបូតធ្លាក់មកគ្រប់លើខ្លួនព្រានព្រៃ។ បាបកម្មផ្តល់ដល់ជនពាល ហ្វូងឆ្កែឃើញចីវរធ្លាក់គ្របលើម្ចាស់ស្មានខុសថា ព្រះថេរៈធ្លាក់ពីលើដើមឈើ

ហើយ ក៏នាំគ្នាបោលស្ទុះចូលទៅខាំក្រញាំម្ចាស់ខ្លួនឯងស្លាប់ក្នុងពេលនោះទៅ។ ព្រះថេរៈបានចុះពីលើដើមឈើកើតមានសេចក្តីសង្ស័យអំពីសីលរបស់ខ្លួន ដោយព្រាននេះស្លាប់ដោយសារចីវររបស់លោក ទើបចូលទៅក្រាបបង្គំទូលសួរព្រះពុទ្ធជាម្ចាស់ ព្រះអង្គត្រាស់ថាសីលរបស់អ្នកមិនដាច់ទេ ទើបព្រះអង្គត្រាស់នូវគាថាដូចពោលមកហើយ។ ក្នុងគាថានេះមានពាក្យថាអ្នកបរិសុទ្ធ គឺអ្នកពុំធ្វើអំពើបាប អ្នកពុំបៀតបៀនអ្នកដទៃ។ បុគ្គលណាប្រទូស្សរ៉ាយចំពោះបុគ្គលបរិសុទ្ធបែបនេះ បាបរមែងធ្លាក់មកលើបុគ្គលនោះវិញដូចជាព្រានព្រៃឈ្មោះកោកៈដែលត្រូវឆ្កែរបស់ខ្លួនខាំស្លាប់ព្រោះបានបៀតបៀនព្រះថេរៈដែលជាបុគ្គលបរិសុទ្ធជាបុគ្គលឥតទោសយ៉ាងនេះឯង។ ប្រៀបដូចផង់ធូលីដែលគេបាចប្រាសខ្យល់ ផង់ធូលីនោះរមែងវិលត្រឡប់មករកអ្នកបាចវិញ ស្របនិងពាក្យខ្មែរមួយបទពោលថា បាចអង្កាមប្រាសខ្យល់ អង្កាមនោះរមែងត្រឡប់មករកអ្នកបាចវិញ។ ស្របនឹងពុទ្ធភាសិតមួយបទពោលថា បាតដៃបើគ្មានដំបៅទេ ទោះបីបុគ្គលយកថ្នាំពិសមកដាក់ ក៏ថ្នាំពិសនោះមិនអាចចូលជ្រាបក្នុងសាច់ធ្វើឱ្យបុគ្គលឈឺចាប់បានឡើយ។ ពុទ្ធភាសិតដូចពោលមកនេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគួរយកមករំលឹកដល់ខ្មែរណា ដែលបានប្រព្រឹត្តអំពើហិង្សាបៀតបៀនលើខ្មែរស្លូតត្រង់គប្បីឈប់ប្រព្រឹត្តចាប់ពីពេលនេះទៅ ព្រោះអំពើដែលគេប្រព្រឹត្តនោះនឹងផ្តល់សេចក្តីទុក្ខមកខ្លួនវិញពុំខានឡើយ។ ពលរដ្ឋខ្មែរបានឆ្លងកាត់សេចក្តីទុក្ខវេទនាជាយូរមកហើយដោយសារតែអំពើហិង្សាមិនគោរពតាមពាក្យព្រះពុទ្ធនេះ គួរកុំឱ្យកើតមានតទៅទៀត។

ទំនាស់ក្នុងគ្រួសារ ក្នុងសហគមន៍និងក្នុងបញ្ហាជាតិត្រូវតែនាំគ្នាដោះស្រាយដោយសន្តិវិធីឆ្លងតាមការនិយាយគ្នាកុំប្រើកម្លាំងបាយ កម្លាំងអាវុធដូចជនពាលឡើយ។ អ្នកនយោបាយកុំលួចសម្លាប់គ្នាបើពេលនេះគេរកមុខមិនឃើញពេលក្រោយគេមុខតែរកឃើញ។ អ្នកស៊ីឈ្នួលសម្លាប់ក៏ត្រូវតែឈប់ ព្រោះជាមុខរបរអមនុស្សធម៌មិនឹងផ្តល់ទុក្ខឱ្យខ្លួនវិញត្រូវតែងាកទៅរកមុខរបរសុចរិតវិញ។ ក៏ដូចជាចោរលួចចោរប្លន់ជាមុខរបរទុច្ចរិតត្រូវមានទោសទាំងផ្លូវលោកនិងផ្លូវធម៌ ក៏ត្រូវវៀរចាកឱ្យស្រឡះ។ មុខរបរជួញដូរមនុស្សមានជួញដូរស្រីឱ្យធ្វើជាស្រីពេស្យាជាដើម ដែលពិភពលោកផ្តន្ទាទោសនិងព្រះពុទ្ធក៏ហាមបើខ្មែរណាប្រព្រឹត្តគប្បីឈប់ពីថ្ងៃនេះទៅ។ អ្នកមានអំណាចខ្មែរណា ដែលរំលោភយកដីរដ្ឋនិងដីរបស់ប្រជាពលរដ្ឋត្រូវតែមានការខ្មាសអៀនហើយប្រគល់ឱ្យរដ្ឋនិងប្រជាពលរដ្ឋវិញ។ ត្រូវចៀសវាងការច្រណែនឈ្នានិះគ្នារហូតដល់ប្រើអំពើហិង្សា ដូចជាការលួចបាញ់សម្លាប់សិល្បករិនីជាដើម ជាអំពើថោកទាបព្រៃផ្សៃណាស់ដែលពិភពលោកមិនដែលកើតមាន។ តុលាការខ្មែរល្មមខ្មាស **សម្បជញ្ញៈ** របស់ខ្លួនហើយមិនគួរយកចំណេះវិជ្ជារបស់ខ្លួនមកប្រ-ព្រឹត្តទុច្ចរិត គឺកាត់សេចក្តីដោយអយុត្តិធម៌ដោយសារខ្លាចអ្នកមានអំណាចដោយសារបក្សពួកដោយសារដុល្លារឡើយ។ អំពើបាបកម្មដែលអ្នកបានប្រ-ព្រឹត្តមកលើអ្នកស្លូតត្រង់ អ្នកនឹងត្រូវទទួលអំពើបាបកម្មនោះវិញ ដូចពុទ្ធភាសិតដែលបានពោលមកហើយ។

# ពាល និង បណ្ឌិត

បុគ្គលពាល គឺជាបុគ្គលគ្មានដឹងបាបបុណ្យគុណទោសអ្វីឡើយ តែង តែប្រព្រឹត្តអំពើអាក្រក់ដោយកាយវាចាចិត្ត កាត់ប្រយោជន៍ខ្លួននិងប្រយោជន៍ អ្នកដទៃ កាត់ប្រយោជន៍ជាតិនេះនិងប្រយោជន៍ជាតិខាងមុខ ជាពិសេស កាត់ប្រយោជន៍ព្រះនិព្វាន ការរំលត់ទុក្ខ។ ឯបុគ្គលជាបណ្ឌិតឬសប្បុរសមាន លក្ខណៈផ្ទុយពីបុគ្គលពាល គឺបុគ្គលជាបណ្ឌិតតែងតែប្រព្រឹត្តអំពើល្អដោយ កាយវាចាចិត្ត ផ្តល់សេចក្តីសុខដល់ខ្លួនផងដល់អ្នកដទៃផង។ តួយ៉ាងដូចព្រះ សម្ពុទ្ធជាអគ្គបណ្ឌិតព្រះអង្គកសាងខ្លួនព្រះអង្គឱ្យបានត្រាស់ជាព្រះពុទ្ធ បន្ទាប់ មកព្រះអង្គទេសនាប្រោសព្រះញាតិនិងប្រោសមនុស្សសត្វជាទូទៅដែលមាន ឧបនិស្ស័យគួរឱ្យព្រះអង្គប្រោសបាន ។

ពាក្យចាស់បុរាណខ្មែរ ក៏មាននិយាយច្រើនពីលក្ខណៈបុគ្គលពាល និង បុគ្គលបណ្ឌិត ឬសប្បុរសដូចពាក្យខ្លះតទៅនេះ ។ នៅជិតសប្បុរស សុខស្រួល ទាំងអស់ ឥតមានភិតភ័យ នៅជិតជនពាល មានតែទោសពៃរ៍ ទុក្ខព្រួយរាល់ ថ្ងៃ មិនបានក្តីសុខ ។ នៅជិតជនពាល ដូចភ្លើងឆេះរាល ឆេះព្រៃព្រឹក្សា ដូច សត្វមានពិស ក្លាខ្លាំងអស្ចារ្យ បង្កទុក្ខា រាល់ពេលវេលា ។ ជនពាលសាមាន្យ ឃោរឃៅឃ្លានពាន មិនមានមេត្តា ជននោះតែងជួប នឹងទុក្ខទោសា ឈឺចាប់ ខ្លោចផ្សា មិនដែលជៀសបាន។ បាបពុំទាន់ឱ្យផលដល់កាលណា ពាលគិតថា បាបនោះដូចទឹកឃ្មុំ លុះបាបកម្មឱ្យផលដល់ប្រជុំ ទើបពាលរងទុក្ខធំដល់កាល

នោះ។ ព្រៃគ្មានសត្វជិត ប្រទេសគ្មានបណ្ឌិត ទ្វីបឥតសាសនា គ្រឹហាឥតបុត្រ ស្រុកគ្មានជាតិជា មេឃឥតចន្ទ្រា សូន្យចក្រវាឡ។ ត្រង់នេះសំដៅយកទ្វីបលោក បើគ្មានសីលធម៌និងព្រះពុទ្ធសាសនាទេ ទ្វីបលោកនឹងត្រូវវិនាសដោយសារគ្មានធម៌មេត្តាបៀតបៀនកាប់សម្លាប់គ្នា។ កង្កែបនៅក្នុងអណ្ដូងទឹកស្មានមេឃតូចប៉ុនគ្របឆ្នាំង បុគ្គលល្ងិតល្ងង់អវិជ្ជាបាំងតែងតាំងខ្លួនថាប្រសើរឯក។ ជាតិជាអ្នកជា ស្ងាត់ស្ងៀមកិរិយា មិនចេញក្អេងក្អាង ឯសន្ដានពាល ចេញឫកអាងយ៉ាង ភ្លាត់ស្នៀតច្រងាង ព្រោះព្រុសមិនឈប់។ ឈ្មោះនឹងពាលពិបាកបន្តិចហើយ កុំស្មានឡើយថាពាលស្ដាប់សព្វវាចា ទុកជាវែកញែកខុសត្រូវទៅផ្លូវណា ក៏ពាលពោលថាគេមិនស្ដាប់ច្បាប់អ្វីទេ។ **ទោសគេតូចឆ្មារថ្កោលថាជាធំ ទោសឯងប៉ុនភ្នំ មិនយល់ថាទោស**។ ពាក្យបុរាណពោលឱ្យប្រយ័ត្នថា អ្វីដែលជាសត្រូវពីមុនមក ត្រូវលែលកមើលឱ្យជាក់ការរាក់ជ្រៅ កុំប្រហែសធ្វេសជឿចិត្តមនុស្សឃោរឃៅ គំនុំចងជាប់នៅស្ថិតស្ថេរឥតរសាយ។ គុណទាំងឡាយទាំងអស់ ជារបស់មានក្នុងប្រាជ្ញ ឯទោសពាលកំណាច ជាធម្មជាតិមានក្នុងខ្លៅ។ ពស់កាចមានពិសទោះវាខាំ ពេទ្យកែដោយថ្នាំអាចស្ងប់បាន មនុស្សកាចលើសពស់ពិសសាមាន្យ គ្មានអ្វីកែបានស្ងប់ស្ងាត់ឡើយ។ វិស័យពេលថ្ងៃលំអអាទិត្យ ពេលយប់ងងឹតលំអចន្ទ្រា អំពើបាបលំអពួកពាលា កុសលធម្មាលំអសប្បុរស។ ណែនាំជនពាលឱ្យធ្វើល្អ ពាលមិនត្រេកអរប៉ុនចុងសក់ ពាលរឹតបានចិត្តធ្វើអាក្រក់ ភូតភរកុហកថែមខ្លាំងក្លា។ ប៉ុន្តែមានមនុស្សពាលខ្លះ អាចកែខ្លួនធ្វើល្អ បន្ទាប់ពីបានស្ដាប់ពាក្យទូន្មានរបស់ពួកលោកអ្នក

សប្បុរស។ កូនប្រុសស្រីចូរចងចាំ បុរាណបានផ្តាំផ្តាច់ទុកថា ប្រដៅជនពាល ដោយអាជ្ញា ឃុំឃាំងប្រហារទើបវាខ្លាច។ ប៉ុន្តែមានបុគ្គលពាលខ្លះមិនបាច់ប្រើអាជ្ញាគ្រាន់តែណែនាំពន្យល់ប្រាប់ហេតុផលល្អអាក្រក់ ក៏ខ្លាចលែងហ៊ានធ្វើអាក្រក់។ មុននឹងធ្វើទារុណកម្មទៅលើគេ ត្រូវអ្នកផ្ទេរប្តូរមកដាក់រូបអ្នកសិន បើមិនគិតចេះតែសង្កត់សង្កិន ឱ្យគេហីនដោយសារឯងមិនក្រែងខ្លាច។ ត្រង់នេះមានន័យថា មុននឹងធ្វើទារុណកម្មដល់ជនណាម្នាក់ ត្រូវប្រៀបធៀបកំហុសរបស់ខ្លួនទៅនឹងអ្នកនោះសិន។ ដូចបានពោលមកហើយលក្ខណៈរបស់បុគ្គលពាលនិងបុគ្គលជាបណ្ឌិតតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធក្តី តាមពាក្យចាស់បុរាណខ្មែរ ទោះបីពាក្យនេះមិនត្រឹមត្រូវដូចពុទ្ធភាសិតក្តីក៏បានជាមេរៀនថា បុគ្គលត្រូវតែសេពគប់បុគ្គលជាបណ្ឌិតកុំសេពគប់បុគ្គលពាល។ ជាពិសេសទៅទៀត គ្រប់ដំណោះស្រាយជម្លោះក្នុងគ្រួសារក្តី ក្នុងប្រទេសជាតិក្តី ក្នុងសហគមន៍អន្តរជាតិក្តី ត្រូវដោះស្រាយដោយគតិបណ្ឌិត កុំដោះស្រាយតាមគតិពាល។ ដំណោះស្រាយគតិពាល គឺការប្រើហិង្សាកាប់សម្លាប់គ្នាជាមធ្យោបាយយកឈ្នះចាញ់គ្នា ព្រះពុទ្ធសំដែងថា មធ្យោបាយនេះមិនអាចបញ្ចប់ការវិវាទគ្នាឡើយ។ ដំណោះស្រាយតាមគតិបណ្ឌិត គឺដោះស្រាយតាមសន្តិវិធីឈរលើច្បាប់ទម្លាប់របស់ប្រទេសនិងរបស់អង្គការសហប្រជាជាតិ។ យ៉ាងណាមិញ ប្រទេសកម្ពុជាត្រូវតែដើរតាមគតិបណ្ឌិតទើបប្រទេសកម្ពុជាបានសុខសន្តិភាព។

# សតិ និង សម្បជញ្ញៈ

**សតិ** និង **សម្បជញ្ញៈ** ទាំងពីរប្រការមានឧបការៈច្រើនដល់អ្នកអនុវត្តកិច្ចការទាំងផ្លូវលោកទាំងផ្លូវធម៌។ **សតិ** ប្រែថា សេចក្ដីរឭក ។ **សម្បជញ្ញៈ** សេចក្ដីដឹងខ្លួនពេលអនុវត្តកិច្ចការ។ តាមផ្លូវធម៌ សតិគឺ ជាការរលឹកនូវអំពើគ្រប់យ៉ាងដែលបានធ្វើកន្លងទៅ ដែលជាគុណធម៌ជំរុញចិត្តឱ្យប្រព្រឹត្តល្អតទៅទៀត បើអំពើដែលប្រព្រឹត្តកន្លងទៅជាអំពើល្អ ហើយនឹងលះនូវអំពើអាក្រក់មិនធ្វើតទៅទៀត។ សម្បជញ្ញៈ ដឹងខ្លួនពេលកំពុងប្រព្រឹត្ត ការដឹងនេះជាធាតុសំខាន់ណាស់ក្នុងការអប់រំចិត្តឱ្យបានល្អ។ ធម៌ទាំងពីរនេះជាគូនឹងគ្នា ត្រូវបណ្ដុះឱ្យមានទាំងពីរទើបសម្រេចប្រយោជន៍។ ធម៌ទាំងពីរនេះបើអនុវត្តកិច្ចការផ្លូវលោកក្នុងជីវភាពប្រចាំថ្ងៃ មានប្រយោជន៍ណាស់។ សតិ រលឹកកិច្ចការដែលធ្វើកន្លងហើយ តើចំរើនលូតលាស់ឬយ៉ាងណាត្រូវរៀបចំផែនការជាថ្មី បើពុំបានលូតលាស់ទេ គឺទុកអតីតកាលជាមេរៀនសម្រាប់រៀបចំបច្ចុប្បន្ន ដើម្បីអនាគតរុងរឿងទាំងផែនការគ្រួសារទាំងផែនការប្រទេស។ សម្បជញ្ញៈ ការដឹងខ្លួនថា ខ្លួនកំពុងធ្វើអ្វីដោយពិចារណាថា តើការងារនោះមានប្រយោជន៍ឬគ្មានប្រយោជន៍ទេជាការងារទុច្ចរិតឬសុចរិតជាដើម។ បើអ្នកបើករថយន្តវិញ បើគ្មានសម្បជញ្ញៈនិងការភ្លេចស្មារតី រថយន្តអាចគ្រោះថ្នាក់ដោយការបើកបរខុសច្បាប់ មានទៅបុកគេជាដើម។ កង្វះ **សតិ** និង **សម្បជញ្ញៈ** កិច្ចការច្រើនភ្លាត់ខុស ហើយសោកស្ដាយជាក្រោយ។ ដូចរឿងទន្សាយក៏រួចត្រីរស់

ក៏រួច មានដំណាលថាតាចាស់ម្នាក់បានលួកចាប់ត្រី ដែលខ្លួនប្រោះទុកក្នុងទ្រុង ដោយគ្មានការប្រុងប្រយ័ត្ន ត្រីរស់រើខ្លួនធ្លាក់ទៅក្នុងទឹកបាត់ទៅ គាត់រត់ទៅយកអង្រុតដែលគាត់ក្រុងទន្សាយមករុតត្រី ទន្សាយក៏បោលទៅបាត់ទៀត។ នេះមកពីមិនមានសតិសម្បជញ្ញៈថា ទន្សាយនៅក្នុងអង្រុត ឯត្រីក៏ពុំអាចរុតបាន។ ក្នុងសតិបដ្ឋានសូត្របានសំដែងហើយថា **សតិបដ្ឋាន** ប្រែថា ការតម្កល់ស្មារតីពិចារណា**រូប** ពិចារណា**វេទនា**គឺការទទួលអារម្មណ៍ជាសុខជាទុក្ខប្រព្រឹត្តទៅក្នុងកាយនិងចិត្ត ពិចារណា**ចិត្ត** ពិចារណា**ធម្ម**គឺអារម្មណ៍ដែលកើតក្នុងចិត្តថាគ្រាន់តែជាធាតុ ពុំមែនជាសត្វជាបុគ្គលមានសភាពសោះសូន្យទទេ។ គឺការកំណត់ពិចារណានូវភាពប្រាកដឡើងនៃអាការៈទាំងនោះ។ គេពុំអាចពិចារណាជាតួបរមត្ថបែបនេះបានឡើយ លុះត្រាតែព្រះអរិយបុគ្គលមានសោតាបន្នបុគ្គលជាដើមដែលមាន **ញាណទស្សនៈ** ទើបដឹងភាពពិតនេះបាន។

# កម្មចែកសត្វ

ពាក្យថា **កម្ម** ដែលចែកសត្វទាំងឡាយឱ្យថោកទាប និងខ្ពង់ខ្ពស់ចេញពីពុទ្ធភាសិតថា **កម្មំ សត្តេ វិភជតិ ហីនប្បណីតតាយ**។ កម្មក្នុងន័យព្រះពុទ្ធសាសនាសំដៅយកអំពើប្រកបដោយចេតនា ដូចពុទ្ធភាសិតមួយទៀតពោលថា **ចេតនាហំ ភិក្ខវេ កម្មំ វទាមិ** ប្រែថា ម្នាលភិក្ខុទាំងឡាយតថាគតពោលថា ចេតនាជាតួកម្ម។ បើធ្វើតាមផ្លូវកាយហៅថា **កាយកម្ម** តាមផ្លូវវាចាហៅថា **វចីកម្ម** តាមផ្លូវចិត្ត ហៅថា **មនោកម្ម**។ ចេតនាជាតួចេតសិកធម៌ គឺជាសកម្មភាពរបស់ចិត្តដែលប្រព្រឹត្តនៅក្នុងអារម្មណ៍។ មួយទៀត ពាក្យថា **ចេតនា** ជាអំពើប្រកបដោយចិត្តក្លែងហៅថា **សចិត្តកៈ**។ អំពើដែលពុំមានចិត្តនិងចេតសិកប្រកបជាមួយទេ ពុំឈ្មោះថា **កម្ម** ក្នុងព្រះពុទ្ធសាសនាឡើយ។ អំពើនោះមាន២យ៉ាងគឺ អំពើល្អហៅថា **កុសលកម្ម** អំពើអាក្រក់ហៅថា **អកុសលកម្ម**។

អំពើល្អនិងអំពើអាក្រក់នេះ ចេញមកពីសកម្មភាពខ្លួនឯង បាលី ហៅថា **កម្មស្សកោម្ហិ** ប្រែថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន។ ព្រះពុទ្ធត្រាស់ដឹងច្បាប់កម្មផលថា សេចក្តីសុខទុក្ខចំរើនវិនាស កើតចេញមកពីអំពើរបស់ខ្លួន។ បានសេចក្តីថា ជីវិតរបស់ខ្លួនប្រព្រឹត្តទៅយ៉ាងណា ស្រេចទៅលើសកម្មភាពល្អអាក្រក់របស់ខ្លួនជាអ្នកចាត់ចែង។ ពាក្យថា **កម្ម** នេះបើតាមន័យរបស់ភាសាខ្មែរឱ្យន័យថា ការលំបាកឬការរងទុក្ខ។ តាមន័យពិតកម្មនេះជាឈ្មោះ

នៃអំពើ ជាពាក្យកណ្តាលមានទាំងអំពើល្អនិងអាក្រក់។ អំពើល្អឱ្យផលជាសុខ អំពើអាក្រក់ឱ្យផលជាទុក្ខ។ ប៉ុន្តែបើនិយាយឱ្យដល់ជម្រៅព្រះពុទ្ធសាសនា ពាក្យខ្មែរថាកម្មដែលមានន័យថាទុក្ខនេះ ទៅជាត្រូវទៅវិញព្រោះកម្មល្អកម្មអាក្រក់នេះឯង ដែលនាំសត្វឱ្យមានជាតិគឺបដិសន្ធិតទៅទៀត។ ការមានជាតិជាហេតុនាំឱ្យមានទុក្ខ។

ព្រះពុទ្ធបរមគ្រូត្រាស់ថា ទំនាបនិងកំពស់របស់មនុស្សត្រូវស្ថិតនៅលើអំពើរបស់គេដែលហៅថាកម្មនេះឯង ពុំមែនស្ថិតនៅលើក្រមាន មានយសសក្តិឥតយសសក្តិឡើយ។ បានសេចក្តីថា មនុស្សឧត្តមប្រសើរនិងមនុស្សថោកទាបពុំមែនយកជាតិត្រកូល ទ្រព្យសម្បត្តិ យសសក្តិធ្វើជាខ្នាតសម្រាប់វាស់ឡើយ។ ស្ទើរតែគ្រប់ទំព័រនៃគម្ពីរព្រះត្រៃបិដក ដែលជាគម្ពីរដ៏ធំរបស់ព្រះពុទ្ធសាសនា ព្រះអង្គបានយកកម្មផលនេះមកធ្វើជាខ្នាត។ ព្រះសមណគោត្តមជាគ្រូនៃទេវតានិងមនុស្សទាំងឡាយបានពន្យល់ថា បើអ្នកនោះមានជាតិត្រកូលខ្ពស់ មានទ្រព្យសម្បត្តិច្រើន មានអំណាចបុណ្យសក្តិធំតែជាអ្នកប្រព្រឹត្តអំពើអា-ក្រក់ដោយកាយវាចានិងដោយចិត្ត អ្នកនោះចាត់ថាជាមនុស្សថោកទាប។ ផ្ទុយទៅវិញ អ្នកនោះគ្មានវិជ្ជាជ្រៅជ្រះនឹងគេទេ ប៉ុន្តែជាអ្នកប្រព្រឹត្តអំពើល្អ លោកចាត់ទុកថា ជាមនុស្សខ្ពង់ខ្ពស់ថ្លៃថ្នូរ។ បើអ្នកនោះមានវិជ្ជាខ្ពង់ខ្ពស់ ហើយប្រព្រឹត្តល្អទៀត ទើបជាមនុស្សខ្ពង់ខ្ពស់។ ដូច្នេះមនុស្សមានលក្ខណៈខុសគ្នាដោយសារអំពើរបស់គេមានលក្ខណៈខុសគ្នា។ ព្រះពុទ្ធបានចែកមនុស្សជាច្រើនប្រភេទទៅតាមអំពើដែលគេបានប្រព្រឹត្ត។ **មនុស្សេរ្យា**ជាមនុស្សពេញ

លក្ខណៈ គឺជាមនុស្សមានចិត្តធម៌ក្នុងខ្លួនដោយហោចណាស់មានសីល៥។ **មនុស្សបេតោ** មនុស្សដូចជាប្រេត គឺមនុស្សមានទ្រព្យសម្បត្តិតែកំណាញ់ស្វិតស្វាញ។ **មនុស្សតិរច្ឆានោ** មនុស្សដូចសត្វ គឺមនុស្សមិនស្គាល់គុណ។ **មនុស្សនេរយិកោ** មនុស្សដូចសត្វនរក គឺមនុស្សរំលោភសិទ្ធិអ្នកដទៃ ធ្វើបាបកាប់សម្លាប់អ្នកដទៃ។ ដូច្នេះ **កម្មផល** តែងបែងចែកមនុស្សសត្វឱ្យខ្ពង់ខ្ពស់ និងថោកទាបដូចពោលមកនេះឯង។

# ផ្លូវប្រតិបត្តិចេញចាកទុក្ខ

ព្រះពុទ្ធបានប្រកាសនៅពេលដែលព្រះអង្គបានសំដែងធម៌ទេសនាប្រោស ភិក្ខុ៥អង្គថា ផ្លូវអមខាងទាំងពីរ គឺទី១ ឈ្មោះ **កាមសុខល្លិកានុយោគ** ចិត្តត្រេកអរនូវសេចក្ដីសុខក្នុងកាមគុណទាំង៥គឺ រូប សម្លេង ក្លិន រស និង សម្ផស្សជាធម៌របស់អ្នកស្រុកជាធម៌ថោកទាបជាធម៌របស់មនុស្សបុថុជ្ជន ពុំមែនជាធម៌របស់អរិយបុគ្គលដែលនាំឱ្យឃើញអរិយសច្ច៤ទេ មិនប្រកបដោយ ប្រយោជន៍ឡើយ ព្រោះការជាប់ចិត្តយ៉ាងនេះនាំឱ្យខ្សោយបញ្ញាមិនអាច ត្រាស់ដឹងបានឡើយ។ តថាគតធ្លាប់បានជួបផ្លូវនេះរួចហើយកាលនៅក្នុងព្រះ រាជវាំង។ ផ្លូវនេះចាត់ទុកជាផ្លូវអមខាង ជាផ្លូវស្ដាំផុត។ ផ្លូវទី២ ឈ្មោះ **អត្តកិលមថានុយោគ** ព្យាយាមប្រព្រឹត្តធ្វើឱ្យលំបាកកាយដោយវិធីផ្សេងៗ មានខែត្រជាក់ចុះត្រាំទឹក ខែក្ដៅឈរឬអង្គុយហាលថ្ងៃ ឈរតែជើងម្ខាង ដេកលើបន្លា ដកដង្ហើមតិចៗ បន្ថយអាហារ ដើម្បីឱ្យស្ងួតកិលេស ដោយយល់ ខុសថាកិលេសនៅក្នុងកាយ ធម៌នេះធ្វើឱ្យលំបាកកាយ មិនមែនជាធម៌របស់ អរិយបុគ្គលទេ មិនប្រកបដោយប្រយោជន៍ឡើយ។ វិធីប្រតិបត្តិនេះ តថាគត ធ្លាប់បានអនុវត្តហើយ ចាត់ទុកថាជាផ្លូវអមខាងផ្លូវឆ្វេងផុត។

ព្រះសម្ពុទ្ធជាកំពូលនៃលោកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ **មជ្ឈិមា បដិបទា** ជាផ្លូវប្រតិបត្តិកណ្ដាល ព្រោះឃើញទោសនៃផ្លូវអមខាងទាំងពីរ ជាផ្លូវប្រតិ បត្តិដើម្បីកើតបញ្ញាចក្ខុធ្វើឱ្យកើតសេចក្ដីដឹងច្បាស់ប្រាកដ ប្រព្រឹត្តទៅដើម្បី

ស្ងប់រម្ងាប់ ដើម្បីដឹងចំពោះដឹងប្រពៃដើម្បីរំលត់ទុក្ខ។ មគ្គប្រកបដោយអង្គ៨ នេះហៅថា ប្រតិបត្តិជាកណ្ដាលគឺ **សម្មាទិដ្ឋិ** ប្រាជ្ញាយល់ឃើញត្រូវ **សម្មា-សង្កប្បោ** ការត្រិះរិះត្រូវ **សម្មាវាចា** វាចាត្រូវ **សម្មាកម្មន្តោ** ការងារត្រូវ **សម្មាអាជីវោ** ការចិញ្ចឹមជីវិតត្រូវ **សម្មាវាយាមោ** ការព្យាយាមត្រូវ **សម្មាសតិ** ការរលឹកត្រូវ និង **សម្មាសមាធិ** ការតម្កល់ចិត្តនឹងត្រូវ។ បើរួមឱ្យខ្លីមានបីគឺ **សីល សមាធិ បញ្ញា**។ **សម្មាទិដ្ឋិ** និង**សម្មាសង្កប្បោ** ជាតួបញ្ញា **សម្មាវាចា សម្មាកម្មន្តោ** និង**សម្មាអាជីវោ** ជាតួសីល។ **សម្មាវាយាមោ សម្មាសតិ** និង**សម្មាសមាធិ** ជាតួសមាធិ។ អដ្ឋង្គិកមគ្គនេះ លោករៀងបញ្ញានៅខាងដើម ប្លែកពីត្រៃសិក្ខាដែលរៀងបញ្ញានៅខាងចុង គឺសីលសមាធិបញ្ញា មកពីវិធីបច្ចេកទេសរបស់ព្រះពុទ្ធក្នុងការសំដែងធម៌ទេសនាប្រោសភិក្ខុ៥អង្គ។ ព្រះអង្គត្រូវតែសំដែងអំពីបញ្ញាមុនដើម្បីឱ្យភិក្ខុ៥អង្គយល់ថា ព្រះពុទ្ធត្រាស់ដឹងហើយដើម្បីឱ្យភិក្ខុទាំងនោះយកចិត្តទុកដាក់ស្ដាប់ ព្រោះសីលនិងសមាធិភិក្ខុទាំងនោះធ្លាប់អនុវត្តមកហើយ។ អ្នកសិក្សាព្រះពុទ្ធសាសនាគប្បីយល់ថាបញ្ញានេះ ជា**បញ្ញាលោកុត្តរៈ** កើតឡើងបានលុះត្រាតែមានសីលនិងសមាធិប្រកបជាមួយ ហើយពុំមែនជាបញ្ញាកើតពីការស្ដាប់និងការត្រិះរិះពិចារណាជាតួបរិយត្តិធម៌នោះទេ តែជាតួបញ្ញាកើតពីការប្រតិបត្តិវិបស្សនាភាវនាទើបកើតបញ្ញាជា **លោកុត្តរៈ**ជាបដិវេធធម៌ឃើញអរិយសច្ច៤។ ការដើរតាមមគ្គប្រកបដោយអង្គ៨ឃើញអរិយសច្ច៤ គឺសេចក្ដីទុក្ខបានដល់ការកើតឡើងនៃខន្ធ៥គឺ **រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ១** ហេតុ

ដែលនាំឱ្យកើតទុក្ខបានដល់ **តណ្ហា១** ការរលត់ទុក្ខបានដល់ការឈប់មាន ជាតិ១ ផ្លូវទៅកាន់ការរំលត់ទុក្ខបានដល់មគ្គប្រកបដោយអង្គ៨ដូចបានពោលមក ហើយ១ (**ទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច**)។ ការត្រាស់ ដឹងរបស់ព្រះពុទ្ធនេះ មិនត្រឹមតែមនុស្សលោកទេដែលមានការរំភើបសប្បាយ រីករាយ ដំណឹងនេះបានដឹងយ៉ាងឆាប់រហ័សដល់ពួកទេវតាពួកព្រហ្មបានសំដែង ការកោតសរសើរចំពោះព្រះពុទ្ធឈ្នះមារ ដែលបានត្រាស់ដឹងរកឃើញការពិត សម្រាប់រំដោះទុក្ខនៃមនុស្សសត្វ ដែលពីមុនគ្មានអ្នកណារកឃើញហើយ សង្ឃឹមថាខ្លួននឹងបានស្ដាប់ធម៌របស់ព្រះអង្គ ក៏ថ្វាយព្រះពរសព្ទសាធុការតែ រៀងៗខ្លួន។ មគ្គប្រកបដោយអង្គ៨នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ ជាផ្លូវនៃការ ចេញចាកទុក្ខបានដល់អមតមហានិព្វាន។ សមណព្រាហ្មណ៍និងតាបសឥសីមុន សម័យពុទ្ធកាលក៏ដូចជាសម័យពុទ្ធកាល មិនបានឃើញផ្លូវនេះទេ។ ក្រោយពី ព្រះអង្គបានសិក្សា ពិសោធនគ្រប់បែបយ៉ាងនិងដោយបារមីធម៌ដែលព្រះអង្គ បានកសាងជួយជំរុញផង ទើបព្រះអង្គរកផ្លូវត្រាស់ដឹងនេះឃើញហើយដោយ ព្រះអង្គប្រតិបត្តិតាមផ្លូវនេះ(**មគ្គ៨**) ក៏បានត្រាស់ជាព្រះពុទ្ធក្នុងលោក គឺការ ឃើញអរិយសច្ច៤នេះឯង។ សាសនាដទៃស្វែងរកសេចក្ដីសុខតែនៅក្នុងខន្ធ៥ មាន**រូបក្ខន្ធ**ជាដើមក្នុងស្ថានមនុស្សលោកស្ថានទេវតានិងស្ថានព្រហ្ម។ ព្រះពុទ្ធ សំដែងថា ភពទាំងបីនេះស្ថិតនៅក្រោមត្រៃលក្ខណ៍ធម៌គឺ **អនិច្ចំ ទុក្ខំ** និង **អនត្តា** កើតចាស់ឈឺស្លាប់មិនរួចពីសេចក្ដីទុក្ខទេ ជាវដ្តសង្សារវិលកើតវិល ស្លាប់រកទីបំផុតគ្មាន។ ចំណែកព្រះនិព្វានទើបដល់ការរំលត់ទុក្ខពុំស្ថិតនៅ

ក្រោមអំណាចមច្ចុរាជឡើយ ។ យើងបានឃើញរឿងក្នុងសាសនាព្រាហ្មណ៍និកាយព្រះវិស្ណុថា ពួកទេវតានិងពួកអសុរបានកាន់ក្បាលនាគនិងកន្ទុយនាគម្ខាងម្នាក់កូរសមុទ្រទឹកដោះ ដើម្បីរកទឹកអម្រឹតផឹកទៅមិនស្លាប់ ។ នេះជារឿងដំណាលប្រាសចាកការពិតរបស់សាសនាព្រាហ្មណ៍ ព្រោះអ្វី ព្រោះថាគ្មានទឹកណាផឹកទៅមិនស្លាប់នោះឡើយ ។ កាលណាមានជាតិតែងតែបញ្ជូនទៅរកជរាព្យាធិ និងមរណៈពុំខានឡើយ ។ ចំណែក ព្រះនិព្វានទើបមិនស្លាប់ទើបហៅថា **អមតមហានិព្វាន** ។ ក្នុងធម្មិអារាធនាព្រហ្មថា ញ៉ាំងសត្វចូលពុទ្ធចក្រមានបញ្ចវគ្គីយ៍ជាអាទិ ឱ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា ។ ពាក្យថា **អម្រឹត** ជាពាក្យសំស្ក្រឹតប្រែថាមិនស្លាប់ស្មើគ្នានឹងពាក្យបាលីថា **អមតំ** បានជាលោកពោលថា **អមតំ និព្វានំ** ប្រែថា និព្វានមិនស្លាប់ ដោយផឹកទឹកអម្រឹតជាតិគឺប្រតិបត្តិតាមមគ្គ៨ ។

ប្រតិបត្តិតាមមគ្គប្រកបដោយអង្គ៨ ដូចដែលបានពោលមកហើយទើបបានរសមួយ គឺនិព្វានរសជាធម្មិមិនស្លាប់លែងវិលកើតវិលស្លាប់ក្នុងសង្សារវដ្តជាបន្តទៅទៀត ។

# ជ័យជំនះដ៏ប្រសើរ

ពុទ្ធភាសិតថា ជំនះណាដែលត្រឡប់ចាញ់វិញ ជំនះនោះពុំប្រសើរ ឯជំនះណាដែលមិនត្រឡប់ចាញ់វិញ ទើបជាជំនះប្រសើរនោះ ចេញមកពីបាលីថា **ន តំ ជិតំ សាធុ ជិតំ អវជិយ្យតិ តំ ខោ ជិតំ សាធុ ជិតំ យំ ជិតំ នាវជិយ្យតិ** ។

ជំនះណាដែលត្រឡប់ចាញ់វិញ ជាជំនះពុំប្រសើរនោះដូចជាជំនះដោយល្បែងស៊ីសង មានបៀអាប៉ោងកាស៊ីណូជាដើមតែងត្រឡប់ចាញ់វិញ។ ធម្មតាអ្នកលេងល្បែងតែងមានឈ្នះមានចាញ់ ហើយអ្នកលេងល្បែងពុំសូវលេងតែម្តងហើយឈប់ទេ ច្រើនតែញៀនលេងពុំឈប់ចេះតែលេងជាបន្តទៅទៀត ដោយគិតថាក្រែងឈ្នះបានច្រើនជាងនេះ លេងយូរៗទៅក៏ចាញ់អស់ទាំងចុង អស់ទាំងដើម។ អ្នកញៀននឹងការលេងល្បែងជួនកាលលក់របស់របរទៅលេងទៀតនាំឱ្យខ្វែងគំនិតគ្នាក្នុងគ្រួសាររហូតបង្កើតជម្លោះបាក់បែកគ្នាថែមទៀត។ ជួនកាលកើតជាចោរលួចប្លន់ បើអ្នករដ្ឋការវិញកើតការពុករលួយស៊ីសំណូកដើម្បីបានប្រាក់លេងល្បែង។ ជំនះដោយការវាយតប់គ្នាឈ្នះគេពេលនេះពេលក្រោយគេរកមធ្យោបាយយកឈ្នះវិញ គឺជាជំនះប្រកបដោយការចងពៀរគ្នា។ ឯជំនះដោយការធ្វើចម្បាំងក៏ដូចគ្នាដែរតែងមានការចាញ់មានឈ្នះហើយជំនះក៏ពុំបានស្ថិតស្ថេរដែរ បើពុំបានចរចាគ្នាបញ្ឈប់សង្គ្រាមទេ។ ព្រះពុទ្ធសាសនាបានបង្រៀនមនុស្សឱ្យដោះស្រាយបញ្ហាដោយសន្តិវិធី ឆ្លងតាមការនិយាយគ្នា

កុំប្រើហិង្សាដោយយុទ្ធវិធី ព្រោះការធ្វើចម្បាំងតែងខូចខាតទាំងទ្រព្យសម្បត្តិ ទាំងជីវិតមនុស្សហើយរមែងចងពៀរនឹងគ្នាទៀតផង។

ជំនះណាដែលមិនត្រឡប់ចាញ់វិញទើបជាជម្នះប្រសើរនោះគឺ ឈ្នះនូវសេចក្តីអាក្រក់ខ្លួនឯង ឈ្នះនូវកិលេសតណ្ហាដែលស្ថិតនៅក្នុងចិត្តមនុស្សសត្វ។ ឫសគល់ដែលនាំឱ្យមនុស្សសត្វធ្វើអាក្រក់បានដល់អកុសល៣យ៉ាងគឺ **លោភៈ ទោសៈ** និង**មោហៈ**។ ជនឈ្នះនូវសេចក្តីអាក្រក់ឈ្មោះថា ជាជនមានចិត្តបរិសុទ្ធ ពុំបៀតបៀនអ្នកដទៃ ដែលភាសាផ្លូវលោកហៅថា ការគោរពសិទ្ធិមនុស្សនេះឯង។ ការពុំបៀតបៀនអ្នកដទៃ រមែងបានសេចក្តីសុខ ព្រោះពុំមានសត្រូវខាងក្រៅ ដោយបានកម្ចាត់បង់សត្រូវខាងក្នុងគឺសេចក្តីអាក្រក់ក្នុងចិត្តរបស់ខ្លួននេះឯង។ បើឈ្នះសត្រូវក្នុងខ្លួនហើយសត្រូវខាងក្រៅក៏ឈ្នះដែរ។ ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្នះមារ គឺឈ្នះកិលេសតណ្ហាក្នុងព្រះទ័យព្រះអង្គដោយកំចាត់បង់មិនឱ្យកើតមានដោយព្រះអរិយមគ្គ។

# អគតិធម៌៤

**អគតិធម៌** ប្រែថា ធម៌មិលំអៀងមាន៤យ៉ាងគឺ **ឆន្ទាគតិ** លំអៀងព្រោះស្រឡាញ់ **ទោសាគតិ** លំអៀងព្រោះស្អប់ **ភយាគតិ** លំអៀងព្រោះខ្លាច **មោហាគតិ** លំអៀងព្រោះល្ងង់។ **អគតិ**ទាំង៤នេះជាអំពើអយុត្តិធម៌ ប្រែថា ធម៌ពុំត្រឹមត្រូវ ជាគន្លងនៃអំពើបាប។

ពាក្យថា **ឆន្ទាគតិ** លំអៀងព្រោះស្រឡាញ់ សម្រេចសេចក្តីអ្វីមួយដោយការកាន់ជើង បើចៅក្រមកាត់សេចក្តីសម្រេចឱ្យអ្នកដែលខ្លួនកាន់ជើងនោះឈ្នះ ព្រោះហេតុតែសេចក្តីស្រឡាញ់ ទោះអ្នកនោះមានកំហុសក៏ដោយ។

**ទោសាគតិ** លំអៀងព្រោះស្អប់ បើទោះបីអ្នកដែលខ្លួនស្អប់នោះធ្វើត្រូវក៏ដោយ ក៏ឱ្យខុសឱ្យចាញ់ដែរព្រោះហេតុស្អប់។

**ភយាគតិ** លំអៀងព្រោះភ័យខ្លាច ពុំហ៊ានសម្រេចឱ្យខុសដល់អ្នកដែលមានកំហុស ដែលជាអ្នកមានអំណាចបុណ្យស័ក្តិមានទ្រព្យសម្បត្តិច្រើន ដោយខ្លាចអ្នកនោះ ធ្វើសេចក្តីអន្តរាយសងសឹកដល់ខ្លួនវិញ នេះលំអៀងព្រោះភ័យខ្លាច។

**មោហាគតិ** លំអៀងព្រោះល្ងង់ឬពុំដឹងការពិត គឺអ្នកមានវិជ្ជា មានបញ្ញាទន់ខ្សោយឬជាអ្នកគ្មានសមត្ថភាពបានសម្រេចបញ្ហាអ្វីមួយពុំត្រឹមត្រូវ គឺសំ-រេចទៅតាមភាពល្ងង់ខ្លៅរបស់ខ្លួន។

**អគតិធម៌**ទាំង៤នេះជាធមិអកុសលជាអំពើបាប ដែលលោកអ្នកសប្បុរសតែងវៀរចាក ជាពិសេសចៅក្រមកាត់សេចក្ដីក្នុងតុលាការត្រូវតែវៀរចាកកុំឱ្យមានទើបការកាត់សេចក្ដីមានយុត្តិធមិ ។

ចំពោះតុលាការក្នុងប្រទេសដែលកាន់របបប្រជាធិបតេយ្យ មានអំណាចឯករាជ្យដាច់ចេញពីអំណាចនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិ គឺរដ្ឋាភិបាល ។ បានសេចក្ដីថា រដ្ឋាភិបាលមាននាយករដ្ឋមន្ត្រីឬរដ្ឋមន្ត្រីទី១ជាដើមមិនអាចបញ្ជាទៅកាន់តុលាការឱ្យធ្វើតាមខ្លួនបានឡើយ ។ សូម្បីប្រធានាធិបតីឬប្រមុខរដ្ឋ ក៏ពុំអាចធ្វើដូច្នោះបានដែរ ផ្ទុយទៅវិញ បើរដ្ឋមន្ត្រីណាធ្វើខុសច្បាប់របស់រដ្ឋតុលាការមានសិទ្ធិជំនុំជម្រះកាត់ទោសរដ្ឋមន្ត្រីនោះបានដូចជាមនុស្សធម្មតាដែរ គឺមនុស្សគ្រប់រូបទាំងប្រជាពលរដ្ឋទាំងអ្នករដ្ឋការត្រូវស្ថិតនៅក្រោមអំណាចច្បាប់រដ្ឋដូចគ្នា ។ បើអំណាចតុលាការមិនឯករាជ្យស្ថិតនៅក្រោមអំណាចរដ្ឋាភិបាលនោះតុលាការពុំអាចកាត់ទោសសមាជិករដ្ឋាភិបាលដែលប្រព្រឹត្តខុសបានឡើយ ។ ទាក់ទងនឹងអ្នកមានអំណាចរំលោភច្បាប់នេះ ដូចជាប៉ូលីសឬនគរបាលមានតួនាទីរក្សាសន្តិសុខជូនប្រជាពលរដ្ឋនៅក្នុងប្រទេស ។ បើឃើញមនុស្សទាស់ទែងខ្វែងគំនិតគ្នាបម្រុងប្រើអំពើហិង្សា ប៉ូលីសឬនគរបាលត្រូវធ្វើអន្តរាគមន៍បំបែកចេញមិនត្រូវប្រើអំពើហិង្សាបែបណាមួយទៅលើប្រជាពលរដ្ឋឡើយ ។ ទោះបីឃើញអំពើឧក្រិដ្ឋជាក់ស្ដែង ប៉ូលីសឬនគរបាលអាចចាប់ឃុំប៉ុន្តែគ្មានសិទ្ធិធ្វើទណ្ឌកម្មមានវាយដំជាដើមដល់អ្នកនោះឡើយ បើអ្នកនោះពុំបានតដៃ ។ ប៉ូលីសគ្មានសិទ្ធិកាត់ទោសមនុស្សដោយខ្លួនឯងទេ សិទ្ធិនេះនៅលើ

តុលាការ ។ **អគតិធម៌**ទាំង៤នេះ ជាធម៌ដែលអ្នកធំអ្នកមានអំណាចត្រូវលះបង់ហើយអនុវត្តតាមគតិធម៌ជាពិសេសចៅក្រមកាត់សេចក្តី ។ ប្រទេសណាដែលមានចៅក្រមកាត់សេចក្តីពុំលំអៀងដោយអគតិធម៌ទាំង៤នេះ ប្រទេសនោះមានដំណើរទៅរកនីតិរដ្ឋហើយ ។ អ្នករំលោភច្បាប់អាចថយចុះ ដោយសារចៅក្រមកាត់សេចក្តីប្រកបដោយគតិយុត្តិធម៌ ផ្តន្ទាទោសតាមកំហុសចំពោះអ្នកដែលរំលោភច្បាប់ ។

# ការប្រាថ្នាសេចក្ដីសុខ

បុគ្គលណាប្រាថ្នាសេចក្ដីសុខដើម្បីខ្លួន ដោយការធ្វើសេចក្ដីអាក្រក់ឱ្យដល់អ្នកដទៃ បុគ្គលនោះតែងជាប់ជំពាក់ដោយគ្រឿងជំពាក់គឺពៀរមិនរួចផុតអំពីពៀរវេរានេះ ចេញពីបាលីថា **បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ វេរសំសគ្គ សំសដ្ឋោ វេរា សោ ន បរិមុច្ចតិ**។ គាថានេះមានសេចក្ដីថា មនុស្សគ្រប់រូបតែងប្រាថ្នាសេចក្ដីសុខដើម្បីខ្លួន ចង់រស់នៅប្រកបដោយសេចក្ដីចំរើនរុងរឿងដូចគ្នា។ ប៉ុន្តែមនុស្សខ្លះចង់បានសេចក្ដីសុខខ្លួនឯងបែរទៅជាបៀតបៀនអ្នកដទៃ ដែលជាហេតុនាំឱ្យមានទុក្ខដល់ខ្លួនទៅវិញ។ គឺការប្រព្រឹត្តធ្វើអំពើអាក្រក់ប៉ះពាល់ដល់សេចក្ដីសុខរបស់អ្នកដទៃ។ ព្រះពុទ្ធសំដែងថា មនុស្សកើតមកត្រូវបំពេញការងារដែលត្រឹមត្រូវ ការងារដែលមិនមានទោស ការងារដែលមិនធ្វើឱ្យអ្នកដទៃមានទុក្ខព្រួយភ័យខ្លាចឬធ្វើឱ្យគេវិនាស ប៉ុន្តែត្រូវបំពេញការងារប្រកបដោយសុចរិត ដែលហៅថាសម្មាអាជីវោ ប្រែថាការងារដ៏ប្រពៃ។ ខាងចុងនៃគាថានេះបញ្ជាក់ថា បើបុគ្គលបៀតបៀនធ្វើឱ្យគេមានទុក្ខ បុគ្គលនោះតែទទួលផលបាបធ្វើឱ្យខ្លួនមានទុក្ខវិញ តាមកម្រិតអកុសលដែលខ្លួនបានប្រព្រឹត្ត។ ពាក្យថាពៀរ គឺផលនៃអំពើបាបនេះឯង។ ប៉ុន្តែពៀរម្យ៉ាងទៀតសំដៅយកការចងកំហឹងនឹងគ្នាពីជាតិនេះរហូតដល់ជាតិខាងមុខទៀត។ អំពើដែលធ្វើឱ្យគេមានទុក្ខមានប្រភេទច្រើនយ៉ាង មានបុគ្គលខ្លះក្នុងលោកនេះចង់បានទ្រព្យសម្បត្តិអ្នកដទៃក៏ប្រព្រឹត្តការលួចឆក់ប្លន់ទ្រព្យអ្នក

ដទៃ បើអ្នករដ្ឋការប្រព្រឹត្តអំពើពុករលួយ មានអ្នកលួចឬប្លន់ខ្លះហ៊ានរហូតដល់សម្លាប់ម្ចាស់ទ្រព្យថែមទៀត។ ធ្វើឱ្យគេមានទុក្ខធ្វើឱ្យគេអស់ទ្រព្យសម្បត្តិ ហើយមានម្ចាស់ទ្រព្យខ្លះត្រូវបាត់បង់ជីវិតថែមទៀត។ ការលួចប្រពន្ធកូនអ្នកដទៃដើម្បីបំពេញតណ្ហារបស់ខ្លួន នេះជាការប៉ះពាល់ដល់សេចក្តីសុខរបស់អ្នកដទៃ ដែលគេចង់ជួបជុំប្តីប្រពន្ធកូនចៅ មិនចង់បែកបាក់គ្នាដូចខ្លួនអ្នកប្រព្រឹត្តអាក្រក់នោះដែរ។ បើអ្នកនយោបាយវិញលួចសម្លាប់គ្នាដើម្បីបំពេញបំណងរបស់ខ្លួនដែលធ្វើឱ្យគ្រួសារគេព្រាត់ប្រាសគ្នាហើយធ្វើឱ្យជាតិមានអសន្តិសុខផង។ បើអ្នករដ្ឋការប្រព្រឹត្តអំពើពុករលួយស៊ីសំណូក ធ្វើឱ្យសេដ្ឋកិច្ចចុះទន់ខ្សោយ ធ្វើឱ្យប្រជាពលរដ្ឋមានភាពក្រីក្រ។ បើក្នុងប្រទេសកើតសង្គ្រាមនឹងគ្នាវិញ នឹងធ្វើឱ្យប្រជាពលរដ្ឋស្លាប់ព្រាត់ប្រាសគ្នា ពិការបាក់ដៃបាក់ជើង នេះជាសេចក្តីទុក្ខដែលបង្កឡើងដោយបុគ្គលបាប។

អ្នកធ្វើបាបកម្មដោយការលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ឬរបស់ជាតិ បើគេចាប់បាននឹងទទួលទោសទណ្ឌកម្មក្នុងបច្ចុប្បន្ន បើគេចាប់ពុំបានទេក៏គេចពុំផុតពីទោសទៅខាងមុខដែរ។ ក្នុង **សុត្តន្តបិដក** សំដែងថា អ្នកដែលលួចទ្រព្យអ្នកដទៃ ស្លាប់ទៅធ្លាក់ទៅសោយទុក្ខក្នុងនរកលុះសេសសល់ផលកម្ម បើបានមកកើតជាមនុស្សវិញ បើមានទ្រព្យសម្បត្តិក៏ទុកពុំគង់ចេះតែវិនាសទៅវិញ ដោយហេតុផ្សេងៗ។ បើបុគ្គលសម្លាប់គេឬប្រើគេឱ្យសម្លាប់ បើគេចាប់បានត្រូវមានទោសទណ្ឌកម្មក្នុងបច្ចុប្បន្នតាមច្បាប់រដ្ឋ។ លុះបុគ្គលនោះស្លាប់ទៅនឹងត្រូវធ្លាក់ទៅសោយទុក្ខក្នុងនរក លុះសេសសល់ផលកម្ម បើបាន

កើតមកជាសត្វឬមនុស្ស ត្រូវគេសម្លាប់ជាច្រើនជាតិ មានអាយុខ្លីដោយទោស នៃការសម្លាប់គេពីជាតិមុន។ ដូច្នេះតាមអត្ថន័យនៃពុទ្ធភាសិតខាងលើនេះ បញ្ជាក់ថា បើបុគ្គលចង់បានសេចក្តីសុខដល់ខ្លួន មិនត្រូវបៀតបៀនសត្វមនុស្សដទៃឡើយ។ ផ្ទុយទៅវិញត្រូវសាងអំពើល្អ ព្រោះសេចក្តីសុខកើតពីការសាងអំពើល្អនេះឯង សមដូចពុទ្ធភាសិតមួយបទពោលថា **នត្ថិ សន្តិ បរំ សុខំ** មានន័យថាសេចក្តីសុខកើតពីការស្ងប់ គឺស្ងប់ពុំធ្វើបាបនេះឯង។

# ពាក្យពិតជាពាក្យពុំស្លាប់

ពាក្យថា **សច្ចំ វេ អមតា វាចា** ប្រែថា ពាក្យពិតមែនជាពាក្យពុំស្លាប់ នេះបានសេចក្តីថា ពាក្យពិតមែនជាពាក្យត្រូវរហូតដូចជាពុទ្ធភាសិត ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គបានត្រាស់សំដែងជាង២៥០០ឆ្នាំកន្លងទៅហើយ ពាក្យនោះនៅតែពិតដដែលហើយនិងនៅតែពិតជានិច្ច ព្រោះជាសច្ចៈសកលពុំមែនជាសច្ចៈសម្រាប់តែទីកន្លែងមួយៗទេ គឺជាការពិតទូទៅគ្រប់ទីកន្លែងនិងគ្រប់ពេលដូចជាពាក្យថា ធ្វើបាបបានបាបធ្វើបុណ្យបានបុណ្យ សង្ខារទាំងឡាយមានខន្ធ៥ជាដើមប្រព្រឹត្តទៅជាអនិច្ចំពុំទៀង ជាទុក្ខំជាទុក្ខ និងជាអនត្តាពុំមែនជារបស់ខ្លួន គឺត្រូវគ្រប់សង្ខារទាំងអស់នៃជនជាតិក្នុងលោក ទោះបីអ្នកមិនកាន់ព្រះពុទ្ធសាសនាក៏ដោយ ។ នេះជាពាក្យពិតមិនចេះស្លាប់ គឺជាពាក្យពុំប្រែប្រួលទៅតាមពេលនិងទីកន្លែងឡើយ ព្រោះមានពាក្យខ្លះដូចជាសុភាសិតបុរាណ ឬសុភាសិតរបស់ជនជាតិដទៃ ដែលកើតពីមនុស្សធម្មតាពោលឡើង ត្រូវបានតែតាមវប្បធម៌របស់ខ្លួននិងតាមពេលប៉ុណ្ណោះ ពុំមែនជាសច្ចៈសាកលឡើយ សច្ចៈបែបនេះហៅថា **លោកិយសច្ចៈ** ឬ **សម្មតិសច្ចៈ** ជាសច្ចៈធម្មតារបស់មនុស្ស ដែលបញ្ចេញទស្សនៈតាមការយល់ឃើញរបស់ខ្លួន។ ចំណែកសច្ចៈដែលព្រះពុទ្ធត្រាស់ដឹង ដែលហៅថា **អរិយសច្ចៈ** ឬ **បរមត្ថសច្ចៈ** ជាសច្ចៈដ៏ប្រសើរខ្ពង់ខ្ពស់ស្របតាមច្បាប់ធម្មជាតិ។ ពាក្យថា **ធម្មជាតិ** គឺពិតតាមកំណើតដើមឬធាតុរបស់វាប្រព្រឹត្តទៅយ៉ាងណាវានៅតែប្រព្រឹត្តទៅយ៉ាងនោះ

គេពុំអាចកែច្បាប់ធម្មជាតិនោះបានឡើយ ដូចជារដូវប្រចាំឆ្នាំនីមួយៗបើដល់ពេលរដូវត្រជាក់ហើយ តែងតែត្រជាក់ពុំអាចកែជាក្តៅក្នុងរដូវត្រជាក់នោះឡើយ នេះជាច្បាប់ធម្មជាតិពុំមែនព្រះជាម្ចាស់អង្គណាបង្កើតឱ្យមានឡើយ។ ច្បាប់កម្មផលជាច្បាប់ធម្មជាតិ គឺអំពើបែបណាតែងចេញផលបែបនោះ គ្រាន់តែផ្តល់ផលយូរឬឆាប់តាមហេតុការណ៍ដែលវាអាចឱ្យផលបាន វាពិតជាបញ្ចេញផលតាមហេតុឬអំពើរបស់វាដោយគ្មានអំពើណាមួយពុំមានបញ្ចេញផលនោះឡើយ ហើយផលដែលកើតឡើង ដោយសារមានហេតុ នេះជាច្បាប់មានទំនាក់ទំនងរវាងហេតុនិងផល មានប្រព័ន្ធទាក់ទងគ្នាស្របតាមលក្ខណៈធម្មជាតិ គេពុំអាចកែប្រែច្បាប់ដែលមានសច្ចភាពនេះបានឡើយ។ ពាក្យពិតជាពាក្យពុំស្លាប់ គឺជាពាក្យនៅតែពិតជានិច្ចហើយជាពាក្យមានតម្លៃគ្រប់ពេលនិងគ្រប់ទីកន្លែង។ ផ្ទុយទៅវិញ បើពាក្យពុំពិតនិងរស់នៅពុំបានយូរឡើយនឹងត្រូវវិនាសសាបសូន្យទៅវិញ នៅពេលការពិតលេចចេញមក។ កាលណាគេដឹងការពិតពាក្យនោះត្រូវអស់តម្លៃខ្លួនឯង ដូចពាក្យចាស់បុរាណខ្មែរពោលថាពាក្យភូតចាញ់អាត្មា។ ពាក្យពុំពិតតាមន័យព្រះពុទ្ធសាសនា សំដៅយកវាចាដែលចាត់ទុកក្នុងទិដ្ឋិការយល់ខុស គឺរបស់មិនទៀងសម្គាល់ថាទៀង របស់ជាទុក្ខសម្គាល់ថាសុខ របស់ជាអនត្តាសម្គាល់ថាអត្តាគឺថាជាខ្លួន របស់មិនស្អាតសម្គាល់ថាស្អាត របស់ជាបាបសម្គាល់ថាជាបុណ្យ របស់ជាគុណសម្គាល់ថាជាទោស របស់អាក្រក់សម្គាល់ថាជារបស់ល្អ របស់វិនាសសម្គាល់ថាចំរើនជាដើម។ បើបុគ្គលមានគំនិតយល់ខុស ព្រមទាំងណែនាំគេឱ្យយល់ខុស បុគ្គល

នោះនឹងដល់នូវសេចក្តីវិនាសថែមទាំងធ្វើឱ្យគេវិនាសផង។ ត្រង់នេះហើយដែលព្រះពុទ្ធបានហាម គឺកុំសេពគប់ជនពាលដែលមានគំនិតយល់ខុសប្រាសចាកសភាពពិតនៃព្រះធម៌ដែលនាំឱ្យគេសិក្សាតាមគំនិតយល់ខុសនោះ។

ចំពោះអ្នកដឹកនាំគ្រប់ប្រភេទ បើដឹកនាំក្នុងផ្លូវខុសហើយនឹងនាំឱ្យអ្នកដើរតាមទទួលនូវសេចក្តីវិនាស ដូចអ្នកកាច់ចង្កូតរថយន្ត កប៉ាល់ ឬនាវា បើអ្នកបើកពុំស្ទាត់ជំនាញ ពុំដឹងផ្លូវច្បាស់នឹងធ្វើឱ្យអ្នកជិះស្លាប់ឬត្រូវរបួស។ យ៉ាងណាមិញ អ្នកកាច់ចង្កូតស្រុកទេស បើអ្នកដឹកនាំមានគំនិតយល់ខុសមានផែនការមិនល្អ មិនអាចធ្វើឱ្យស្រុកទេសចំរើនលូតលាស់បានឡើយ ផ្ទុយទៅវិញនឹងធ្វើឱ្យស្រុកទេសវិនាសទៅវិញ។ មេដឹកនាំព្រះពុទ្ធសាសនា គឺព្រះពុទ្ធព្រះបរមគ្រូ ព្រះអង្គត្រាស់ដឹងនូវធម៌ពិតជាធម៌ដឹកនាំមនុស្សសត្វឱ្យចេញចាកទុក្ខ ទើបសព្វថ្ងៃនេះ មនុស្សកាន់តែមានចំនួនច្រើនឡើងក្នុងពិភពលោកទទួលយកធម៌ព្រះអង្គទៅប្រតិបត្តិតាម។

# សាមគ្គីធម៌

ពុទ្ធភាសិតថា **សាមគ្គី សាមគ្គានំ តបោ សុខោ** ប្រែថា ការព្រមព្រៀងគ្នារបស់អ្នកព្រមព្រៀងគ្នាទាំងឡាយជាតបធម៌នាំឱ្យមានសេចក្តីសុខ។ មានអត្ថន័យថា សង្គមណាក៏ដោយបើមានការព្រមព្រៀងគ្នាដោយកាយវាចាចិត្តហើយ សង្គមនោះរមែងបាននូវសេចក្តីសុខ។ មូលហេតុដែលនាំឱ្យកើតសាមគ្គី សូមលើកយកតែធម៌មួយជាចម្បង គឺបើព្រះសង្ឃគោរពវិន័យ បើគ្រហស្ថគោរពច្បាប់ជាតិនិងច្បាប់អន្តរជាតិ នោះសាមគ្គីរមែងកើតមាន។

ចំពោះព្រះសង្ឃព្រះពុទ្ធសាសនា ព្រះពុទ្ធបានបញ្ញត្តព្រះវិន័យទុកជាក្បួនខ្នាតសម្រាប់ព្រះសង្ឃគ្រប់ព្រះអង្គប្រតិបត្តិតាម ដើម្បីការបរិសុទ្ធក្នុងសង្គមរបស់ព្រះសង្ឃ។ បើព្រះសង្ឃបរិសុទ្ធគ្រប់អង្គហើយសាមគ្គីរមែងកើតមាន កាលណាបើមានសាមគ្គីហើយ សេចក្តីសុខរមែងកើតមាន។ ផ្ទុយទៅវិញ ព្រះសង្ឃដែលបរិសុទ្ធនិងមិនសាមគ្គីជាមួយព្រះសង្ឃដែលមិនបរិសុទ្ធមិនគោរពព្រះវិន័យមានមិនធ្វើសង្ឃកម្មជាមួយជាដើម។ បើព្រះសង្ឃគ្រប់វត្តក្នុងប្រទេសកម្ពុជាគោរពព្រះវិន័យ នោះសាមគ្គីរបស់ព្រះសង្ឃរមែងកើតមានទូទាំងប្រទេសដែរ ព្រោះក្នុងព្រះវិន័យព្រះសង្ឃបរិសុទ្ធ ពុំអាចធ្វើសង្ឃកម្មជាមួយព្រះសង្ឃមានកំហុស ឬមានកំហុសហើយពុំបានសម្អាតឱ្យបរិសុទ្ធឡើយ។ ដូច្នេះបញ្ជាក់ថា សាមគ្គីធ្វើសង្ឃកម្មជាមួយគ្នារបស់ព្រះសង្ឃដែលហៅថាសង្ឃកម្មមានច្រើន ដែលព្រះសង្ឃក្នុងព្រះពុទ្ធសាសនាត្រូវព្រមព្រៀងគ្នាធ្វើ

ដូចជា **ធ្វើឱ្យចោសចសំដែង ឃាតិមោក្ខ ធ្វើកឋិនកម្ម បវារណាកម្ម** ជាដើម។ ពេលមានកិច្ចប្រជុំត្រូវព្រមព្រៀងគ្នាប្រជុំនិងព្រមព្រៀងគ្នាក្រោកចាកការប្រជុំជាដើម។ ដូច្នេះបើព្រះសង្ឃគ្រប់អង្គគោរពព្រះវិន័យ សាមគ្គីរមែងកើតមានឡើង។

ចំណែកគ្រហស្ថផ្លូវអាណាចក្រវិញ មូលហេតុដែលនាំឱ្យមានសាមគ្គី គឺកើតឡើងពីការគោរពច្បាប់របស់ប្រទេសនិងច្បាប់អន្តរជាតិ។ បានសេចក្ដីថា ទាំងប្រជាពលរដ្ឋទាំងអ្នករដ្ឋការគ្រប់តំណែងពីថ្នាក់លើមកថ្នាក់ក្រោមបានគោរពច្បាប់ទាំងអស់គ្នា នោះសាមគ្គីរមែងកើតមានព្រោះមានការទុកចិត្តគ្នា ដោយទាំងអស់គ្នាស្ថិតនៅក្រោមអំណាចច្បាប់។

តុលាការកាត់សេចក្ដីប្រកបដោយគតិយុត្តិធម៌ពុំលំអៀងច្បាប់របស់ប្រទេសនីមួយៗដែលគាត់តែងឡើងសម្រាប់គោរពទាំងអស់គ្នា។ បើច្បាប់នោះគោរពតែប្រជាពលរដ្ឋអ្នករដ្ឋការពុំគោរពឬគោរពតែអ្នករដ្ឋការថ្នាក់ក្រោម ចំណែកអ្នករដ្ឋការថ្នាក់លើមិនគោរព ច្បាប់នោះពុំមានប្រសិទ្ធភាពឡើយ។ ជាពិសេសប្រទេសមួយ បើគ្មានយុត្តិធម៌ក្នុងសង្គមទេ ការបែកបាក់គ្នារមែងកើតមាន។ បានសេចក្ដីថា មនុស្សល្អគោរពច្បាប់មិនអាចទៅរួមជាមួយមនុស្សអាក្រក់មិនគោពរច្បាប់ឡើយ គឺមនុស្សល្អមិនធ្វើចោរមិនអាចទៅរួមជាមួយមនុស្សអាក្រក់លួចប្លន់ឡើយ។ ឧទាហរណ៍នៅប្រទេសកម្ពុជា ប្រជាពលរដ្ឋខ្មែរដែលសល់ពីស្លាប់ដោយអំពើឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហមមិនជឿទុកចិត្តខ្មែរក្រ-ហម ដែលបានធ្វើបាបខ្លួនឡើយ។ កាលណាមិនជឿទុកចិត្តការសាមគ្គីជាមួយ

ខ្មែរក្រហម ក៏ពុំអាចកើតមានឡើយ។ ប្រជាពលរដ្ឋខ្មែរមិនរួមជាមួយជនពុករលួយរំលោភច្បាប់ធ្វើឱ្យខូចប្រយោជន៍ជាតិឡើយ ដូចច្បាប់ហាមមិនឱ្យកាប់ព្រៃឈើជនពុករលួយកាប់ព្រៃឈើស្ទើរពាយស្រុកខ្មែរ។ ច្បាប់ហាមមិនឱ្យរំលោភដីរដ្ឋនិងដីរបស់ប្រជាពលរដ្ឋ ជនអ្នកមានអំណាចបានរំលោភយកដោយគ្មានខ្លាចរអែង។ ការអនុវត្តច្បាប់ពុំបានត្រឹមត្រូវបានបង្កើតនូវអំពើអយុត្តិធម៌ក្នុងសង្គម ដែលធ្វើឱ្យអ្នកមាននិងអ្នកក្រមានគម្លាតគ្នាកាន់តែឆ្ងាយទៅៗ។ ការនេះបានប៉ះពាល់ដល់អ្នកក្រីក្រ ដែលរកមិនបានមួយដុល្លារក្នុងមួយថ្ងៃហើយ អ្នករដ្ឋការតូចតាចបានប្រាក់បៀវត្សរ៍តិចស្ទើរតែមិនអាចរស់បាន។ បញ្ហាព្រំដែនដីគោកនិងដីសមុទ្រខ្មែរមានភាពមិនប្រក្រតី និងបញ្ហាជនអន្តោប្រវេសន៍ចូលមកប្រទេសកម្ពុជាមិនប្រក្រតី រដ្ឋគប្បីខិតខំដោះស្រាយស្របតាមច្បាប់ជាតិនិងច្បាប់អន្តជាតិ ដើម្បីការពារប្រយោជន៍ខ្មែរ។

នៅប្រទេសដែលកាន់របបប្រជាធិបតេយ្យអ្នកដឹកនាំសុខចិត្តលាចេញពីតំណែង បើគេដឹងខ្លួនគេថាមិនអាចដោះស្រាយបញ្ហាជាតិពេលនេះបានទេ ដើម្បីទុកឱកាសឱ្យអ្នកមានសមត្ថភាពដោះស្រាយបន្តមិនទុកឱ្យវិបត្តិកាន់តែធ្ងន់ឡើង ខូចប្រយោជន៍ជាតិឡើយហើយគេមិនប្រើអំពើហិង្សាបង្ក្រាបចំពោះអ្នកប្រឆាំង ដើម្បីដោះស្រាយបញ្ហាទ័លច្រករបស់ខ្លួន ឬគេចវេសមិនដោះស្រាយឡើយ ព្រោះនេះជាអំពើរំលោភច្បាប់។ ដូចនេះ ការគោរពច្បាប់ជាកត្តាចម្បងទីមួយឆ្ពោះទៅរកសាមគ្គីភាពនៃសង្គមប្រជាធិបតេយ្យ។ ក៏ដូចជា

ព្រះសង្ឃគោរពវិន័យ  ជាកត្តានាំឱ្យមានសាមគ្គីរវាងព្រះសង្ឃនិងព្រះសង្ឃដូចគ្នាដែរ ។

# ធម្មាធិបតេយ្យ និង ប្រជាធិបតេយ្យ

## ១~ ធម្មាធិបតេយ្យ :

ពាក្យថា **ធម្មាធិបតេយ្យ** មកពីពាក្យថា **ធម្ម** + **អាធិបតេយ្យ** ប្រែថា មានធមិជាអធិបតី ឬមានធមិជាធំ។ ពាក្យធមិក្នុងទីនេះ សំដៅយកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលនិយាយការពិត ជាសច្ចធមិដែលណែនាំមនុស្សនិងសង្គមមនុស្សទៅរកសុខសន្តិភាព។ ផ្លូវធមិនេះ ជាច្បាប់សកលជាច្បាប់យុត្តិធមិដែលរកឃើញនិងសំដែងដោយព្រះសម្មាសម្ពុទ្ធជាង២៥០០ឆ្នាំមកហើយ។ ព្រះពុទ្ធដីកាសំដែងយ៉ាងណាហើយនៅតែការពិតយ៉ាងនោះត្រូវគ្រប់ទីកន្លែងនិងគ្រប់កាលៈទេសៈ ដូចជាពាក្យថា កើតចាស់ឈឺស្លាប់ បុណ្យបាបគុណទោស មគ្គផលនិព្វានជាដើម។

ផ្លូវធមិ គឺនិយាយពីការពិត ជាតថភាពការពិតយ៉ាងណានិយាយយ៉ាងនោះ ជាយថាវត្ថុជាច្បាប់ពិតសកលទៅតាមពិត ពុំមែននិយាយពីការចូលចិត្ត ឬតាមជំនឿនោះឡើយ។ ការយកធមិជាធំមានន័យថា មុននឹងធ្វើការងារអ្វីមួយបានគិតពិចារណាថា អំពើដែលបម្រុងធ្វើនោះ តើមានខុសផ្លូវធមិឬទេ? បើឃើញថាអំពើនោះត្រឹមត្រូវតាមផ្លូវធមិហើយ ទើបសម្រេចចិត្តធ្វើ ។ អំពើត្រឹមត្រូវជាផ្លូវធមិ គឺប្រព្រឹត្តអំពើល្អជាកុសល ជៀសវាងអំពើអកុសល អំពើបៀតបៀន អំពើអយុត្តិធមិនេះហៅថា **ធម្មាធិបតេយ្យ** យកធមិជាធំ។ ប្រៀបដូចអ្នកគោរពផ្លូវអាណាចក្រពុំហ៊ានប្រព្រឹត្តអំពើណាមួយដែលខុស

ច្បាប់រដ្ឋ។ បើនិយាយអំពីសង្ឃកម្មរបស់ព្រះសង្ឃដែលបានព្រមព្រៀងគ្នាបំពេញកិច្ចការអ្វីមួយរបស់ព្រះសង្ឃត្រូវសម្រេចឡើង ដោយមតិភាគច្រើនរបស់ព្រះសង្ឃ ហៅថា សម្រេចដោយធម៌ **យកធម៌ជាធំ** ហើយនោះក៏ចាត់ជា **ប្រជាធិបតេយ្យ** របស់ព្រះពុទ្ធសាសនាដូចផ្លូវអាណាចក្រដែរ ។

**២- ប្រជាធិបតេយ្យ :**

ពាក្យថា **ប្រជាធិបតេយ្យ** មកពីពាក្យថា **ប្រជា + អាធិបតេយ្យ** ប្រែថា យកប្រជាពលរដ្ឋជាធំ គឺពោលដល់អំណាចនៃរដ្ឋត្រូវកើតចេញមកពីប្រជាពលរដ្ឋ។ នៅក្នុងប្រទេសដែលមានប្រជាធិបតេយ្យ គេបានចាត់ចែងឱ្យប្រជាពលរដ្ឋជ្រើសរើសតំណាងរបស់ខ្លួនដែលហៅថា តំណាងរាស្ត្រជាអ្នកកាន់នីតិបញ្ញត្តិតាមរយៈការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ រួចហើយជ្រើសរើសរដ្ឋាភិបាលដឹកនាំប្រទេសជាអ្នកកាន់នីតិប្រតិបត្តិ។ អំណាចមួយទៀត គឺអំណាចតុលាការ ជាស្ថាប័នរកយុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់ឋានៈនៅក្នុងប្រទេស។ អំណាចទាំងបី គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ត្រូវឱ្យដាច់ពីគ្នាដោយឯករាជរៀង១ខ្លួន។ បើអំណាចទាំងបីនេះនៅជាមួយគ្នា ការអនុវត្តពុំមានយុត្តិធម៌ឡើយ គឺជារបបផ្តាច់ការ។ បានសេចក្តីថា ធ្វើច្បាប់ខ្លួនឯង អនុវត្តច្បាប់ខ្លួនឯង កិច្ចការគ្រប់យ៉ាងសម្រេចថាមានយុត្តិធម៌ឬពុំមានយុត្តិធម៌ដោយខ្លួនឯង។ ឧទាហរណ៍ ចោទមនុស្សដោយខ្លួនឯង សម្រេចឱ្យមានទោសដោយខ្លួនឯង យ៉ាងនេះពុំមានយុត្តិធម៌ឡើយ។ បើនិយាយឱ្យងាយយល់ គឺប្រជាពលរដ្ឋទាំងអស់ពុំអាចទៅកាន់តំណាងខាង

នីតិបញ្ញត្តិ ខាងរដ្ឋាភិបាល និងខាងតុលាការទាំងអស់គ្នាបានទេ គឺត្រូវជ្រើសរើសតំណាងរបស់ខ្លួនឱ្យទៅធ្វើការជំនួសខ្លួនដូចពោលមកហើយនេះឯង។ ដើម្បីអនុវត្ត**របបប្រជាធិបតេយ្យ**នេះអោយមានប្រសិទ្ធិភាព លុះត្រាតែប្រជាពលរដ្ឋមានសេរីភាពជាមូលដ្ឋានពេញបរិបូណ៌ ព្រោះលទ្ធិប្រជាធិបតេយ្យជាទ្រឹស្តីមួយថែងថា អំណាចរបស់រដ្ឋគ្រប់យ៉ាងត្រូវកើតចេញមកពីប្រជាពលរដ្ឋដែលជាម្ចាស់អំណាច។

បើគេយកធម្មាធិបតេយ្យរបស់ព្រះពុទ្ធសាសនាប្រៀបធៀបនឹងប្រជាធិបតេយ្យរបស់ផ្លូវអាណាចក្រមានលក្ខណៈដូចគ្នានិងខុសគ្នា ដូចតទៅ :

១- ដូចគ្នាត្រង់ការសម្រេចកិច្ចការធំៗរបស់សង្គមត្រូវយកតាមមតិភាគច្រើនរបស់សមាជិកដែលបានអនុម័ត ។

២- ខុសគ្នាត្រង់របបប្រជាធិបតេយ្យនៃផ្លូវអាណាចក្រសម្រេចតាមមតិភាគច្រើននៃសមាជិកសង្គម ឯមតិភាគតិចត្រូវតែសម្រេចតាមមតិភាគច្រើន។ របបនេះអំណាចទាំងបីធ្វើការមានកំណត់ឆ្នាំ ដើម្បីឱ្យប្រជាពលរដ្ឋពិនិត្យមើលសកម្មភាពធ្វើការ តើចំរើនឬពុំចំរើន ហើយប្រជាពលរដ្ឋ បញ្ចេញមតិសាជាថ្មី។ ឯធម្មាធិបតេយ្យរបស់ព្រះពុទ្ធសាសនា បើពិនិត្យមើលកិច្ចការរបស់ព្រះសង្ឃ ដែលហៅថាសង្ឃកម្មដូចជាកឋិនកម្មជាដើម គឺភិក្ខុដែលអាចក្រាលគ្រងកឋិនបាន លុះត្រាតែមានការស្រុះស្រួលយល់ព្រមពីព្រះសង្ឃដទៃទៀតក្នុងអង្គប្រជុំ ហើយព្រះសង្ឃដែលក្រាលគ្រងនោះមានសមត្ថភាព និងមានគុណសម្បត្តិអាចក្រាលគ្រងធ្វើឱ្យសម្រេចកឋិនផង និងញ៉ាំងព្រះសង្ឃឱ្យ

ត្រេកអរផង  ទើបឈ្មោះថាប្រកបដោយធម៌។ ដូចនេះប្រជាធិបតេយ្យរបស់ព្រះពុទ្ធសាសនាសម្រេចតាមមតិភាគច្រើនផង ជាអ្នកមានសមត្ថភាពនិងគុណសម្បត្តិផង។

# អនត្តាធម៌របស់ព្រះពុទ្ធសាសនា

ធម៌ **អនត្តា** ជា ធម៌ដែលព្រះពុទ្ធត្រាស់ដឹងថា អ្វីទាំងអស់សុទ្ធតែកើតឡើងពីគ្រឿងផ្សំដែលបាលីហៅថា **សង្ខារ** គឺកើតឡើងដោយ **ហេតុ-បច្ច័យ** ពុំមែនជាតួខ្លួនវាពិតទេ។ ពាក្យថា **អនត្តា** ចេញមកពីពាក្យបាលីថា **ន** និង **អត្តា**។ ពាក្យថា **អត្តា** ប្រែថាខ្លួន និង **ន** ជាតួបដិសេធ ប្រែថា មិន គឺពុំមែនជាតួខ្លួនពិតប្រាកដទេ។ ពាក្យនេះព្រះពុទ្ធបានបដិសេធនូវទស្សនៈរបស់ពួកព្រាហ្មណ៍ដែលថា មានធម្មជាតិម្យ៉ាងដែលពួកនេះហៅថា **អាត្ម័ន** តាមភាសាសំស្ក្រឹត និង តាមភាសាបាលីហៅថា **អត្តា** ខ្មែរថាព្រលឹងឬវិ-ញ្ញាណ, បារាំងថា *L'âme, L'espri* អង់គ្លេសថា *Mind, Conscience, Ego (Ego)* នេះក្លាយពីពាក្យក្រិក នៅក្នុងខ្លួនមនុស្សសត្វ មិនចេះស្លាប់ ទោះបីជីវិតស្លាប់ទៅក៏ដោយ។ ព្រះពុទ្ធឱ្យឈ្មោះទិដ្ឋិយល់ខុសនេះថា **សស្សតទិដ្ឋិ** ដែលយល់ថា ចិត្តវិញ្ញាណនេះទៀងមិនចេះរលត់ គឺបើរូបរាងកាយស្លាប់ តែ **អាត្ម័ន** ដែលជាចិត្តវិញ្ញាណនេះ ពុំស្លាប់ចេញពីរូបកាយចាស់ដែលស្លាប់ទៅស្វែងរកភពថ្មីទៀត ប្រៀបដូចផ្ទះដែលត្រូវភ្លើងឆេះ អ្នកម្ចាស់ផ្ទះតែងចេញទៅកសាងផ្ទះទៀតជាធម្មតា។ **ព្រះពុទ្ធ** ត្រាស់ថា គំនិតដែលពួកសាសនាព្រាហ្មណ៍យល់ថាជាអត្តា នោះគ្មានអ្វីក្រៅពី **នាមធម៌** ដែលនៅក្នុងខន្ធ៥ គឺ **រូប វេទនា សញ្ញា សង្ខារ** និង **វិញ្ញាណ** ឡើយ។ ខន្ធ៥នេះហើយដែលគេសំ

គាល់ថាជាខ្លួន តាមពិតខន្ធ៥នេះប្រព្រឹត្តទៅជា **អនិច្ចំ ទុក្ខំ** និង **អនត្តា**។ បើខន្ធ៥នេះជារបស់ខ្លួនគេពិតមែន មានខ្លឹមសារ តើពួកព្រាហ្មណ៍អាចបង្គាប់បញ្ជាកុំឱ្យខន្ធ៥នេះប្រែប្រួលទៅកាន់ការចាស់ ឈឺ ស្លាប់ និង កុំឱ្យកើតក្នុងទីថោកទាបបានឬទេ? ព្រះពុទ្ធសំដែងថា វិញ្ញាណពុំអាចស្ថិតនៅដោយគ្មានរូបបានឡើយ គឺ វិញ្ញាណ និង រូប ត្រូវអាស្រ័យគ្នា ទើបប្រព្រឹត្តទៅបាន។ អ្វីដែលទៅកើតទៀតនោះ ព្រះពុទ្ធពុំដែលសំដែងថា វិញ្ញាណទៅកើតទៀតឡើយ តែព្រះអង្គសំដែងអំពី **វិបាក** របស់ **កម្ម** ដែលខន្ធចាស់បានប្រព្រឹត្តធ្វើកើតចេញជាថាមពលមួយមានចលនាទៅមុខទៀត ដែលហៅថាវិបាកវិ-ញ្ញាណ តែពុំមែនជាវិញ្ញាណដែលកើតមានដោយ ផស្សៈរវាងអាយតនៈខាងក្នុងគឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង មនោ ប៉ះនឹង **រូប សម្លេង ក្លិន រស សម្ផស្ស** និង **ធម្មៈ** (អារម្មណ៍ក្នុងចិត្ត) ដែលនាំឱ្យកើតវិញ្ញាណនេះទេ។ ទស្សនៈអំពីវាសនាបន្ទាប់ពីស្លាប់ទៅនេះ ព្រះពុទ្ធបានបដិសេធអំពីទិដ្ឋិ ការយល់ខុសមួយទៀតអំពីទស្សនៈអ្នករៀនផ្លូវលោក ជាពិ-សេសអ្នករៀនវិទ្យាសាស្ត្រផ្នែក **រូបវិទ្យា** និង **គីមីវិទ្យា** *(Physique, Chemistry)* ដែលយល់ថា មនុស្សសត្វស្លាប់ទៅសូន្យពុំកើតទៀត។ ព្រះពុទ្ធសំដែងថា មនុស្សសត្វបើនៅមាន **អវិជ្ជា តណ្ហា ឧបាទាន** ជាហេតុ ជាបច្ច័យ នាំឱ្យសាងកម្មល្អកម្មអាក្រក់ នាំឱ្យមានវិបាក *(Consequence)* បដិ-សន្ធិទៅតាមកម្មផលរបស់ខ្លួន។ ទិដ្ឋិយល់ខុសដែលថាមនុស្សសត្វស្លាប់ទៅ

សូន្យនេះ ព្រះពុទ្ធឱ្យឈ្មោះថា **ឧច្ឆេទទិដ្ឋិ**។ **ហេតុ** និង **ផល** តែងមានសម្ពន្ធភាពទាក់ទងគ្នា ហេតុតែងមានផល ហើយផលកើតមាន ព្រោះមានហេតុ នេះជាច្បាប់ធម្មជាតិ គ្មានព្រះជាម្ចាស់ *(Dieu, God)* ណាបណ្ដាលឱ្យមានឡើយ។ ច្បាប់សាកលនេះ ក៏ពុំមែនព្រះពុទ្ធបង្កើតឱ្យមានដែរ ព្រះពុទ្ធគ្រាន់តែត្រាស់ដឹងឃើញការពិតជាអរិយសច្ចៈ *(Noble Truth)* ប៉ុណ្ណោះ។ ក្រុមវិទ្យាសាស្ត្រយល់ថា ធម្មជាតិទាំងអស់តែងមានខ្លឹមឬបណ្ដូលរបស់វា។ ព្រះពុទ្ធសំដែងថា វត្ថុមានវិញ្ញាណនិងគ្មានវិញ្ញាណទាំងអស់ពុំមែនខ្លឹមសារទេ ព្រោះវត្ថុទាំងនោះពុំមែនកើតមានពីកំណើតទេ គឺកើតឡើងពីគ្រឿងផ្សំទាំងអស់ *(Corps composé, Component)*។ ដូចជារូបរាងកាយរបស់មនុស្សសត្វកើតពីការផ្សំធាតុទាំង៤ គឺ ធាតុដី ទឹក ភ្លើង ខ្យល់។ មួយទៀត ដូចក្រុមវិទ្យាសាស្ត្ររកឃើញតាមគីមីវិទ្យាថា ធាតុទឹកកើតមកពីអ៊ីដ្រូសែនពីរ និង អុកស៊ីសែនមួយ *(តាមរូបមន្ត* $H_2O$*)*។ **អនត្តា** ក្នុងន័យព្រះពុទ្ធសាសនា គឺវត្ថុកើតពីគ្រឿងផ្សំ វត្ថុនោះត្រូវរលាយទៅវិញដោយគ្មានស្ថាប់បង្គាប់។ ប៉ុន្តែវេទនាជាសុខជាទុក្ខ ពុំមែនជាសុខជាទុក្ខមានពិតប្រាកដ ប៉ុន្តែអ្នកទទួលវេទនាគ្មាន នេះជាអត្ថន័យរបស់ព្រះពុទ្ធសាសនាក្នុងការវិភាគរកការពិតនូវ **រូបធម៌** និង **នាមធម៌** (ខន្ធ៥)។ អ្នកខ្លះសួរថាបើថាខ្លួនជា**អនត្តា**ពិតមែន ម៉េចក៏អារ ឬកាប់សាច់ឈឺ។ **អនត្តា** ពុំមែនអារឬកាប់សាច់ពុំឈឺនោះឡើយ តែនៅត្រង់ប្រាជ្ញាឃើញការពិតទៅលើសង្ខារគឺវត្ថុកើតពីគ្រឿងផ្សំនេះឯង។ ឃើញ**អនត្តា**ដោយប្រតិបត្តិតាម **សីល សមាធិ បញ្ញា** ហើយការឃើញខ្លួន ថាពុំមែនខ្លួន

ជា **អនត្តា** នាំឱ្យមនុស្សដាក់មានៈការប្រកាន់ខ្លួន ដែលជាហេតុនាំឱ្យសាង អំពើបាប ចំណែកអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាដើម លោកលះអំពើបាបអស់ហើយ ព្រោះលោកឃើញការពិតថា ខន្ធ៥ជា **អនត្តា**នេះឯង ។

# ព្រះពុទ្ធទ្រង់ប្រោសមាលុង្ក្យបុត្រ

សាវ័ករបស់ព្រះពុទ្ធមួយព្រះអង្គនាម **មាលុង្ក្យបុត្រ** ដែលមានសេចក្ដីសង្ស័យក្នុងសាសនា បានក្រាបបង្គំទូលសួរព្រះសាស្ដាថា បពិត្រព្រះបរមគ្រូជាម្ចាស់ ពិភពលោកទៀងឬពុំទៀង មានទីបំផុតឬពុំមានទីបំផុតទេ។ ចិត្តជាវត្ថុតែមួយជាប់នឹងកាយឬក៏ជាវត្ថុដោយឡែកដាច់ពីកាយ ព្រះពុទ្ធនៅមានក្រោយពីបរិនិព្វានឬនឹងមិនមានទេ ក្នុងកាលជាខាងក្រោយបរិនិព្វាន។ សាវ័កអង្គនេះ បន្ថែមសេចក្ដីថា បើព្រះអង្គពុំអាចឆ្លើយនឹងសំនួរទាំងនេះបានទេ សូមតបឱ្យច្បាស់ថា ព្រះអង្គមិនជ្រាបមិនដឹងរឿងនេះទេ ខ្ញុំព្រះអង្គនឹងលាចាកសិក្ខាបទ ហើយចេញចាកពីទីនេះទៅរកកន្លែងដទៃ។ ព្រះបរមគ្រូត្រាស់សួរតបវិញថា ម្នាលមាលុង្ក្យបុត្រ! តថាគតដែលបានប្រាប់អ្នកថា ចូរអ្នកមកបួសក្នុងសំណាក់**តថាគត** **តថាគត**នឹងពន្យល់អ្នកពីសំនួរទាំងនេះដែរឬទេ ? បពិត្រព្រះដ៏មានព្រះភាគ ព្រះអង្គពុំដែលមានព្រះពុទ្ធដីកាដូច្នេះទេ។ បើដូច្នេះ មានតែថាខ្ញុំព្រះអង្គចូលមកកាន់ផ្នួសក្នុងសំណាក់របស់ព្រះអង្គ ដោយសារតែតថាគតនឹងពន្យល់ពីពាក្យសួរនេះឬ? ខ្ញុំព្រះអង្គពុំបានទូលថ្វាយដូច្នេះទេ។ ឥឡូវនេះ លក្ខខ័ណ្ឌទាំងពីរប្រការនេះ តើកើតឡើងទៅវិញទៅមកឬទេ? សូមទ្រង់ព្រះមេត្តាប្រោស ឥតមានទេ។ បើយ៉ាងនេះ ខ្លួនអ្នកដែលជាមនុស្សល្ងង់ខ្លៅនោះ ត្រូវនឹងថានរណាក៏ឥតទម្លាក់កំហុសទៅវិញទៅមកដែរ

គឺថា យើងទាំងពីររូបសឹងដល់នូវសេរីភាព ឥតមានកាតព្វកិច្ចនឹងបំពេញទៅវិញទៅមកឡើយ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ប្រទានព្រះបរមពុទ្ធោវាទថា ម្នាលមាលុង្ក្យបុត្រ បើជនណាដណ្តឹងសួរអ្នកដោយបញ្ហាបែបនេះ ជននោះមុខជានឹងដល់នូវមរណភាពមុនពេលដែលតថាគតឆ្លើយតបពុំខានឡើយ ។ ឧបមាថា មានមនុស្សម្នាក់ត្រូវរបួសដោយព្រួញជ័រឆក់ ។ មាតាបិតា និង មិត្ររបស់អ្នកនោះ ទៅអញ្ជើញគ្រូពេទ្យឱ្យមកជួយដកព្រួញ និង ព្យាបាលរបួស ចំណែកអ្នករបួសនោះបែរជានិយាយទៅកាន់គ្រូពេទ្យថា ខ្ញុំមិនទាន់ឱ្យលោកគ្រូពេទ្យដកយកព្រួញចេញ មុននឹងដឹងថាបុគ្គលណាដែលបាញ់ខ្ញុំឱ្យរបួស បុគ្គលនោះឈ្មោះអ្វី ជាកូនចៅនរណា មុខមាត់វាបែបណា វាបាញ់ខ្ញុំដោយធ្នូណា ចន្លោះធ្នូនោះធ្វើដោយអ្វី ស្លាបសត្វណាដែលយកមកដាក់ភ្ជាប់នឹងព្រួញ? បើរង់ចាំចម្លើយបែបនេះ បុគ្គលនោះមុខជានឹងដល់នូវមរណៈមុនពេលដែលបានទទួលពត៌មានទាំងនេះមិនខានឡើយ ។

ម្នាលមាលុង្ក្យបុត្រ! ចូរអ្នកចាំទុកថា ការសម្រេចជាព្រះអរហន្ត ពុំមែនស្ថិតនៅលើចម្លើយនៃសំនួរទាំងនេះ ដែលជាសំនួរឥតប្រយោជន៍នោះទេ សភាវធម៌ដែលទៀងទាត់គឺ ជាតិ ជរា ព្យាធិ មរណៈ សោកទុក្ខ បរិទេវទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខ ត្រូវតែអ្នករំលត់ទុក្ខទាំងនេះដោយព្រះនិព្វាន ក្នុងជីវិតបច្ចុប្បន្ននេះ ។ ដោយហេតុនេះ ម្នាលមាលុង្ក្យបុត្រ ចូរអ្នកចាំហើយតម្កល់ក្នុងចិត្តថា ធម៌ណាដែលតថាគតបានសំដែង បានពន្យល់ដល់អ្នក ត្រូវទុក

ជាធម៌ពិត ធម៌មែន ធម៌ណាដែលតថាគតពុំបានប្រាប់ពន្យល់អ្នកទេ អ្នកកុំគប្បី យកទុកក្នុងចិត្តឡើយ។ ចុះហេតុដូចម្តេចបានជាតថាគតពុំបានប្រាប់ពន្យល់ ធម៌ដែលសួរនោះដល់អ្នក? ព្រោះតថាគតយល់ថាឥតប្រយោជន៍ ឥតមានជាប់ ជាបច្ច័យទៅនឹងជីវិតរបស់ព្រះអរហន្ត និង សាសនាតថាគតទេ។ ធម៌នោះពុំ មែនឆ្ពោះទៅរកការនឿយណាយ ការរលាស់ខ្លួនចេញចាកវដ្តទុក្ខ ដើម្បីនិព្វាន ឡើយ តថាគតតែងបង្រៀនថា សេចក្តីទុក្ខ កំណើតនៃទុក្ខ ការរំលត់ទុក្ខ និង ផ្លូវទៅកាន់ការរលត់ទុក្ខ ដោយសង្ខេប តថាគតប្រៀនប្រដៅតែធម៌មួយ គឺ **ទុក្ខ** និង **ការចេញចាកទុក្ខ**។

# នាមបញ្ញត្តិរបស់អ្នកប្រតិបត្តិព្រះពុទ្ធសាសនា

អ្នកកាន់ព្រះពុទ្ធសាសនាបានប្រតិបត្តិតាមធម៌ព្រះពុទ្ធមានប្រភេទផ្សេងៗគ្នា ត្រូវបាននាមបញ្ញត្តិ ទៅតាមការប្រតិបត្តិនោះ :

១- ពាក្យថា **ពុទ្ធមាមិកជន** ប្រែថា អ្នករាប់អានព្រះពុទ្ធ ឬរាប់អានព្រះពុទ្ធសាសនា គឺអ្នកដែលយល់ថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាពាក្យប្រៀនប្រដៅត្រឹមត្រូវមានសច្ចភាព ជាពាក្យដឹកនាំមនុស្សសត្វឱ្យចេញចាកទុក្ខ ក៏ស្រឡាញ់ចូលចិត្ត ពោលសរសើរ គាំទ្រ នូវពាក្យប្រៀនប្រដៅនោះ ហើយក៏ប្រតិបត្តិតាមធម៌ព្រះពុទ្ធផ្នែកណាមួយ ។

២-ពាក្យថា **ទាយក** ប្រែថា អ្នកឱ្យទានភេទបុរស **ទាយិកា**អ្នកឱ្យទានភេទស្ត្រី បានដល់បុរសស្ត្រីណាបានជួយសង្គ្រោះអ្នកដទៃដោយកម្លាំងកាយ កម្លាំងទ្រព្យសម្បត្តិ កម្លាំងគំនិតប្រាជ្ញា ជូនបាយទឹក នំ ចំណីដល់មាតាបិតា បូជាចំពោះព្រះសង្ឃដោយបច្ច័យ៤ លោកហៅថា **ទាយក ទាយិកា** ។

៣- ពាក្យថា **ឧបាសក ឧបាសិកា** ប្រែថា បុរសស្ត្រីណាដែលចូលទៅអង្គុយជិតព្រះរតនត្រ័យ ។ ពាក្យថា ចូលទៅអង្គុយជិត ពុំមែនចូលទៅអង្គុយជិតដោយរូបកាយទេ គឺចូលទៅអង្គុយជិតដោយខ្សែគំនិត គឺជឿគុណព្រះរតនត្រ័យ ។ បានសេចក្តីថា ជឿព្រះពុទ្ធជាអ្នកត្រាស់ដឹងនូវធម៌ ជឿព្រះធម៌ជាមាគ៌ាដឹកនាំសត្វឱ្យចេញចាកទុក្ខ ជឿព្រះសង្ឃជាអ្នកប្រតិបត្តិតាម **សីល សមាធិ បញ្ញា** ដើម្បីរំលត់ទុក្ខពិតមែន ជាពិសេសជឿកម្មនិង

ផលរបស់កម្ម ហើយប្រតិបត្តិតាម មានរក្សាសីលជាដើម ហៅថា **ឧបាសក ឧបាសិកា**។

៤- ពាក្យថា **ពុទ្ធសាសនិកជន** ប្រែថា ជនជាអ្នកពុទ្ធសាសនា គឺអ្នកអនុវត្តតាមធមិរបស់ព្រះពុទ្ធសាសនា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ យ៉ាងណា ក៏ប្រតិបត្តិតាមយ៉ាងនោះ គឺមានចរិតលក្ខណៈជាអ្នកពុទ្ធសាសនា ហៅថាពុទ្ធសាសនិកជន។ ពាក្យនេះ ហៅបានទាំងព្រះសង្ឃ ទាំងគ្រហស្ថ។

៥- ពាក្យថា **ពុទ្ធបរិស័ទ** ប្រែថា ការអង្គុយជុំវិញព្រះពុទ្ធ។ បាន សេចក្តីថា អ្នកអនុវត្តតាមឱវាទរបស់ព្រះពុទ្ធ ហើយរក្សាការពារនូវពាក្យ ប្រៀនប្រដៅរបស់ព្រះពុទ្ធមិនឱ្យបាត់បង់។ បើមានគេសង្ស័យអំពីធម្មវិន័យ របស់ព្រះពុទ្ធ តែងតែព្យាយាមដោះស្រាយតាមពាក្យប្រៀនប្រដៅរបស់ព្រះ អង្គ បង្ហាញសេចក្តីពិតដើម្បីកំចាត់បង់នូវសេចក្តីសង្ស័យនោះ។ ពាក្យថា អង្គុយជុំវិញបានសេចក្តីថា មានខ្សែគំនិតជុំវិញធម្មវិន័យរបស់ព្រះពុទ្ធ។ ពាក្យ ថា **ពុទ្ធបរិស័ទ** បានទាំងបព្វជិតបរិស័ទ ទាំងគ្រហស្ថបរិស័ទ។

៦- ពាក្យថា **ពុទ្ធសាវក** ប្រែថា សាវករបស់ព្រះពុទ្ធ។ សាវកនេះ លោកច្រើននិយាយសំដៅទៅលើព្រះអរហន្ត ដូចជាអគ្គសាវកទាំងពីរ គឺ**ព្រះ សារីបុត្ត**ជាសាវកស្តាំ និង **ព្រះមោគ្គល្លាន**ជាសាវកឆ្វេងរបស់ព្រះពុទ្ធ ឬសា- វកទាំង៨០ ហៅថាអសីតិមហាសាវកជាដើម។ សាវកនេះជាជំនួយយ៉ាងសំ- ខាន់ណាស់ដល់ព្រះអង្គក្នុងការជួយផ្សាយព្រះពុទ្ធសាសនា។

ដើម្បីឱ្យព្រះពុទ្ធសាសនាស្ថិតនៅនិងលូតលាស់ចំរើន ព្រះពុទ្ធសំដែងថា ដោយសារពុទ្ធបរិស័ទរបស់ព្រះអង្គទាំង៤ពួក គឺ **ភិក្ខុ ភិក្ខុនី ឧបាសក** និង **ឧបាសិកា** ប្រតិបត្តិតាមហេតុ៥ប្រការ គឺ :

**១. <u>ស្តាប់ធម៌ដោយគោរព</u>** : គឺព្យាយាមស្តាប់ធម្មទេសនា ស្តាប់ឱវាទ ស្តាប់ធម្មកថា ដែលនិយាយពន្យល់អំពីធម្មវិន័យរបស់ព្រះពុទ្ធ។ ក្រៅពីនោះ ឧស្សាហ៍ធ្វើធម្មសាកច្ឆា ធ្វើការសន្ទនាធម៌ ដើម្បីកំចាត់ការសង្ស័យក្នុងធម្មវិន័យរបស់ព្រះពុទ្ធ។

**២. <u>រៀនធម៌ដោយគោរព</u>** : គឺយកចិត្តទុកដាក់សិក្សារៀនសូត្រធម្មវិន័យរបស់ព្រះពុទ្ធឱ្យយល់ច្បាស់ដោយលើកយកគោលធំៗរបស់ព្រះអង្គមកសិក្សាជាមួយលោកអ្នកចេះដឹងព្រះពុទ្ធសាសនា។ ជាមួយគ្នានេះ ត្រូវស្រាវជ្រាវមើលគម្ពីរក្បួនច្បាប់ព្រះពុទ្ធសាសនាឱ្យបានច្រើនថែមទៀត។

**៣. <u>ទ្រទ្រង់ធម៌ដោយគោរព</u>** : គឺចងចាំនូវធម៌ដែលបានស្តាប់បានរៀនហើយឱ្យជាក់ជាប់ក្នុងចិត្ត ដែលក្នុងបាលីពោលថា **យោនិសោមនសិការៈ** ប្រែថា ការធ្វើទុកក្នុងចិត្តនូវធម៌ដោយឧបាយនៃបញ្ញា។

**៤. <u>ពិចារណានូវធម៌ដោយគោរព</u>** : គឺពិចារណាឱ្យយល់នូវអត្ថន័យ និង អត្ថរសនៃព្រះធម៌ឱ្យបានច្បាស់លាស់។

**៥. <u>ប្រតិបត្តិតាមធម៌ដោយគោរព</u>** : គឺប្រតិបត្តិតាមធម៌ ដែលបានយល់ច្បាស់ហើយដោយយកចិត្តទុកដាក់ រហូតឃើញច្បាស់ក្នុងចិត្តរបស់ខ្លួន ក្នុងបាលីថា **សន្ទិដ្ឋិកោ** ប្រែថា ដឹងពិតឃើញពិតនិងពាក្យថា **បច្ចត្តំ**

**ចេតសិកញ្ចោ** ប្រែថាឃើញច្បាស់ក្នុងចិត្តនៃខ្លួន គឺឃើញនូវខន្ធ៥មានរូបខន្ធជាដើម ប្រព្រឹត្តទៅជា **អនិច្ចំ ទុក្ខំ** និង **អនត្តា**។

# សិទ្ធិមនុស្សតាមន័យព្រះពុទ្ធសាសនា

ព្រះសម្មាសម្ពុទ្ធជាកំពូលនៃអ្នកគោរពសិទ្ធិមនុស្ស មិនតែប៉ុណ្ណោះ ព្រះអង្គបានណែនាំឱ្យមនុស្សគោរពសិទ្ធិនេះផង។ លើសពីនេះទៅទៀត ព្រះអង្គណែនាំឱ្យគេគោរពជីវិតទូទៅមានជីវិតសត្វតិរច្ឆានជាដើម ដូចជាធមិ **ធារណា** ក្នុងសិក្ខាបទនៃសីល៥ជាដើម។ ព្រះអង្គពន្យល់ថា មនុស្សនិងសត្វមានជីវិតមួយដូចគ្នា ស្រឡាញ់ជីវិត គឺមានជីវិតសញ្ញាដូចគ្នាខុសតែគុណធមិប៉ុណ្ណោះ។ ព្រះពុទ្ធប្រកាសប្រាប់ពិភពលោកឱ្យគោរពសិទ្ធិនេះ កន្លងទៅជាង ២៥៥០ឆ្នាំទៅហើយ ចំណែកអង្គការសហប្រជាជាតិ ទើបតែបានប្រកាសឱ្យមនុស្សគោរពសិទ្ធិមនុស្ស នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ នេះទេ។ អង្គការសហប្រជាជាតិបានសម្រេចចាត់ទុក **បុណ្យវិសាខបូជា** របស់ព្រះពុទ្ធសាសនាជាបុណ្យអន្តរជាតិ ដោយព្រះពុទ្ធសាសនាកើតមុនសាសនាដទៃ ហើយព្រះពុទ្ធបង្រៀនកុំឱ្យមនុស្សបៀតបៀនគ្នា គឺធមិអហិង្សាដែលជាមូលដ្ឋាននៃសន្តិភាពពិភពលោក។ តាមព្រះពុទ្ធសាសនា ការរំលោភសិទ្ធិមនុស្ស គឺការធ្វើឱ្យមនុស្សទទួលការឈឺចាប់ ដែលបណ្តាលមកពីការប្រព្រឹត្តពុំគប្បីពីបុគ្គលណាម្នាក់ឬសំណាក់អាជ្ញាធររដ្ឋាភិបាល។ លើសពីនេះទៀត ព្រះពុទ្ធសាសនាមិនត្រឹមតែគិតពីមារយាទមិនល្អមិនត្រឹមត្រូវរបស់បុគ្គលនិងសង្គមប៉ុណ្ណោះទេ ថែមទាំងគិតដល់ការប្រព្រឹត្តរវាងមនុស្សជាមួយសត្វតិរច្ឆាននិងរវាងមនុស្សជាមួយធម្មជាតិផងដែរ។ **សិទ្ធិ** ប្រែថា ផលសម្រេចគឺថាអំណាចដែលធម្មជាតិ

បានផ្តល់ឱ្យតាំងពីកំណើតមក។ ពាក្យថា **សិទ្ធិមនុស្ស** មកពី **សិទ្ធិ** និង **មនុស្ស** ប្រែថា ផលសម្រេចរបស់សត្វដែលមានវិចារណញ្ញាណ។ បានដល់អំណាចដែលមានលទ្ធភាពអាចធ្វើឱ្យទៅជាមនុស្សពេញលក្ខណៈ។ បានសេចក្តីថា **សិទ្ធិមនុស្ស** គឺជាអំណាចរបស់មនុស្សដែលត្រូវតែទទួលស្គាល់នូវសេចក្តីថ្លៃថ្នូរ ដែលមានតាំងពីកំណើតនិងសិទ្ធិទាំងឡាយដែលមិនអាចដកហូតបានពីមនុស្សទាំងអស់។ **សិទ្ធិ** ដែលមិនអាចដកហូតបានគឺ ជីវិត ការនិយាយ ស្តីប្រាសចាកទារុណកម្ម មិនអាចលក់ដូរកម្មសិទ្ធិឯកជនជាដើម។ **សិទ្ធិ មនុស្ស** ជាក្របខណ្ឌច្បាប់ធម្មជាតិ និងជាគ្រឹះនៃ **សេរីភាព សមភាព យុត្តិធម៌ សន្តិភាព ប្រជាធិបតេយ្យ** និងអភិវឌ្ឍន៍ក្នុងសង្គមនិងពិភពលោក។

**របបប្រជាធិបតេយ្យ** បានចាប់កំណើតតាំងពីបុរាណកាលនៅប្រទេសក្រិច។ ប្រជាពលរដ្ឋនៃទីក្រុងអាថែននៃប្រទេសក្រិចផ្លាស់ប្តូរវេនគ្នាតែងច្បាប់និងគ្រប់គ្រងភូមិស្រុករបស់ខ្លួន។ លុះដល់ពេលក្រោយមកប្រជាពលរដ្ឋកាន់តែមានចំនួនច្រើនឡើង ទើបគេចាត់តំណាងឱ្យធ្វើការជំនួយវិញ ហៅថាតំណាងប្រជាពលរដ្ឋដោយជ្រើសរើសអ្នកមានសមត្ថភាពម្នាក់ដឹកនាំសង្គម ហៅថា ប្រធានាធិបតី។ លុះសម័យក្រោយមក គេសិក្សាយកគោលគំនិតនេះខ្លះ មកច្នៃរចនាលទ្ធិប្រជាធិបតេយ្យឱ្យល្អប្រណីតឡើងតាមការយល់ឃើញនៃសង្គមប្រជាធិបតេយ្យសេរីរបស់ខ្លួន។ អ្នកមានប្រជាធិបតេយ្យ គឺទទួលស្គាល់នូវកិត្តិយស នូវផលប្រយោជន៍ នូវសេរីរបស់បុគ្គលម្នាក់ៗ។ គឺសេរីភាពនេះហើយដែលមានលទ្ធភាពអាចសម្រេចនូវទិសដៅរបស់ខ្លួនក្នុងសង្គម។

សេរីភាពជាគន្លឹះនៃការជឿនលឿនគ្រប់វិស័យ មានវិស័យសេដ្ឋកិច្ច និងវប្បធម៌ជាដើមនេះ ដោយសារអ្នកប្រជាធិបតេយ្យទទួលស្គាល់នូវសិទ្ធិនៃបុគ្គលម្នាក់ៗ ដែលគេពុំអាចរំលោភបាន ការអនុវត្តនៃលទ្ធិប្រជាធិបតេយ្យសេរីគឺប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ និងអ្នកដឹងនាំប្រទេសមានអំណាចឈរឈ្មោះឱ្យគេជ្រើសរើស មានអំណាចទិតៀននយោបាយអ្នកដឹកនាំ មានអំណាចដកហូតអ្នកដឹកនាំដែលប្រព្រឹត្តផ្ទុយអំពីប្រយោជន៍ជាតិ។ សង្គមប្រជាធិបតេយ្យសេរីបានចែកអំណាចទាំងបីឱ្យដាច់ចេញពីគ្នាមានលក្ខណៈឯករាជ្យរៀងខ្លួន គឺអំណាចនីតិបញ្ញត្តិ បានដល់សភាជាតិនិងព្រឹទ្ធសភា អំណាចនីតិប្រតិបត្តិ បានដល់រដ្ឋាភិបាលនិងអំណាចតុលាការដើម្បីការពារយុត្តិធម៌។ **ឯករាជ្យ** របស់តុលាការជាការសំខាន់ណាស់របស់សង្គមប្រជាធិបតេយ្យសេរី ព្រោះវាជាធាតុនៃយុត្តិធម៌នឹងធ្វើឱ្យសង្គមមានស្ថេរភាព។ បើសង្គមគ្មានយុត្តិធម៌ទេ ជាសង្គមគ្មានលំនឹងប្រកបដោយការចលាចល់មានការរំលោភនិងបំពានច្បាប់ ។

របបកុម្មុយនិស្តពុំមានលទ្ធិប្រជាធិតេយ្យទេ ព្រោះរបបនេះប្រើអំណាចកាប់សម្លាប់ប្រជាពលរដ្ឋតាមអំពើចិត្ត គ្មានតុលាការជំនុំជម្រះឡើយ ។ដកហូតសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋនិងបង្ខំឱ្យធ្វើការដូចទាសករ នេះហើយដែលគេហៅថា អំណាចផ្តាច់ការនៃ**វណ្ណៈអធន**។ យើងអាចរៀបរាប់ជាគោលនៃរបបកុម្មុយនិស្តគឺ ប្រជាពលរដ្ឋគ្មានសិទ្ធិជ្រើសរើសមេដឹកនាំរបស់ខ្លួន មានគណបក្សតែមួយ គឺគណបក្សកុម្មុយនិស្ត អ្នកដឹកនាំស្ថិតនៅលើតែមនុស្សម្នាក់

ឬមនុស្សតែមួយក្រុមតូចដែលហៅថា អង្គការឬមជ្ឈឹមបក្ស សិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋត្រូវចោលទាំងអស់។ ចំណែករបបផ្តាច់ការក៏ពុំមានលទ្ធិប្រជាធិតេយ្យដែរ ព្រោះរបបនេះការពារអំណាចរបស់ខ្លួនដោយប្រើអាវុធនិងប្រើអំពើហិង្សា ដើម្បីគំរាមប្រជាពលរដ្ឋនិងគណបក្សដែលប្រឆាំងជំទាស់នឹងគណបក្សរបស់ខ្លួន។ អំណាចតុលាការមានការលំអៀងទៅបម្រើជនផ្តាច់ការ។ សិទ្ធិធ្វើកូដកម្មបាតុកម្មត្រូវបិទ បើហ៊ានធ្វើគេនឹងបង្ក្រាបដោយចុងកាណុងដោយដំបងឆក់រហូតដល់បាញ់សម្លាប់។ ក្រៅពីនេះ អ្នកសារពត៌មានខ្លះដែលប្រឆាំងនឹងភាពខុសឆ្គងរបស់រដ្ឋាភិបាល បានត្រូវលួចបាញ់សម្លាប់ ឬឱ្យឡានដេញបុក ឬក៏ចោទឡើងតុលាការ ។

តាមការសង្កេត របបកុម្មុយនិស្ត និងរបបផ្តាច់ការ បានដួលរលំម្តងមួយៗហើយក្នុងពិភពលោក នៅសេសសល់ខ្លះនឹងត្រូវប្រជាពលរដ្ឋផ្តួលរំលំជាបន្តបន្ទាប់នៅពេលខាងមុខនេះ។ ចំណែករបប**ប្រជាធិបតេយ្យសេរី**នឹងកាន់តែចំរើនលូតលាស់ឡើងជាលំដាប់។ ចំពោះប្រទេសកម្ពុជានៅសល់ចំហាយរបបកុម្មុយនិស្តខ្លះ និងរបបផ្តាច់ការខ្លះ។ ទៅអនាគតយុវជនយុវនារីខ្មែរជឿនលឿននឹងលប់បំបាត់នូវចំហាយ ដែលសេសសល់នេះឱ្យអស់ពីកម្ពុជា ហើយសាងរបបប្រជាធិបតេយ្យពិតប្រាកដ តាមមាគ៌ាព្រះពុទ្ធសាសនាដែលគោរពសិទ្ធិប្រជាពលរដ្ឋជាមូលដ្ឋាន។

# អត្ថន័យរបស់ពាក្យលោភៈ

ពាក្យថា លោភចិត្ត ឬចិត្តលោភ ចេញមកពីបាលីថា **លោភោ** ប្រែថា សភាពធ្វើចិត្តឱ្យជាប់ជំពាក់នៅក្នុងអារម្មណ៍។ លោភចិត្តនេះ ជាអកុសលមូលមួយក្នុងចំណោមអកុសលមូលទាំងបីគឺ **លោភៈ ទោសៈ** និង **មោហៈ**។ អកុសលមូលទាំងបីនេះជាឫសគល់នៃអកុសលទាំងពួង។ រួចមកហើយមានអ្នកខ្លះយល់ច្រឡំថា បើព្រះពុទ្ធហាមមិនឱ្យមនុស្សលោភនឹងធ្វើឱ្យបង្អាក់ដំណើរនៃការលូតលាស់នៃសេដ្ឋកិច្ចជាតិ។ ការយល់បែបនេះ មកអំពីគេពុំយល់ពាក្យថា **លោភៈ** នេះឯង។ ប្រហែលជាគេយល់ថា កុំឱ្យលោភបានន័យថា កុំឱ្យចង់បានច្រើន ពុំមែនមានន័យដូច្នេះឡើយ។ មិនឱ្យលោភពុំមែនបានសេចក្ដីថា ហាមមិនឱ្យរៀនសូត្រ មិនឱ្យរកស៊ីធ្វើការចិញ្ចឹមជីវិតឡើយ សូម្បីព្រះសង្ឃព្រះពុទ្ធសាសនា ដែលលះបង់អ្វីទាំងអស់ហើយមកបួសក៏លោកស្វែងរកបច្ច័យ៤ ដើម្បីចិញ្ចឹមជីវិតប្រព្រឹត្តទៅជាធម្មតា។ ព្រះពុទ្ធមិនត្រឹមតែពុំហាមទេ ថែមទាំងដាស់តឿនឱ្យខំប្រឹងប្រែងថែមទៀត ដូចជាពាក្យថា **ឧដ្ឋានសម្បទា** ប្រែថា ការខំប្រឹងប្រែងរៀនសូត្រធ្វើការងារចិញ្ចឹមជីវិតឱ្យបានខ្លាំងក្លា តែត្រូវជៀសវាងការងារមិនប្រកបដោយធម៌ គឺការងារទុច្ចរិតនិងអយុត្តិធម៌។ **អារក្ខសម្បទា** មានចំណេះវិជ្ជាហើយបានទ្រព្យសម្បត្តិហើយ ត្រូវរក្សាឱ្យគង់វង់ជាដើម។ ធម៌នេះមាននិយាយក្នុងប្រយោជន៍បច្ចុប្បន្ន៤យ៉ាង។

ធម៌ដែលព្រះពុទ្ធមិនឱ្យលោភនេះ មានន័យដ៏ជ្រាលជ្រៅណាស់ ដែលជារូបមន្តរម្ងាប់សេចក្តីទុក្ខផ្លូវចិត្តរបស់មនុស្ស។ មានវិគ្គហៈថា **លុព្ភតីតិ លោភោ** កន្លែងខ្លះប្រែថាចង់បាន កន្លែងខ្លះប្រែថាការជាប់ចិត្ត។ របស់អ្វីទាំងអស់ ទាំងមានវិញ្ញាណ ទាំងឥតវិញ្ញាណ តែងតែស្ថិតនៅក្នុងភាពពុំទៀង តែងតែផ្លាស់ប្តូរប្រែប្រួល ហើយទីបំផុតត្រូវវិនាសត្រូវស្លាប់ទៅវិញ។ បើចិត្តមនុស្សនៅតែជាប់(លោភៈ)នូវរបស់ដែលវិនាសហើយនោះ គេនឹងកើតទុក្ខផ្លូវចិត្តចំពោះសត្វ(របស់មានវិញ្ញាណ) និងសង្ខារ(របស់ឥតវិញ្ញាណ) ដែលវិនាសបាត់បង់ទៅហើយនោះ។ ក្នុងទុក្ខ១២កង មានទុក្ខមួយកងពោលថា សេចក្តីទុក្ខកើតអំពីការបាត់បង់របស់ជាទីស្រឡាញ់របស់ខ្លួន (**បិយេហិ វិប្បយោ-គោ ទុក្ខោ**)។ ដូច្នេះបើចិត្តមិនជាប់(**អលោភៈ**) សេចក្តីទុក្ខផ្លូវចិត្តក៏ពុំមានដែរ។ ព្រះពុទ្ធសាសនាសំដែងឱ្យពិចារណាថា សង្ខារទាំងឡាកើតមកហើយតែងស្លាប់បាត់បង់ទៅវិញ មនុស្សសត្វទាំងឡាយតែងតែព្រាត់ប្រាសគ្នាជាធម្មតា ដូច្នេះការសោកស្តាយយំសោក ពុំអាចរស់ឡើងវិញឡើយ នាំតែខូចផ្លូវចិត្តប៉ុណ្ណោះ គួរតាំងចិត្តជាឧបេក្ខា ពិចារណាកម្មផលរបស់មនុស្សសត្វ។ បើមានធម៌ករុណាការអាណិតអាសូរចំពោះសត្វនិងសង្ខារ ដែលស្លាប់បាត់បង់ទៅដែលពុំអាចរស់ឡើងវិញបាននោះ, សេចក្តីសោកស្តាយតែងស្ថិតនៅជាប់ក្នុងចិត្ត មានខ្លះសោកស្តាយខ្លាំងរហូតធ្វើអត្តឃាតសម្លាប់ខ្លួនឯងក៏មាន។ ការសោយសោកនេះ មកអំពីចិត្តជាប់(លោភៈ) មិនពិចារណាឃើញការពិតហើយលះបង់ចិត្តជាប់នេះ។ បានសេចក្តីថា បើម្តាយឪពុក ជីដូនជីតា បងប្អូន

កូនចៅនៅរស់ត្រូវតែគោរពគ្នា សង្គ្រោះគ្នា ស្រឡាញ់រាប់អានគ្នា ដល់ពេលស្លាប់ ជាការបាត់បង់ព្រាត់ប្រាសគ្នា ត្រូវប្រើទឹកចិត្តមួយផ្សេងពីនេះ ដោយពិចារណាកម្មផលរបស់មនុស្សសត្វប្រកបដោយឧបេក្ខាចិត្ត បើចិត្តផ្លាស់ប្តូរមិនទាន់ ចិត្តរមែងកើតទុក្ខ។ ចិត្តរបស់មនុស្សបុថុជ្ជនផ្សេងពីចិត្តរបស់ព្រះអរិយបុគ្គលដែលជាព្រះអរហន្តមានញាណទស្សនៈឃើញការពិតថារូបរាងកាយរបស់មនុស្ស ដែលប្រកបដោយ ខន្ធ៥ គឺ **រូប វេទនា សញ្ញា សង្ខារ** និង **វិញ្ញាណ** ពុំមែនជាសត្វ ជាបុគ្គល មានសភាពសោះសូន្យទទេ។ បានសេចក្តីថា **ខន្ធ៥** គ្រាន់តែជាធាតុកើតឡើង តាំងនៅ និង រលត់ទៅវិញជាធម្មតា ជា **អនត្តា** មិនមែនខ្លួនជាសភាវធម៌ប្រព្រឹត្តទៅដោយខ្លួនវា ពុំអាចបង្គាប់បញ្ជាបានឡើយ ដូច្នេះហើយបានជាព្រះអរហន្តមាន**ព្រះពុទ្ធ**ជាដើម លោកពុំតក់ស្លុតភ័យខ្លាច សោកស្តាយនូវជីវិត ទោះបីដល់នូវសេចក្តីស្លាប់ក៏ដោយ។ លោកចាត់ទុករូបរាងកាយជាធាតុ៤ ដូចធាតុខាងក្រៅ បានជាមិនភ័យតក់ស្លុតព្រោះលោកមិនជាប់ (**អលោភៈ**)។ លោកនៅថែទាំរូបរាងកាយ និងប្រើប្រាស់បច្ច័យ៤ មានចីវរច្ច័យជាដើម ប៉ុន្តែបើរូបរាងកាយ និងវត្ថុទាំងនោះវិនាស ក៏លោកមានព្រះទ័យស្មើ មិនតក់ស្លុតមិនសោកស្តាយសោះឡើយ។ **លោភៈ** ការចង់បាន ឬការជាប់ជំពាក់ខ្លាំង អាចជម្រុញចិត្តឱ្យលួចទ្រព្យសម្បត្តិអ្នកដទៃ និងជម្រុញឱ្យធ្វើឃាតអ្នកដទៃ ដើម្បីបានទ្រព្យសម្បត្តិដូចជាចោរប្លន់ សម្លាប់អ្នកម្ចាស់ទ្រព្យ ឬចាប់ជំរិតមានទារប្រាក់ជាដើម។ បើអ្នក

រដ្ឋការវិញ ប្រព្រឹត្តអំពើពុករលួយដោយការលោភហួសព្រំដែន បាលីថា **អភិជ្ឈា វិសមលោភ** ប្រែថា ការសម្លឹងរំពៃចង់បានទ្រព្យសម្បត្តិអ្នកដទៃ និងទ្រព្យសម្បត្តិជាតិ។ ធម៌អកុសល គឺលោភៈនេះហើយដែលធ្វើឱ្យប្រទេសក្នុងពិភពលោកមានចោរលួច ចោរប្លន់ លួចរំកិលព្រំដែន កើតការវិវាទរវាងប្រទេសជិតខាងគ្នា ដូចប្រទេសកម្ពុជាដែលកំពុងមានបញ្ហាទឹកដីជាមួយប្រទេសជិតខាងទាំង៣ជាដើម។ ការរំលោភសិទ្ធិប្រជាពលរដ្ឋរបស់អ្នកកាន់អំណាច ក៏មកអំពីការលោភលន់ហួសប្រមាណនេះឯង។ សង្គ្រាមសកលលោកទាំងពីរលើកក៏បណ្តាលមកអំពីមហិច្ឆតា លោភលន់ចង់ត្រួតត្រាលើសកលលោកដាច់មុខតែម្នាក់ឯង។ **លោភៈ** គ្រប់សង្កត់បិទបាំងមិនឱ្យបុគ្គលនឹកឃើញភាពពុំទៀង (**អនិច្ចំ**) នៃរូបរាងកាយឡើយ។ គម្ពីរព្រះពុទ្ធសាសនាសំដែងថា កាលណាសន្តានចិត្តនៃមនុស្សក្រាស់ដោយ **លោភៈ** រមែងកើត **ឧបទ្រព្យ** និងអន្តរាយផ្សេងៗដល់មនុស្សក្នុងបច្ចុប្បន្ន ហើយមនុស្សសត្វដែលទៅកើតជាប្រេតក៏មកអំពី **លោភមូលចិត្ត** នេះដែរ។

ដូចបានពោលមកហើយ ព្រះពុទ្ធបានសំដែងក្នុងធម៌អភិធម្មអំពីលោភចិត្តនេះថា ជាឫសគល់នៃអកុសលទាំងឡាយ នាំសត្វឱ្យមានទុក្ខ។ បើមាន "**អលោភចិត្ត**" គឺចិត្តមិនលោភ ជាឫសគល់នៃកុសលទាំងឡាយ នាំឱ្យសត្វបានសុខ។ កាលណាចិត្តមិនលោភ បានន័យថាមិនជាប់ ទោះបីរបស់នោះវិនាសទៅក៏មិនកើតទុក្ខ នេះជាការដោះទុក្ខផ្លូវចិត្តយ៉ាងខ្ពស់បំផុត ដើម្បីចិត្ត

បរិសុទ្ធបំណងបំបាត់ទុក្ខ ព្រោះរបស់អ្វីទាំងអស់ដែលកើតឡើងពីគ្រឿងផ្សំតែងតែវិនាសទៅវិញជាធម្មតា។ **អានិសង្ស**នៃការមិនលោភនាំឱ្យមនុស្សប្រកបកិច្ចការងារគ្រប់យ៉ាងប្រកបដោយធម៌ (**សម្មាអាជីវៈ**) មិនត្រឹមតែធ្វើខ្លួនអ្នកប្រព្រឹត្តឱ្យបានសុខទេ ថែមទាំងធ្វើឱ្យសង្គមបានសុខផង ព្រោះពុំមានធម៌**អនិន្ទានទាន** ការលួចប្លន់។ ការមិនលោភមិនត្រឹមតែពុំបង្អាក់ដំណើរការលូតលាស់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិទេ ថែមទាំងធ្វើឱ្យសេដ្ឋកិច្ចទាំងពីរនេះលូតលាស់ថែមទៀត ព្រោះមនុស្សដែលមានចិត្តមិនលោភ ជាមនុស្សមានចិត្តខ្ពស់ មានបញ្ញាដ៏ជ្រាលជ្រៅ ខំប្រឹងប្រែងធ្វើជីវិតខ្លួន និងជីវិតសង្គមឱ្យចំរើនលូតលាស់ខាងសម្ភារៈ និងសីលធម៌ប្រកបដោយធម៌ ហើយរបស់ណាដែលបានមកឬកើតឡើងដោយធម៌ របស់នោះទុកគង់វង្សស្ថិតស្ថេរ។

# បុគ្គលធ្វើឱ្យអ្នកដទៃមានទុក្ខ តែងជាប់ជំពាក់ពៀរ

គាថាថា បុគ្គលណាប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយការធ្វើសេចក្តីទុក្ខឱ្យកើតមានដល់អ្នកដទៃ បុគ្គលនោះតែងជាប់ជំពាក់ដោយគ្រឿងជាប់ជំពាក់គឺ**ពៀរ** នឹងមិនរួចផុតអំពីពៀរវេរានះ ចេញពីបាលីថា **បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ វេរសំសគ្គ សំសដ្ឋោ វេរា សោ ន បរិមុច្ចតិ**។ គាថានេះមានសេចក្តីថា មនុស្សគ្រប់រូបតែងតែប្រាថ្នាសេចក្តីសុខដើម្បីខ្លួនចង់រស់នៅប្រកបដោយសេចក្តីចំរើនរុងរឿងដូចគ្នា។ ប៉ុន្តែមនុស្សខ្លះចង់បានសុខខ្លួនឯង បែរទៅជាបៀតបៀនអ្នកដទៃ ដែលជាហេតុនាំឱ្យមានទុក្ខដល់ខ្លួនទៅវិញ គឺការប្រព្រឹត្តធ្វើអំពើអាក្រក់ប៉ះពាល់ដល់សេចក្តីសុខរបស់អ្នកដទៃ។ **ព្រះពុទ្ធ**សំដែងថា មនុស្សកើតមកត្រូវបំពេញការងារ ប៉ុន្តែការងារដែលត្រឹមត្រូវ ការងារដែលមិនមានទោស ការងារដែលមិនធ្វើឱ្យអ្នកដទៃមានសេចក្តីទុក្ខព្រួយ ភ័យខ្លាច ឬធ្វើឱ្យគេវិនាស ប៉ុន្តែត្រូវបំពេញការងារប្រកបដោយសុចរិត ដែលហៅថា **សម្មាអាជីវោ** ប្រែថាការងារដ៏ប្រពៃ។ ខាងចុងនៃគាថានេះបញ្ជាក់ថា បើបុគ្គលបៀតបៀនធ្វើឱ្យគេមានទុក្ខ បុគ្គលនោះតែងទទួលផលបាបធ្វើឱ្យខ្លួនមានទុក្ខវិញតាមកម្រិតអកុសលដែលខ្លួនបានប្រព្រឹត្ត។ ពាក្យថា **ពៀរ** គឺផលនៃអំពើបាបនេះឯង។ ប៉ុន្តែពៀរម្យ៉ាងទៀតសំដៅយកការចងកំហឹងនឹងគ្នាពីជាតិនេះរហូតដល់ជាតិខាងមុខទៀត។

អំពើដែលធ្វើឱ្យគេមានទុក្ខ មានប្រភេទច្រើនយ៉ាង មានបុគ្គលខ្លះក្នុងលោកនេះចង់បានទ្រព្យសម្បត្តិអ្នកដទៃ ក៏ប្រព្រឹត្តការលួច ឆក់ ប្លន់ បើអ្នករដ្ឋការប្រព្រឹត្តអំពើពុករលួយ មានអ្នកលួច ឬប្លន់ខ្លះ ហ៊ានរហូតដល់សម្លាប់ម្ចាស់ទ្រព្យថែមទៀត។ ធ្វើឱ្យគេមានទុក្ខ គឺធ្វើឱ្យគេអស់ទ្រព្យសម្បត្តិ ហើយមានម្ចាស់ទ្រព្យខ្លះត្រូវបាត់បង់ជីវិតថែមទៀត។ ការលួចប្រពន្ធកូនរបស់អ្នកដទៃដើម្បីបំពេញតណ្ហារបស់ខ្លួន នេះជាការប៉ះពាល់ដល់សេចក្ដីសុខអ្នកដទៃដែលគេចង់ជួបជុំប្ដីប្រពន្ធកូនចៅ មិនចង់បែកបាក់គ្នាដូចខ្លួនអ្នកប្រព្រឹត្តអាក្រក់នោះដែរ។ បើអ្នកនយោបាយវិញ លួចសម្លាប់គ្នាដើម្បីបំពេញបំណងរបស់ខ្លួនដែលធ្វើឱ្យគ្រួសារគេព្រាត់ប្រាស់គ្នា ហើយធ្វើឱ្យជាតិមានអសន្តិសុខផង។ បើអ្នករដ្ឋការប្រព្រឹត្តអំពើពុករលួយ ស៊ីសំណូក ធ្វើឱ្យសេដ្ឋកិច្ចជាតិចុះទន់ខ្សោយធ្វើឱ្យប្រជាពលរដ្ឋមានភាពក្រីក្រ។ បើក្នុងប្រទេសកើតសង្គ្រាមនឹងគ្នាវិញនឹងធ្វើឱ្យប្រជាពលរដ្ឋស្លាប់ព្រាត់ប្រាស់គ្នា ពិការបាក់ដៃបាក់ជើង នេះជាសេចក្ដីទុក្ខដែលបង្កឡើងដោយបុគ្គលបាប។

អ្នកសាងបាបកម្មដោយការលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ឬរបស់ជាតិ បើគេចាប់បាននឹងទទួលទោសទណ្ឌកម្មក្នុងបច្ចុប្បន្ន បើគេចាប់ពុំបានទេក៏គេចពុំផុតអំពីទោសទៅមុខទៀតដែរ។ ក្នុងសុត្តន្តបិដក និយាយថា អ្នកដែលលួចទ្រព្យសម្បត្តិអ្នកដទៃ ស្លាប់ទៅធ្លាក់ទៅសោយទុក្ខក្នុងនរក លុះសេសសល់ផលកម្ម បើបានមកកើតជាមនុស្សវិញ បើមានទ្រព្យសម្បត្តិ ក៏ទុកពុំគង់ចេះតែវិនាសទៅវិញដោយហេតុផ្សេងៗ។ បើបុគ្គលសម្លាប់គេ ឬប្រើគេឱ្យ

សម្លាប់ បើគេចាប់បាននឹងមានទោសទណ្ឌកម្មក្នុងបច្ចុប្បន្នតាមច្បាប់របស់រដ្ឋ។ លុះបុគ្គលនោះស្លាប់ទៅ នឹងធ្លាក់ទៅសោយទុក្ខក្នុងនរក លុះសេសសល់ផលកម្ម បើបានកើតមកជាសត្វ ឬមនុស្សត្រូវគេសម្លាប់ជាច្រើនជាតិ មានអាយុខ្លីដោយទោសនៃការសម្លាប់គេពីជាតិមុន។ ដូច្នេះ តាមអត្ថន័យនៃពុទ្ធភាសិតខាងលើនេះបញ្ជាក់ថា បើបុគ្គលចង់បានសេចក្តីសុខដល់ខ្លួន មិនត្រូវបៀតបៀនមនុស្សសត្វដទៃទៀយ ផ្ទុយទៅវិញត្រូវសាងអំពើល្អ ព្រោះសេចក្តីសុខកើតពីការសាងអំពើល្អនេះឯង សមដូចពុទ្ធភាសិតមួយបទ ពោលថា **នត្ថិ សន្តិបរំ សុខំ** មានន័យថា សេចក្តីសុខកើតពីការស្ងប់គឺស្ងប់ពុំធ្វើអំពើបាបនេះឯង។

# បុណ្យកុសលដែលធ្វើជាតិនេះ ពុំមែនឱ្យផល តែជាតិខាងមុខតែម្យ៉ាងទេ

អ្នកដែលសិក្សាព្រះពុទ្ធសាសនាតិចច្រើនយល់ច្រឡំថា ការធ្វើបុណ្យកុសលជាតិនេះ សំរាប់ទទួលផលជាតិក្រោយ។ ការយល់នេះត្រូវបានមួយភាគ ពុំត្រឹមត្រូវទាំងអស់ទេ។ បុណ្យកុសលដែលគេធ្វើរមែងឱ្យផលតាំងពីជាតិនេះទៅ ដូចជាអានិសង្សក្នុងការធ្វើទាន រមែងមានគេស្រឡាញ់ គេរាប់អានច្រើន កេរ្តិ៍ឈ្មោះល្អរមែងផ្សាយទៅ ក៏ដូចជាការរក្សាសីល រមែងគេស្រឡាញ់គេទុកចិត្ត សប្បុរសតែងយកជាមិត្ត ទៅទីណាកន្លែងណាតែងមានសេចក្តីក្លាហានមិនសំយុងមុខចុះដោយសារខ្លួនជាអ្នកមានសីល ពុំបៀតបៀនអ្នកដទៃដែលនាំឱ្យមានសត្រូវជាដើម នេះជាផលដែលបានទទួលក្នុងបច្ចុប្បន្ន ពុំមែនចាំជាតិក្រោយឡើយ។ ព្រះពុទ្ធសាសនាបានពោលថា កម្មកុសល និង អកុសលខ្លះឱ្យផលតាមទម្ងន់ គឺអំពើល្អ និង អំពើអាក្រក់ធ្ងន់ ត្រូវឱ្យផលមុន ឯកម្មស្រាលត្រូវឱ្យផលក្រោយ។ កម្មខ្លះត្រូវឱ្យផលក្នុងពេលកំពុងប្រព្រឹត្ត កម្មខ្លះត្រូវឱ្យផលពុំទៀងពេលដែលត្រូវឱ្យផល ប្រៀបដូចជាឆ្កែដេញទន្សាយ ជួបពេលណាចាប់ខាំពេលនោះ។ មានកម្មខ្លះពុំអាចឱ្យផលបាន ដោយសារមានកម្មមួយផ្សេងពីនោះឱ្យផលកាត់មុខ។ កម្មខ្លះឱ្យផលជាតិនេះ ឬជាតិខាងមុខជាបន្តៗទៅទៀត។ ពុទ្ធសាសនាពោលថា បានជាកម្មឱ្យផលពុំទៀង ព្រោះមនុស្សបុថុជ្ជនធ្វើកម្មពុំទៀងដែរ ម្តងធ្វើល្អ ម្តងធ្វើអាក្រក់។ ផ្ទុយគ្នាពីមគ្គផល

របស់ព្រះអរិយបុគ្គល គឺបើមគ្គកើតឡើង ផលក៏កើតឡើងក្នុងលំដាប់គ្នា ដោយគ្មានកម្មណាមួយឱ្យផលកាត់មុខឡើយ។ សេចក្តីថា បើ **សោតាបត្តិមគ្គ** កើតឡើង **សោតាបត្តិផល** ក៏កើតឡើងរហូតដល់ **អរហត្តមគ្គ** កើតឡើង **អរហត្តផល** ក៏កើតឡើង។ អំពើល្អក្តី អាក្រក់ក្តី មិនថាតែអំពើមានទម្ងន់ធ្ងន់ទេ ទោះបីអំពើមានទម្ងន់ស្រាល ក៏តែងតែតាមឱ្យផល ប្រៀបដូចស្រមោលអន្ទោលតាមប្រាណ។ ពុទ្ធសាសនាពោលទៀតថា មតិករបស់មនុស្សសត្វពិតប្រាកដ គឺកម្មល្អ កម្មអាក្រក់នេះឯង (**កម្មទាយាទោ**)។ អំពើមួយត្រូវចេញជាផលមួយ ពុំមែនអំពើណាមួយគ្មានចេញផលនោះឡើយ ក៏ដូចជាហេតុមួយត្រូវចេញផលមួយដូចគ្នាដែរ នេះជាហេតុផលតាមច្បាប់ធម្មជាតិ។ ដូច្នេះ អ្នកដែលពោលថាធ្វើបុណ្យ មានការធ្វើទាន រក្សាសីលអប់រំចិត្តជាដើម ចាំទទួលផលនៅជាតិខាងមុខនោះ សូមប្រែការយល់ និង ពោលដូច្នេះវិញថា ធ្វើបុណ្យកុសលដើម្បីសាងខ្លួនឱ្យល្អ នឹងបានសុខចំរើនក្នុងជាតិនេះ និងជាតិខាងមុខ ទើបត្រឹមត្រូវតាមន័យរបស់ព្រះពុទ្ធសាសនា។

បញ្ហាមួយទៀត គេមិនត្រូវយល់ និងនិយាយតែមួយផ្នែកថាអ្នកដែលបានបុណ្យសក្តិ និងមានទ្រព្យសម្បត្តិច្រើនដោយសារបុណ្យពីជាតិមុននោះឡើយ។ ដើម្បីយល់ និង និយាយឱ្យត្រឹមត្រូវតាមន័យរបស់ព្រះពុទ្ធសាសនា គេត្រូវនិយាយថា អ្នកដែលបានបុណ្យស័ក្តិ និង មានទ្រព្យសម្បត្តិច្រើនក្នុងជាតិនេះ ដោយសារបុណ្យពីជាតិមុនផ្សំគ្នានឹងការខំប្រឹងប្រែងសិក្សារៀនសូត្រ និងធ្វើការងារល្អក្នុងជាតិនេះផង។ បានសេចក្តីថា មានឧបនិស្ស័យដោយបាន

សាងល្អពីជាតិមុន ហើយក្នុងជាតិនេះបានខំព្យាយាមសាងល្អទៀតផ្សំគ្នា ទើបកើតបានជាផលល្អបែបនេះ។ ត្រង់ន័យនេះ ស្របនឹងពាក្យនៅក្នុងមង្គលសូត្រថា ភាពនៃបុគ្គលដែលបានធ្វើបុណ្យពីជាតិមុន និងការដឹកលំខ្លួនដោយប្រពៃក្នុងបច្ចុប្បន្ន ចាត់ទុកជាមង្គលដ៏ឧត្តម។ ស្របនឹងពាក្យខ្មែរថា **ព្រេង** និង **ប្រឹង** ជាគូគ្នា។ បានសេចក្តីថា បើមានព្រេងវាសនាឬមានសំណាងដោយបានកសាងពីជាតិមុនក៏ដោយ បើមិនបានខំប្រឹងប្រែងព្យាយាមក្នុងផ្លូវល្អក្នុងជាតិនេះទៀតទេ ព្រេងវាសនានោះពុំអាចកើតឡើងឡើយ។ ប្រៀបដូចជាប្រេងមាននៅក្នុងល្ង ឬនៅក្នុងដូងទុំ បើមិនយកល្ងឬដូងនោះមករំងាស់ឱ្យចេញជាប្រេងទេ ប្រេងពុំអាចកើតឡើងបានឡើយ។ ដូចបុគ្គលមានគ្រាប់ពូជ បើពុំយកគ្រាប់ពូជនោះទៅបណ្តុះដាំ ដោយដាំលើដីល្អមានជីរជាតិ មានពន្លឺទេ គ្រាប់ពូជនោះពុំអាចដុះជាដើម បែកជាមែកបញ្ចេញជាផ្លែផ្កាបានឡើយ។ យ៉ាងណាមិញ គ្រាប់ពូជប្រៀបដូចបុណ្យពីជាតិមុន ការយកទៅដាំប្រៀបដូចជាការងារល្អក្នុងបច្ចុប្បន្ននេះ។ អំពើល្អពីអតីតជាតិ ផ្សំនឹងអំពើល្អក្នុងបច្ចុប្បន្នផង ទើបបុណ្យស័ក្តិនិងទ្រព្យសម្បត្តិកើតឡើងបាន។ បើបានមកដោយអំពើទុច្ចរិត ដូចជាចំណេះវិជ្ជាតិចលើកឱ្យធ្វើធំដោយសារបក្សពួក និងទ្រព្យសម្បត្តិបានមកដោយអំពើពុករលួយ រំលោភយកដីរបស់ប្រជាពលរដ្ឋជាដើម។ បុណ្យសក្តិនិងទ្រព្យសម្បត្តិនោះ ពុំមែនកើតឡើងដោយបុណ្យពីជាតិមុនឡើយ តែដោយអំពើទុច្ចរិត, ហើយរបស់ដែលបានមិនប្រកបដោយធម៌នេះនឹងត្រូវវិនាសទៅវិញក្នុងពេលណាមួយពុំខានឡើយ។

# ជំនួញខុស៥ប្រការ

**ព្រះសម្មាសម្ពុទ្ធ** ជាកំពូលនៃអ្នកគោរពសិទ្ធិមនុស្ស ព្រោះលក្ខណៈនៃព្រះពុទ្ធមានព្រះទ័យបរិសុទ្ធ ផុតចាកការបៀតបៀនហើយទើបមានព្រះនាមថា **វិសុទ្ធិគុណ**។ នៅក្នុងគម្ពីរព្រះត្រៃបិដក ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលចាត់ជាធម៌និងវិន័យនោះសុទ្ធតែជាពាក្យប្រៀនប្រដៅឱ្យលះបង់អំពើអាក្រក់គ្រប់យ៉ាង មានការបៀតបៀនអ្នកដទៃជាដើម **សព្វបាបស្ស អករណំ**។ ព្រះអង្គគោរពសិទ្ធិមនុស្សផង ណែនាំគេឱ្យគោរពផង។ មិនត្រឹមតែគោរពសិទ្ធិមនុស្សទេ ព្រះអង្គឱ្យគោរពសិទ្ធិសត្វផង ដូចជាធម៌ **បាណា** ក្នុងសិក្ខាបទទី១នៃសីល៥ជាដើម។ ធម៌ដែលព្រះអង្គណែនាំឱ្យគោរពសិទ្ធិមនុស្សមានចំនួនច្រើនណាស់ ពិសេសជំនួញ៥ប្រការដែលព្រះពុទ្ធហាមមិនឱ្យមនុស្សទូទៅជួញដូរឡើយ។ ជំនួញ៥ប្រការនោះគឺជំនួញគ្រឿងសាស្ត្រាវុធ ជំនួញមនុស្ស សម្លាប់សត្វយកសាច់ធ្វើជំនួញ ជំនួញគ្រឿងស្រវឹង និងជំនួញថ្នាំពិស។

**១_ សត្ថវណិជ្ជា** ប្រែថា ជំនួញគ្រឿងសាស្ត្រាវុធគ្រប់យ៉ាង ដូចជាកាំភ្លើងគ្រប់ធុនគ្រាប់បែកគ្រប់យ៉ាងជាដើម។ កាលជំនាន់ដើមមានត្រឹមតែធ្នូស្នា ក្រោយមក ពេលវិទ្យាសាស្ត្រលូតលាស់ គឺលូតលាស់ទាំងសម្ភារៈល្អ ទាំងសម្ភារៈអាក្រក់។ ការបង្កើតសម្ភារៈល្អសំរាប់សម្រួលជីវភាពការរស់នៅរបស់មនុស្សឱ្យបានខ្ពង់ខ្ពស់ល្អប្រសើរ ដូចជាថ្នាំពេទ្យ ទីលំនៅ ប្រដាប់ប្រដា

ប្រើប្រាស់ សំលៀកបំពាក់ ចំណីអាហារបរិភោគជាដើម។ ការបង្កើតសម្ភារៈអាក្រក់ដែលធ្វើឱ្យអន្តរាយដល់សង្គម ដូចជាការបង្កើតកាំភ្លើង គ្រាប់បែករហូតបង្កើតគ្រាប់បែកបរមាណូប្រល័យលោកជាដើម។ ព្រះពុទ្ធហាមមិនឱ្យផលិត មិនឱ្យលក់ដូរគ្រឿងសាស្ត្រាវុធទាំងនោះ ព្រោះនាំឱ្យយកទៅសម្លាប់គ្នា ដោយមនុស្សគ្រប់រូបចង់រស់នៅក្នុងសុខសន្តិភាព មិនចង់ឱ្យអ្នកណាម្នាក់បៀតបៀនខ្លួនឡើយ។ ការសម្លាប់គ្នា ឈ្មោះថាពុំគោរពជីវិតអ្នកដទៃ គឺពុំគោរពសិទ្ធិមនុស្សនេះឯង។ ព្រះពុទ្ធសំដែងថា ខ្លួនមានសិទ្ធិចង់រស់ មនុស្សសត្វដទៃក៏ចង់រស់ដូចខ្លួនដែរ ដូច្នេះចូរកុំបៀតបៀនអ្នកដទៃ។ នៅប្រទេសកម្ពុជាមានគ្រាប់កប់រាប់លានគ្រាប់ ពេលប៉ះទៅផ្ទុះធ្វើឱ្យប្រជាពលរដ្ឋខ្មែររាប់ពាន់រាប់ម៉ឺននាក់ត្រូវស្លាប់ និងពិការកំបុតដៃកំបុតជើង នេះដោយសារការផលិតការជួញការធ្វើសង្គ្រាមដែលពិភពលោកប្រជុំគ្នាបំបាត់កុំឱ្យមាន។

**២. សត្តវណិជ្ជា** សត្វក្នុងទីនេះសំដៅយកមនុស្ស គឺព្រះពុទ្ធហាមកុំឱ្យជួញ ឬលក់មនុស្ស។ ព្រះពុទ្ធសំដែងថា មនុស្សទោះបីមានឋានៈខ្ពស់ទាបយ៉ាងណាក៏ដោយ ក៏សុទ្ធតែមានតម្លៃដ៏ខ្ពស់ពុំអាចកាត់ថ្លៃបានឡើយ ដូច្នេះចូរកុំបន្ថោកបន្ទាបតម្លៃរបស់មនុស្ស គឺកុំចាប់មនុស្សលក់។ កាលពីសម័យដើម មានការចាប់មនុស្សលក់ឱ្យទៅបំរើគេដាច់ថ្លៃនេះហើយបានជាព្រះពុទ្ធហាម ដោយព្រះបំណងមិនឱ្យកើតមានអំពើបែបនេះតទៅទៀត។ នេះជាការរំលោភសិទ្ធិមនុស្ស ដែលមានជាតិជាមនុស្សដូចគ្នា។ បច្ចុប្បន្ននេះ ពិភពលោកកំពុងតែដោះស្រាយបំបាត់អំពើអមនុស្សធម៌នេះ ដូចបំបាត់ការចាប់ក្មេង

ស្ត្រីលក់ឱ្យធ្វើជាស្ត្រីពេស្យាជាដើម ។ ប្រទេសកម្ពុជាមានកើតបញ្ហានេះយ៉ាងខ្លាំងក្លា ដូចជាបញ្ឆោតស្ត្រីខ្មែរទៅលក់ដូរនៅក្នុងប្រទេស និងក្រៅប្រទេសឱ្យធ្វើជាស្ត្រីពេស្យា, ការរំលោភរបស់មនុស្សសាមញ្ញ ការរំលោភរបស់អ្នកមានអំណាច ឱ្យស្ត្រីខ្មែរបំរើខ្លួនក្នុងផ្លូវភេទក្នុងរូបភាពទិញដូរ ការរំលោភក្នុងរូបភាពទៅបំរើក្នុងគ្រួសារ ការរំលោភក្នុងរូបភាពបញ្ឆោតរៀបអាពាហ៍ពិពាហ៍ ការរំលោភក្នុងរូបភាពជួយរកការឱ្យធ្វើជាដើម ។ អំពើនេះកើតឡើងដោយសារភាពក្រីក្រ ភាពល្ងង់ខ្លៅ សីលធម៌ធ្លាក់ចុះ ប្រព័ន្ធច្បាប់ពុំតឹងតែង តុលាការពុករលួយ អ្នកកាន់អំណាចពុំមានសមត្ថភាព ។

**៣~ មំសវណិជ្ជា** ជួញសាច់ គឺសម្លាប់សត្វធ្វើជំនួញ ។ នេះជាជំនួញដែលព្រះពុទ្ធហាម ជាសីលធម៌មានទម្រឹតខ្ពស់របស់ព្រះពុទ្ធសាសនា ។ អ្នកដែលហ៊ានសម្លាប់មនុស្ស មកពីដំបូងរៀនសម្លាប់សត្វតិរច្ឆាន ។ ព្រះពុទ្ធបានបង្រៀនឱ្យពុទ្ធបរិស័ទរបស់ព្រះអង្គផ្សាយមេត្តាករុណាចំពោះសព្វសត្វក្នុងទិសទាំង១០។ មនុស្សនិងសត្វស្រឡាញ់ជីវិតដូចគ្នា ពុំមែនសត្វតិរច្ឆានណាមួយកើតឡើងសំរាប់ឱ្យគេសម្លាប់ធ្វើជាអាហារដូចជាសាសនាខ្លះពោលនោះឡើយ ។

**៤~ មជ្ជវណិជ្ជា** កុំផលិត កុំជួញគ្រឿងស្រវឹង គ្រឿងញៀនគ្រប់ប្រភេទ ដូចស្រា អាភៀនជាដើម ព្រោះនាំឱ្យគេយកទៅផឹកទៅជក់ នាំឱ្យអស់ទ្រព្យសម្បត្តិ នាំឱ្យកើតជម្លោះទាស់ទែងគ្នា នាំឱ្យកើតរោគ នាំឱ្យខូចសតិស្មារតី នាំឱ្យខូចការងារដែលត្រូវធ្វើ ។

**៥. វិសវណិជ្ជា** កុំផលិតកុំជួញថ្នាំពិស ថ្នាំពុលនាំឱ្យយកទៅសម្លាប់គ្នា នេះជាការរំលោភសិទ្ធិមនុស្ស ។

បើមនុស្សគ្រប់រូបមិនជួញនូវជំនួញទាំង៥ប្រការនេះ នឹងធ្វើឱ្យពិភពលោកមានសន្តិភាព ជាការគោរពសិទ្ធិមនុស្សដល់ឫសគល់ មានជម្រៅជាងសិទ្ធិមនុស្សដែលអង្គការសហប្រជាជាតិបានប្រកាសកាល ពីថ្ងៃ១០ធ្នូ ១៩៤៨ ទៅទៀត ។

# ចូរយកខ្លួន និង ធម៌ជាទីពឹង

ពុទ្ធភាសិតមួយបទពោលថា **អត្តទីបា ភិក្ខវេ ធម្មទីបា វិហរថ អនញ្ញសរណា** ប្រែថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកយកខ្លួនអ្នកជាទីពឹង និងយកធម៌ជាទីពឹង អ្វីដទៃក្រៅពីខ្លួនអ្នកនិងធម៌ ពុំមែនជាទីពឹងរបស់អ្នកឡើយ។

ពាក្យថា **យកខ្លួនជាទីពឹង** បានសេចក្តីថា សកម្មភាពល្អគ្រប់យ៉ាងត្រូវកើតចេញមកពីខ្លួនឯង អ្នកដទៃពុំអាចធ្វើសេចក្តីល្អជំនួសខ្លួនបានឡើយ។ ស្របនឹងពុទ្ធភាសិតមួយបទទៀតពោលថា សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធកើតចេញមកពីខ្លួនឯង អ្នកដទៃពុំអាចញ៉ាំងអ្នកដទៃឱ្យបរិសុទ្ធ និងមិនបរិសុទ្ធបានឡើយ។ ព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើមដែលបានសម្រេចធម៌ជាន់ខ្ពស់ពោលគឺព្រះនិព្វានជាការរំលត់ទុក្ខ ដោយសារលោកប្រតិបត្តិធម៌ដោយព្រះអង្គឯង។ កុំថាឡើយអ្នកដទៃ សូម្បីម្តាយឪពុកកូនចៅ ប្តីប្រពន្ធ ក៏ពុំអាចធ្វើសេចក្តីល្អឱ្យដល់គ្នា ឬជួសគ្នាបានឡើយ។

ពាក្យថា **យកធម៌ជាទីពឹង** បានសេចក្តីថា យកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធមកអនុវត្តតាម គឺព្រះអង្គបានបង្ហាញនូវព្រះធម៌ដែលជាមាគ៌ានាំមនុស្សសត្វទៅរកសេចក្តីសុខក្សេមក្សាន្តក្នុងសង្គមមនុស្ស និងសុខជាន់ខ្ពស់គឺព្រះនិព្វាន។ មាគ៌ានៃព្រះធម៌គឺ **ទាន សីល ភាវនា** សំរាប់គ្រហស្ថប្រតិបត្តិ និង **សីល សមាធិ បញ្ញា** សំរាប់បព្វជិតប្រតិបត្តិ បានសេចក្តីថា

ពុទ្ធបរិស័ទយកខ្លួនជាទីពឹង គឺប្រតិបត្តិដោយខ្លួនឯងហើយ, តើប្រតិបត្តិតាមផ្លូវណា គឺប្រតិបត្តិតាម **ព្រះធម៌** គឺ **មគ្គប្រកបដោយអង្គ៨** ដែលជាមាគ៌ាចេញចាកទុក្ខដែលព្រះពុទ្ធបានសំដែង។ ព្រះពុទ្ធដូចជាអ្នកបង្ហាញផ្លូវគឺព្រះធមិឯមនុស្សសត្វត្រូវដើរគឺប្រតិបត្តិតាមព្រះធមិដោយខ្លួនឯង។ ប្រៀបដូចអ្នកស្គាល់ផ្លូវបានប្រាប់អ្នកវង្វេងផ្លូវ ត្រូវអ្នកវង្វេងផ្លូវដើរដោយខ្លួនឯង ពុំអាចឱ្យអ្នកស្គាល់ផ្លូវដើរជួសអ្នកវង្វេងផ្លូវបានឡើយ ក៏មានន័យដូចគ្នានេះដែរ។

ពាក្យថា **ក្រៅពីខ្លួន** និង **ក្រៅពីព្រះធម៌** ពុំមែនជាទីពឹង បានសេចក្ដីថា សេចក្ដីសុខចំរើនគ្រប់យ៉ាងកើតអំពីអំពើល្អរបស់ខ្លួន ដូចពុទ្ធភាសិតថាសត្វទាំងឡាយមានកម្មជារបស់ខ្លួន ( **កម្មស្សកោម្ហិ** )។ ឯអ្នកដែលអាចប្រព្រឹត្តល្អបាន លុះត្រាតែបានសិក្សា បានស្ដាប់ផ្លូវល្អ បានដល់ការស្ដាប់ព្រះធមិហ្នឹងឯង។ ដូច្នេះក្នុងន័យនេះបញ្ជាក់ថា ទេវតា ព្រះឥន្ទ ព្រះព្រហ្មព្រះអាទិទេព ពុំអាចជួយខ្លួនឱ្យបានសុខឡើយ នេះជាច្បាប់កម្មផលរបស់ព្រះពុទ្ធសាសនា។

# គុណវិបត្តិនៃការអុជធូប

ក្នុងធម៌នមស្ការដែលពុទ្ធបរិស័ទខ្មែរតែងសូត្រជាដំបូងថា : **ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ** ដែលប្រែថា ខ្ញុំព្រះករុណាសូមបូជាចំពោះនូវ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ដោយគ្រឿងសក្ការៈទាំងឡាយមានទៀន និងធូបជាដើមនេះ ។ល។ ***អត្ថបទនេះពុំមែនជាពាក្យរបស់ព្រះពុទ្ធសម្តែងទេ*** គឺជាពាក្យរបស់អ្នកប្រាជ្ញព្រះពុទ្ធសាសនាខ្មែរតែងសម័យក្រោយ ប៉ុន្តែពុំអាចស្រាវជ្រាវឃើញឈ្មោះ ឬក្រុមអ្នកតែងអត្ថបទនេះទេ។ នៅសម័យពុទ្ធកាល ពុំឃើញមានប្រើពាក្យធូបទេ តែមានប្រើពាក្យ**ប្រទីប**(ពន្លឺ) និង **បុប្ផ**(ផ្កា) គឺគេបូជាចំពោះព្រះរតនត្រ័យមានព្រះពុទ្ធជាដើម ដោយពន្លឺគឺ ទៀន និងផ្កា ឬដោយគ្រឿងក្រអូបផ្សេងៗ ដូចជាគន្ធកុដិ ដែលព្រះពុទ្ធគង់នៅ **វត្តជេតពន ត្រូវនាងវិសាខា** តែងដាក់គ្រឿងក្រអូបក្នុងកុដិព្រះអង្គ ដូច្នេះហើយបានជាមហាជនតែងហៅកុដិព្រះអង្គថា **គន្ធកុដិ** ប្រែថា កុដិក្លិន គឺកុដិមានក្លិនក្រអូប។ ពាក្យ **ធូប** នេះចេញពីភាសាបាលីប្រែថា **ផ្សែង** *(ទំនងជាទាក់ទងនឹងសាសនាព្រាហ្មណ៍)*។ តាមសាសនាព្រាហ្មណ៍ ដើម្បីឱ្យព្រះឥន្ទ ព្រះព្រហ្ម ប្រទានពរឱ្យពួកគេបានសុខ គេតែងបូជាយញ្ញ មានចាប់សត្វដុតទាំងរស់ មានពេលខ្លះចាប់មនុស្សដុតទាំងរស់ថែមទៀត។ ឯទូតដែលឱ្យដំណឹងទៅព្រះឥន្ទ និង ព្រះព្រហ្មថាខ្លួន (ពួកព្រាហ្មណ៍) បូជានោះ គឺផ្សែង(ធូប) នេះឯង។ ដូច្នេះធូបនេះចេញពីសាសនា

ព្រាហ្មណ៍ដែលប្រែថាផ្សែង គឺផ្សែងចេញពីការបូជាយញ្ញ ហុយឡើងទៅលើ ជាទូតឱ្យដំណឹងទៅព្រះអាទិទេពរបស់គេ ពុំមែនជាធូបដូចខ្មែរធ្វើដូចសព្វថ្ងៃនេះទេ។ នៅប្រទេសភូមា ប្រទេសសេរីលង្កា ប្រទេសនេប៉ាល់ដែលកាន់ **ព្រះពុទ្ធសាសនាថេរវាទ**ដូចខ្មែរ គេមិនប្រើធូបពេលធ្វើសក្ការបូជាចំពោះគុណព្រះរតនត្រ័យទេ គឺគេប្រើទៀននិងផ្កា។ ការប្រើធូប ក្រៅពីប្រទេសកម្ពុជា មានប្រទេសថៃ និងប្រទេសលាវប្រើធូបដូចប្រទេសខ្មែរដែរ។

ការអុចធូបបូជាព្រះរតនត្រ័យ តាមទម្លាប់ពុទ្ធសាសនិកជនខ្មែរនេះ មានផលវិបាកអាក្រក់ណាស់ដល់សុខភាពមនុស្សពេលដែលគេដកដង្ហើមស្រូបយកផ្សែងធូប ព្រោះផ្សែងធូបមានជាតិពុល កាត់យកខ្យល់អុកស៊ីសែនដែលបន្សុទ្ធឈាមឱ្យថ្លាស្អាតបំបាត់ជាតិពុលតាមរយៈការដកដង្ហើម។ ផលវិបាកអាក្រក់ម្យ៉ាងទៀត បើដុតធូបក្នុងកុដិ ក្នុងសាលា ក្នុងព្រះវិហារ នាំឱ្យខ្មៅត្រង់កន្លែងដែលដុតនោះ ដោយសារផ្សែងហុយទៅប៉ះជិតជាប់។ ការដុតធូបបានន័យថា ការបូជាផ្សែង តើមានប្រយោជន៍អ្វីក្នុងការបូជាផ្សែងដែលជាគ្រឿងពុលនេះដល់ព្រះពុទ្ធ។ បើព្រះពុទ្ធគង់ព្រះជន្មនៅ ហើយគេអុជធូបបូជានៅចំពោះព្រះភ័ក្ត្រ តើព្រះអង្គសព្វព្រះទ័យឬទេ? នៅពេលដែលព្រះអង្គស្រូបយកផ្សែងជាតិពុលនេះ។ ព្រះពុទ្ធនឹងហាមឃាត់ពុទ្ធបរិស័ទមិនឱ្យប្រព្រឹត្តធ្វើគ្រឿងបូជាខុសក្បួនអនាម័យបែបនេះពុំខាន។ ព្រះពុទ្ធសម្តែងថា ការធ្វើសក្ការបូជាចំពោះព្រះរតនត្រ័យដោយចិត្តជ្រះថ្លា បានផលបានអានិសង្សហើយចំពោះគ្រឿងសក្ការបូជាដែលមិនប៉ះពាល់ដល់សុខភាព គឺមិននាំឱ្យមានជម្ងឺ។

បើបូជាចំពោះវត្ថុដូចជាផ្សែងធូបនេះនាំឱ្យមានជម្ងឺមិនត្រឹមតែមិនបានអានិ-សង្សទេ ថែមទាំងទទួលបាបថែមទៀត ព្រោះនាំឱ្យវិលមុខនៃអ្នកទៅរួមបុណ្យដោយការស្រូបយកផ្សែងធូប ។

ការបូជាដែលបានផលបានអានិសង្សច្រើន គឺ **<u>បដិបត្តិបូជា</u>** ប្រែថា ការបូជាដោយប្រតិបត្តិតាម **សីល សមាធិ បញ្ញា** ប្រសើរជាងការធ្វើសក្ការបូជាដោយគ្រឿងសក្ការបូជាទាំងឡាយមានផ្កាជាដើម ។ បើនៅតែចង់បូជានូវគ្រឿងសក្ការបូជា គួរដកយកធូបចេញកុំបូជា គួរបូជាតែផ្កា ឬពន្លឺដូចជុតទៀនជាដើមបានហើយ ។ ក្នុងន័យនេះ បើនៅតែចង់សូត្រធមិ **ឥមេហិ** នេះគួរដកពាក្យថា **ធូបា** ចេញ ហើយបញ្ចូលពាក្យ **បុប្ផ** វិញ គឺបញ្ចូលថា **ឥមេហិ ទីបបុប្ផទីសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ** ប្រែថា ខ្ញុំព្រះករុណាសូមបូជាចំពោះនូវ **ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ** ជាម្ចាស់ដោយគ្រឿងសក្ការបូជាទាំងឡាយមានទៀន និងផ្កាជាដើមនេះ។ ត្រង់នេះគេអាចកែបាន ព្រោះមិនមានជាពាក្យព្រះពុទ្ធដីកា ជាពាក្យរបស់ខ្មែរចងក្រងជំនាន់ក្រោយ ព្រោះសូម្បីតែថៃ និងលាវ ដែលប្រើការអុជធូបដែរនោះ ពុំមានធមិ **ឥមេហិ** នេះទេ។ សូមកុំយល់ថា ទម្លាប់ដែលធ្លាប់ធ្វើមកហើយ បើមិនធ្វើនាំឱ្យមានទោសនោះឡើយ ។ ទម្លាប់ខ្លះគេអាចកែបានបើទម្លាប់នោះមិនល្អ ដោយកែទៅរកទម្លាប់ល្អឆ្ពោះទៅរកការជឿនលឿន ដូចធមិចាស់ធមិថ្មី គឺធមិចាស់ជាធមិមិនបកប្រែ នៅសូត្រជាភាសាបាលី ឯធមិថ្មីគឺបកប្រែឱ្យស្ដាប់សេចក្ដីបាន វៀរលែងតែពាក្យព្រះពុទ្ធដីកាដែលគេពុំ

អាចកែប្រែបាន។ បើថ្វាយបង្គំមិនបានអុជទៀន ឬបូជាផ្កា ក៏មិនមានទាស់ខុសអ្វីឡើយ គ្មានព្រះវិន័យណាចែងថាថ្វាយបង្គំត្រូវតែអុជទៀនធូបឬបូជាផ្កាឡើយ បើមានក៏បូជាទៅ។ ការថ្វាយបង្គំនេះ មានន័យជាពិសេសគឺនឹកដល់គុណ **ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ** នេះឯង។ មានអ្នកខ្លះថា បើសូត្រ **ឥមេហិ** មិនបានអុជទៀនជាដើមទេ មិនហ៊ានសូត្រទេ ព្រោះកុហកព្រះ។ យល់ដូច្នេះក៏ត្រូវ មិនសូត្រក៏បាន ប៉ុន្តែបើទម្លាប់សូត្រទៅហើយ បើសូត្រទៅដោយតាំងចិត្តថាទៀនផ្កានៅក្នុងចិត្តក៏គ្មានទាស់ខុសអ្វីដែរ ព្រោះបើមិនសូត្រ **ឥមេហិ** សូត្រសង្ខេប ក៏មានពាក្យថ្វាយគ្រឿងសក្ការបូជានៅក្នុងនោះដែរ។

នៅពេលភ្ជុំបិណ្ឌ ពេលចូលឆ្នាំ ពុទ្ធបរិស័ទអុជធូបហុយទ្រលោមសំបូងសំរូងប្រតិស្ឋអធិដ្ឋាន សុំសេចក្តីសុខ និង ឧទ្ទិសកុសល ដល់ មាតាបិតាជីដូនជីតា ញាតិកាលសន្តាន។ ចុះបើមិនអុជធូបសំបូងសំរូងមិនកើតឬ? តាមពិតការអធិដ្ឋានចិត្តពុំមែនស្ថិតនៅលើធូបទេ គឺស្ថិតនៅលើផ្លូវចិត្តវិញទេ។ ផលវិបាកអាក្រក់មួយទៀត ការអុជទៀនធូបដោយភ្លេចពន្លត់ ខ្យល់បក់មករលំទៅឆេះរបស់របរផ្សេងៗ រហូតខ្លះមានឆេះផ្ទះទៀតផង។ តាមសេចក្តីដូចបានពោលមកហើយនេះ គួរអ្នកទទួលខុសត្រូវខាងព្រះពុទ្ធសាសនា និងពុទ្ធបរិស័ទខ្មែរទូទៅយកទៅពិចារណា គួរឈប់ប្រើធូបក្នុងការធ្វើសក្ការបូជាចំពោះព្រះរតនត្រ័យ ដោយកែធមិ **ឥមេហិ** ត្រង់ **ធូបា** មកជា **បុប្ផ** វិញ គឺបូជាប្រទីបមានភ្លើងទៀនជាដើម និងផ្កាគ្រឿងក្រអូបជាដើមវិញ ដើម្បីអនាម័យដូចប្រទេសភូមា ប្រទេសស្រីលង្កាជាដើម គេប្រើតែទៀន និងផ្កា គេមិនប្រើ

ធូបឡើយ ។ ទោះបីពុទ្ធបរិស័ទអុជធូបនៅខាងក្រៅកុដិ សាលា វិហារក៏ដោយ ក៏ពុំឃើញមានប្រយោជន៍ដែលកើតអំពីការអុជធូបនេះឡើយ ឃើញតែចំណាយថវិកាក្នុងការជាវធូបមកអុជអស់ប្រាក់កាសប៉ុណ្ណោះ ។ បើឈប់អុជមិនទាន់បាន គួរអុជនៅខាងក្រៅកុដិសាលាព្រះវិហារ ។ ថ្ងៃក្រោយគួរឈប់អុជតែម្តង ។

## **នាមអ្នកបរិច្ចាគបច្ច័យបោះពុម្ព**

ឈឈឈ❁៚៚៚

១. ឧបាសក **ឡូ ប៊ុនឡេង** និង ឧបាសិកា **អៀប ឆៃគីម**

ព្រមទាំងកូនចៅ $៥៣០

២. លោក **យឿង ហុង** និងភរិយា ព្រមទាំងកូន $២០០

៣. **នាង សួសហាន** និងកូនចៅ $៤០

៤. ឧបាសិកា **នាង ញ៉** និង ស្វាមី $២០

៥. ឧបាសិកា **វង្ស ម៉ៅ** ឧបាសិកា **ឆាន់ កាន់ជួង** $២០

៦. ឧបាសិកា **ឆាន់ ហ៊ួង** និងកូនចៅ $២០

៧. ឧបាសិកា **ឈុន យេន** $២០

៨. ឧបាសិកា **គឹម ស៊ីមឿន** ព្រមទាំងកូនចៅ $២០

៩. ឧបាសិកា **យឹម លិម** និងកូនចៅ $១០

សៀវភៅនេះចែកជាធម្មទាន ទូរស័ព្ទទំនាក់ទំនង:

ក. ព្រះភិក្ខុ **វិបុល** ០១១ ២២៥ ៥៤៧ និង

០១២ ៣១២ ៩០៨

ខ. ឧបាសិកា **សាមឿន** ០១២ ២២១ ៥០៥

---

វាយអត្ថបទដោយព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា**